ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងរ៉ែ និងថាមពល

# ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល ២០២១-២០២៣

រៀបរៀងដោយក្រុមការងារប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពល

ខែធ្នូ ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០០១ រថ.អថ.ប្រក

ថ្ងៃចន្ទ ១៣រោចខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១

# ប្រកាស

## ស្តីពីការដាក់ឱ្យអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពលឆ្នាំ ២០២១-២០២៣

## ក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ ០៣២១.រថ.អថ. ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានា នៃអគ្គនាយកដ្ឋានថាមពល
- យោងតាមស្មារតីកិច្ចប្រជុំពិភាក្សា និងពិនិត្យសម្រេចលើឯកសារផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពលឆ្នាំ ២០២១-២០២៣ លើកចុងក្រោយ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០
- យោងតាមការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

### ប្រការ ១_

ដាក់ឱ្យអនុវត្ត "ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល ឆ្នាំ២០២១-២០២៣" ដើម្បីចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា។



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

**ប្រការ ២_**

ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល ឆ្នាំ២០២១-២០២៣ ដែលបានដាក់ឱ្យអនុវត្តនៅក្នុងប្រការ ១ ខាងលើ មានខ្លឹមសារទាំងស្រុងដូចឧបសម្ព័ន្ធភ្ជាប់មកជាមួយ។

**ប្រការ ៣_**

អង្គភាព និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលរួមមាន អគ្គនាយកដ្ឋានថាមពល មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា និងមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ត្រូវរួមគ្នាអនុវត្ត "ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល ឆ្នាំ២០២១-២០២៣" ដែលបានដាក់ឱ្យអនុវត្តក្នុងប្រការ ១ ខាងលើ ឱ្យបានសុក្រឹត និងមានប្រសិទ្ធភាព ដើម្បីចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ ៤_**

ប្រកាស និងសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥_**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

ក្រសួងរ៉ែ និង ថាមពល

ស៊ុយ សែម

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី-ខេត្ត

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# អារម្ភកថា

ក្រសួងរ៉ែ និងថាមពល បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល ដែលមានបេសកកម្មដឹកនាំគ្រប់គ្រង និងអភិវឌ្ឍ វិស័យរ៉ែ និងថាមពល រួមទាំងវិស័យប្រេងកាត បរិមាណូស៊ីវិល-វិទ្យុសកម្ម និងអគ្គិសនី ដែលក្នុងនេះ វិស័យថាមពល ប្រេងកាត បរិមាណូស៊ីវិល-វិទ្យុសកម្ម និងអគ្គិសនី អាចហៅខ្លីថា"វិស័យថាមពល"។ វិស័យទាំងនេះបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រស្រប តាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងយុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា។ ការអភិវឌ្ឍវិស័យខាងលើនេះបានផ្សាភ្ជាប់យ៉ាងស៊ីជម្រៅជាមួយនឹងអត្ថប្រយោជន៍សម្រាប់និរន្តរភាពសង្គម សេដ្ឋកិច្ចនិងបរិស្ថាន ។

វិស័យថាមពលបានចូលរួមចំណែកដោយផ្ទាល់ និងជាគន្លឹះដ៏សំខាន់សម្រាប់ជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យផ្សេងទៀត រួមមានសហគ្រាសធុនតូចនិងមធ្យម ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម ការដឹកជញ្ជូន ការអភិវឌ្ឍតំបន់ជនបទ និងការបង្កើនសុខដុមនីយភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ ដែលនាំឱ្យមានការ បង្កើតការងារ បង្កើនប្រាក់ចំណូលដល់ប្រជាជន បង្កើនចំណូលជាតិក៏ដូចជាធ្វើឱ្យផលិតផលក្នុងស្រុកសរុប សម្រាប់សង្គម និងសេដ្ឋកិច្ចទាំងមូលឱ្យកាន់តែប្រសើរឡើង។ ក្នុងខណៈពេលដែលព្រះរាជាណាចក្រកម្ពុជា កាន់តែមានស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចជាតិកាន់តែមានភាពរីកចំរើន នោះសេចក្តីត្រូវការ និងភាពចាំបាច់ នៃថាមពលអគ្គិសនីក៏កាន់តែកើនឡើងដែរ ដូច្នេះការរៀបចំធ្វើការអភិវឌ្ឍវិស័យថាមពលអគ្គិសនីយ៉ាងណា ដើម្បីឱ្យកម្ពុជាមានការផ្គត់ផ្គង់អគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមាន ថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំង ព្រះរាជាណាចក្រកម្ពុជាគឺជារបៀបវារៈ មួយដែលចាំបាច់ និងសំខាន់បំផុតរបស់រាជរដ្ឋាភិបាលក្នុងវិស័យថាមពលអគ្គិសនីនៅនីតិកាលទី៦នៃរដ្ឋសភា។ ក្រសួងរ៉ែ និងថាមពលបានខិតខំកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់លើបរិស្ថានធម្មជាតិ និងសង្គម ដែលអាចកើតឡើងដោយសារគម្រោងអភិវឌ្ឍន៍វិស័យថាមពល និងបានធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធដទៃទៀត រិះរកដំណោះស្រាយ និងវិធានការទាំងឡាយ ដែលអាចធ្វើទៅ បានដើម្បីបន្ថយផលប៉ះពាល់លើបរិស្ថានធម្មជាតិ និងសង្គមឱ្យបានជាអតិបរមា។ ក្នុងការធ្វើការសម្រេចចិត្ត អភិវឌ្ឍន៍គម្រោងណាមួយ គឺតែងតែឈរលើមូលដ្ឋាននៃការថ្លឹងថ្លែង និងប្រៀបធៀបយ៉ាងល្អិតល្អន់ និងត្រឹមត្រូវ រវាងផលប៉ះពាល់ និងផលប្រយោជន៍ លើមូលដ្ឋាននៃការសិក្សាវាយតម្លៃលម្អិតប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ ដែលបានគិតគូរដល់ផលប្រយោជន៍ជាតិ និងផលប្រយោជន៍រួមរបស់ប្រទេស។

គោលដៅសំខាន់នៃការអភិវឌ្ឍវិស័យថាមពលគឺដើម្បីធ្វើឱ្យមានផលប្រយោជន៍ដល់ប្រទេសជាតិ និង សម្រាប់មនុស្សគ្រប់គ្នាដោយរក្សាឱ្យមានតុល្យភាពរវាងផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន តាមរយៈ ការអភិវឌ្ឍដើម្បីបំពេញនូវសេចក្តីត្រូវការថាមពលឱ្យបានគ្រប់គ្រាន់ អាចទុកចិត្តបាន និងមានថ្លៃសមរម្យ និង ការជំរុញនិងលើកទឹកចិត្តឱ្យប្រើប្រាស់និងផ្ទេរបច្ចេកវិទ្យាមេត្រីភាពដល់បរិស្ថាន ការពង្រឹងសកម្មភាពដែល មានស្រាប់ដូចជាការអភិវឌ្ឍបច្ចេកវិទ្យាស្អាត ការគ្រប់គ្រងសារជាតុគីមី ប្រសិទ្ធភាពថាមពល និងការអភិវឌ្ឍ ថាមពលកកើតឡើងវិញរួមមានថាមពលពន្លឺព្រះអាទិត្យ ខ្យល់ វារីអគ្គិសនី ជីវម៉ាស ជីវឧស្ម័ន និងថាមពលថ្មី ផ្សេងៗទៀតដើម្បីឈានឆ្ពោះទៅរកការអភិវឌ្ឍបៃតង និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុង បរិយាកាស។

ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលទទួលខុសត្រូវដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យថាមពល និងក្នុងនាមជាសមាជិកក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងរ៉ែ និងថាមពលបានរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពលសម្រាប់ឆ្នាំ ២០២១-២០២៣ ដើម្បីអភិវឌ្ឍ និងតម្រង់ទិសជាយុទ្ធសាស្ត្រដ៏សំខាន់មួយសម្រាប់ក្រសួង ទីភ្នាក់ងារនានា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដទៃទៀតសម្រាប់កិច្ចសហប្រតិបត្តិការ និងការអនុវត្តការងារឆ្លើយតបការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល ដែលការអនុវត្តសកម្មភាពនានាក្នុងផែនការនេះបានបន្សុីគ្នា រវាងគោលដៅផ្ទាល់របស់វិស័យថាមពលជាមួយគ្នានឹងគោលដៅឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើម្បីឈានឆ្ពោះទៅរួមចំណែកក្នុងការឆ្លើយតបជាសកលទៅនឹងការប្រែប្រួលអាកាសធាតុ។ ឯកសារនេះត្រូវបានរៀបចំឡើងដោយមានការគាំទ្រ និងការចូលរួមពីអគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា គ្រប់នាយកដ្ឋានទាំងអស់នៃអគ្គនាយកដ្ឋានថាមពល អ្នកជំនាញប្រែប្រួលអាកាសធាតុ និងតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធានាឱ្យបាននូវភាពគ្រប់ជ្រុងជ្រោយ និងភាពអាចអនុវត្តបាន។ ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពលឆ្នាំ២០២១-២០២៣ គឺជាឯកសារណែនាំយុទ្ធសាស្ត្រដ៏សំខាន់មួយសម្រាប់ក្រសួង ទីភ្នាក់ងារនានា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀតសម្រាប់កិច្ចសហប្រតិបត្តិការ និងការអនុវត្តការងារដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល។ ការអនុវត្តសកម្មភាពនានាក្នុងផែនការនេះនឹងនាំទៅរកការកែលម្អវិស័យថាមពលឆ្ពោះទៅរកការអភិវឌ្ឍបៃតង និងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុដោយរក្សាបាននូវគោលដៅគន្លឹះរបស់វិស័យថាមពលគឺ ការផ្គត់ផ្គង់ថាមពលឱ្យបានគ្រប់គ្រាន់ អាចទុកចិត្តបាន និងមានថ្លៃសមរម្យសម្រាប់សេចក្តីត្រូវការថាមពលរបស់សេដ្ឋកិច្ច និងសង្គមរបស់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមក្រសួងរ៉ែ និងថាមពល ខ្ញុំសូមជំរុញឱ្យគ្រប់នាយកដ្ឋានរបស់ក្រសួងរ៉ែ និងថាមពល ស្ថាប័នក្នុងវិស័យថាមពល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវបន្ត និងពង្រឹងកិច្ចសហការជាមួយក្រសួងរ៉ែ និងថាមពល ដើម្បីអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនេះឱ្យបានជោគជ័យ៕

ថ្ងៃ ចន្ទ ១៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**



**ស៊ុយ សែម**

# មាតិកា

**អារម្ភកថា** ............ i

**មាតិកា** ............ iii

**ពាក្យបំព្រួញ និងអក្សរកាត់** ............ iv

**១. សាវតារ** ............ ១

ក. គោលនយោបាយ ............ ៣

ខ. បរិបទនៃការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល ............ ៩

គ. ការងារអាទិភាពរបស់វិស័យថាមពល ............ ១៥

**២. យុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** ............ ១៦

**៣. ផែនការសកម្មភាព** ............ ១៩

ក. សង្ខេបវិសាលភាពនៃផែនការ ............ ១៩

ខ. តារាងផែនការសកម្មភាព ............ ១៩

គ. លទ្ធផលរំពឹងទទួលបានពីការអនុវត្តផែនការសកម្មភាពនេះ ............ ២៤

**៤. ការគ្រប់គ្រង និងយន្តការហិរញ្ញវត្ថុ** ............ ២៥

ក. ការវិភាគលើការគ្រប់គ្រង និងយន្តការហិរញ្ញវត្ថុដែលមានស្រាប់ ............ ២៥

ខ. ការវិភាគប្រភព និងបរិមាណហិរញ្ញវត្ថុសម្រាប់សកម្មភាពប្រែប្រួលអាកាសធាតុ ............ ២៥

**៥. ការពិនិត្យតាមដាន និងវាយតម្លៃ** ............ ២៨

**៦. ផ.ស.ប.អ.ថ. និងយេនឌ័រ** ............ ៣២

**៧. តម្រូវការផ្នែកច្បាប់** ............ ៣២

**៨. សេចក្តីសន្និដ្ឋាន** ............ ៣៣

**ឧបសម្ព័ន្ធ** ............ ៣៤

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AF | Adaptation Fund | មូលនិធិបន្សុាំ |
| AFD | Agence Française de Développement | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BUR | Biennial Update Report | របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង |
| CCAP | Climate Change Action Plan | ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ផ.ស.ប.អ) |
| CCCA | Cambodia Climate Change Alliance | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCSP | Cambodia Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា( ផ.យ.ប.ក. ) |
| CCD | Climate Change Department | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| CCTT | Climate Change Technical Team | ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ |
| CDM | Clean Development Mechanism | យន្តការអភិវឌ្ឍន៍ស្អាត |
| CEDAW | Convention on the Elimination of All Forms of Discrimination Against Women | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី |
| CIF | Climate Investment Funds | មូលនិធិវិនិយោគអាកាសធាតុ |
| CPEIR | Climate Public Expenditure and Institutional Review | ការពិនិត្យការចំណាយសាធារណៈ និងស្ថាប័ន លើការងារអាកាសធាតុ |
| DANIDA | Danish International Development Agency | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក |
| EU | European Union | សហភាពអឺរ៉ុប |
| FCPF | Forest Carbon Partnership Facility | មូលនិធិភាពជាដៃគូកាបូនព្រៃឈើ |
| GCF | Green Climate Fund | មូលនិធិអាកាសធាតុបៃតង |
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| GEF | Global Environment Facility | មូលនិធិបរិស្ថានពិភពលោក |
| GHG | Greenhouse Gas | ឧស្ម័នផ្ទះកញ្ចក់ |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit | សង្គមអាឡឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ |
| INC | Initial National Communication | សេចក្តីជូនដំណឹងជាតិលើកទី១ |
| JICA | Japan International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KOIKA | Korea International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ - កយកា |

| | | |
|---|---|---|
| LCDF | Least Developed Countries Fund | មូលនិធិសម្រាប់ប្រទេសអភិវឌ្ឍន៍តិចបំផុត |
| LDC | Least Developed Country | ប្រទេសអភិវឌ្ឍន៍តិចតួច |
| M&E | Monitoring and Evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MME | Ministry of Mines and Energy | ក្រសួងរ៉ែ និងថាមពល (ក.រ.ថ.) |
| MOE | Ministry of Environment | ក្រសួងបរិស្ថាន(ក.ប.ស.) |
| NA | Not Available | មិនមាន (ម.ម.) |
| NCCC | National Climate Change Committee | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) |
| NDC | Nationally Determined Contribution | ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (រ.ច.ជ.អ.ក.ស.ប.ប.អ.) |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) |
| REDD+ | Reducing Emissions from Deforestation and Forest Degradation | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RS | Rectangular Strategy | យុទ្ធសាស្ត្រចតុកោណ |
| SEforALL | Sustainable Energy for All | ថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា |
| Sectoral CCSP | Sectoral Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (ផ.យ.ប.អ.តាមវិស័យ) |
| SNC | Second National Communication | សេចក្តីជូនដំណឹងជាតិលើកទី២ |
| SWEDEN (Sida) | Swedish International Development Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNIDO | United Nations Industrial Development Organization | អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម |
| UNFCCC | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |

# ១. សារតារ

ដើម្បីរួមចំណែកក្នុងការឆ្លើយតបជាសកលទៅនឹងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ ១៩៩៥ និងបានចូលជាសមាជិកពិធីសារក្យូតូ ក្នុង ខែកក្កដា ឆ្នាំ២០០២។ នៅឆ្នាំ២០១៦ ព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាអនុម័ត និងបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសរួមគ្នាជាមួយប្រទេសចំនួន ១៩៤ ផ្សេងទៀត ដើម្បីចូលរួមដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុតាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងយន្តការហិរញ្ញវត្ថុគាំទ្រដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលបានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០២០។ កិច្ចព្រមព្រៀងនេះ មានគោលបំណងឆ្លើយតបទៅនឹងការគំរាមកំហែងពីការប្រែប្រួលអាកាសធាតុជាសកល ដោយរក្សាសីតុណ្ហភាពពិភពលោកមិនឱ្យកើនឡើងលើស ២អង្សាសេ នៅសតវត្សរ៍នេះ ដោយធៀបនឹងសីតុណ្ហភាពពិភពលោកមុនបដិវត្តន៍ឧស្សាហកម្ម និងខិតខំប្រឹងប្រែងដើម្បីកំណត់ការកើនឡើងសីតុណ្ហភាពសកលឱ្យនៅត្រឹមតែ ១,៥ អង្សាសេតែប៉ុណ្ណោះ។[1] នៅឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិប្រែប្រួលអាកាសធាតុដើម្បីធ្វើការសម្របសម្រួលដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុថ្នាក់ជាតិ នៅឆ្នាំ២០១៥ គណៈកម្មាធិការនេះបានកែសម្រួលទៅជាក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(ក.ជ.អ.ច.)។ ក.ជ.អ.ច. រួមមានក្រសួងនិងស្ថានប័នចំនួន ៣៦ និងអភិបាលរាជធានី/ខេត្តចំនួន២៥ ជាសមាជិក។ **សម្តេចតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាជាប្រធានកិត្តិយស និងមានរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន។ ក.ជ.អ.ច.មានតួនាទីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុតាមរយៈការវាយតម្លៃបច្ចេកវិទ្យាថ្មីៗ ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំទៅនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹង[2,3]។ ក.ជ.អ.ច. បាននិងកំពុងសម្របសម្រួលអនុវត្តកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី១ ទី២ និងទី៣ ដែលជាកម្មវិធីដ៏សំខាន់មួយត្រូវបានរៀបចំឡើងឱ្យស្របទៅនឹងក្របខ័ណ្ឌស្ថាប័នជាតិ សម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាដោយរក្សាឱ្យមានសង្គតិភាពជាមួយនឹងគោលដៅ និងផែនការវិស័យផ្សេងៗទៀតក្នុងផ្នែកសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។ ការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុត្រូវបានរាជរដ្ឋាភិបាលកម្ពុជាបញ្ចូលក្នុងគោលនយោបាយសំខាន់ៗរបស់ជាតិជាច្រើនដូចជា យុទ្ធសាស្ត្រចតុកោណ[4] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ[5] និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ (ផ.យ.ប.អ.ក.)[6]។ ផ.យ.ប.អ.ក. ជាឯកសារមគ្គុទ្ទេសក៍គោលសម្រាប់ ស្ថាប័នជាតិ អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងការបង្កើតវិធានការ និងសកម្មភាពជាក់ស្តែងសមស្របដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមរយៈ

[1] https://unfccc.int/process-and-meetings/the-paris-agreement/the-paris-agreement

[2] សេចក្តីជូនដំណឹងជាតិទី២

[3] ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣

[4] http://cnv.org.kh/wp-content/uploads/2012/10/Rectangular-Strategy-Phase-IV-of-the-Royal-Government-of-Cambodia-of-the-Sixth-Legislature-of-the-National-Assembly-2018-2023.pdf

[5] http://www.mop.gov.kh/DocumentEN/NSDP%202019-2023%20in%20English.pdf

[6] https://ncsd.moe.gov.kh/resources/document/cambodia-climate-change-strategic-plan-2014-2023-cccsp-2014-2023kh

ការអនុវត្តយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជា។ គោលដៅមួយក្នុងចំណោមគោលដៅទាំង៣ របស់ ផ.យ.ប.អ.ក. គឺការផ្លាស់ប្តូរឆ្ពោះទៅរកមាគ៌ាអភិវឌ្ឍន៍បៃតងតាមរយៈលើកកម្ពស់ការអភិវឌ្ឍដែលបញ្ចេញកាបូនតិច និងការប្រើប្រាស់បច្ចេកវិទ្យាសមស្រប ដែលរក្សាបាននូវគោលដៅនិងផែនការវិស័យផ្សេងៗទៀតក្នុងផ្នែកសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

ដើម្បីចូលរួមក្នុងការអនុវត្ត ផ.យ.ប.អ.ក. កាលពីឆ្នាំ២០១៣ អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពលសម្រាប់ឆ្នាំ ២០១៤-២០១៨ បន្ទាប់មកនៅឆ្នាំ២០១៥ ក្រសួងរ៉ែ និងថាមពលបានរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យរ៉ែ និងថាមពលសម្រាប់ឆ្នាំ ២០១៦-២០១៨។ កន្លងមកការរៀបចំ ផ.ស.ប.អ. មិនសូវបានបន្សុីគ្នាឱ្យបានពិតប្រាកដជាមួយនឹងគោលដៅ និងផែនការនៃការអភិវឌ្ឍវិស័យថាមពលទេ ដែលធ្វើឱ្យការអនុវត្តមិនសូវបានគ្រប់ជ្រុងជ្រោយ ហេតុដូច្នេះហើយ ដើម្បីបន្តអនុវត្ត ផ.យ.ប.អ.ក និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពល ដោយបន្សុីគ្នាជាមួយនឹងទិសដៅនិងផែនការអភិវឌ្ឍវិស័យថាមពល ក្រសួងរ៉ែនិងថាមពល រៀបចំផែនការសកម្មភាពប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពលសម្រាប់ឆ្នាំ ២០២១ - ២០២៣ ( ផ.ស.ប.អ.ថ. ) នេះឡើង ដោយកំណត់គោលបំណងសំខាន់ក្នុងការរៀបចំផែនការនេះ ដូចខាងក្រោមៈ

- គាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យថាមពលតាមរយៈការរៀបចំផែនការមេជាថ្មី ដែលក្នុងនោះគ្រោងបង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញឱ្យបានជាអតិបរមា បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល ដោយរក្សាបាននូវការផ្គត់ផ្គង់ប្រភពថាមពលឱ្យបានគ្រប់គ្រាន់ អាចទុកចិត្តបាន និងមានថ្លៃសមរម្យ ប្រកួតប្រជែងជាមួយប្រទេសជិតខាងទៅតាមផែនការមេដែលបានសិក្សានិងអនុម័ត។
- បន្សាំវិស័យថាមពលទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលអាចកើតមានឡើង។
- បង្កើនភាពធន់នៃវិស័យថាមពលទៅនឹងការប្រែប្រួលអាកាសធាតុ។
- លើកកម្ពស់ការយល់ដឹង និងសមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់វិស័យថាមពល។

ក្រសួងរ៉ែ និងថាមពល ( ក.រ.ថ ) បានរៀបចំ ផ.ស.ប.អ.ថ. សម្រាប់ឆ្នាំ ២០២១-២០២៣ ស្របទៅតាមទម្រង់ដែលណែនាំដោយទីស្តីការគណៈរដ្ឋមន្ត្រី និងស្របទៅតាមការពិភាក្សាជាមួយ ក.ជ.អ.ច.។ ដំណើរការនៃការរៀបចំ ផ.ស.ប.អ.ថ. នេះមានការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយអគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា គ្រប់នាយកដ្ឋាននៃអគ្គនាយកដ្ឋានថាមពល និងភាគីពាក់ព័ន្ធទាំងអស់ដើម្បីធានាឱ្យបាននូវភាពស៊ីគ្នារវាង ផ.ស.ប.អ.ថ. ជាមួយនឹងផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការសកម្មភាពនានាក្នុងវិស័យថាមពល ក៏ដូចជាគោលដៅផ្សេងៗទៀតនៃការអភិវឌ្ឍវិស័យថាមពល។

ផ.ស.ប.អ.ថ.នេះកំណត់សកម្មភាពជាក់ស្តែង និងធនធានចាំបាច់សម្រាប់ក្រសួងរ៉ែ និងថាមពល ធ្វើប្រតិបត្តិការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ឆ្នាំ ២០២១-២០២៣ ស្របទៅតាមផែនការមេអភិវឌ្ឍន៍វិស័យថាមពលដែលក្រសួងបានកំណត់។ ផ.ស.ប.អ.ថ. ក៏ផ្តល់ការតម្រង់ទិសដែលមានសារៈសំខាន់សម្រាប់ក្រសួងរ៉ែ និងថាមពល យកមករៀបចំផែនការអភិវឌ្ឍន៍វិស័យថាមពល ដូចជាការរៀបចំធ្វើបច្ចុប្បន្នភាពផែនការមេអភិវឌ្ឍន៍វិស័យថាមពល ការរៀបចំគោលនយោបាយប្រសិទ្ធភាពថាមពល ការសិក្សាហេដ្ឋារចនា

សម្ព័ន្ធថាមពលដើម្បីធានាបាននូវភាពធន់ជាមួយនឹងការប្រែប្រួលអាកាសធាតុបច្ចុប្បន្ន និងអនាគត ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការកសាងសមត្ថភាពដើម្បីឆ្លើយតបនឹងការប្តេជ្ញាចិត្តរបស់ប្រទេសលើការប្រើប្រាស់ថាមពលប្រកបដោយចីរភាព និងប្រសិទ្ធភាពសម្រាប់ទាំងអស់គ្នា។[7]

## ក. គោលនយោបាយ

ព្រះរាជាណាចក្រកម្ពុជាមានក្របខ័ណ្ឌគោលនយោបាយជាតិ និងបទប្បញ្ញត្តិមួយចំនួនចែងអំពីការងារពាក់ព័ន្ធការចូលរួមឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលអាចជះឥទ្ធិពលដោយផ្ទាល់ឬដោយប្រយោលដល់ការអភិវឌ្ឍវិស័យថាមពល ដូចជាការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាបញ្ចេញកាបូនតិច និងការប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់ការផលិតអគ្គិសនី។ គោលនយោបាយទាំងនេះ មានចែងនៅក្នុងឯកសារដូចខាងក្រោម៖

- គោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- គោលនយោបាយ និងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ
- គោលនយោបាយ និងផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍវិស័យថាមពល។

### ក-១-គោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

#### *១-១-យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤*

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដំណាក់កាលទី៤ ទទួលស្គាល់ភាពចាំបាច់នៃ "ការអភិវឌ្ឍប្រកបដោយបរិយាបន្នភាពនិងចីរភាព" និង "ការធ្វើពិពិធកម្មសេដ្ឋកិច្ច" ជាវិស័យអាទិភាពពីរដើម្បីឆ្ពោះទៅរកចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ នៅក្នុងជ្រុងនៃការអភិវឌ្ឍប្រកបដោយបរិយាបន្ននិងចីរភាព ការធានានិរន្តរភាពបរិស្ថាន និងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គឺជាការផ្តោតសំខាន់នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញការធ្វើឱ្យប្រសើរឡើងនូវការប្រកួតប្រជែង ការលើកកម្ពស់នវានុវត្តន៍ឧស្សាហកម្ម ការបណ្តុះបណ្តាលបច្ចេកទេស ការស្រាវជ្រាវនិងការអភិវឌ្ឍ សហគ្រិនភាព ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការធានានិរន្តរភាពបរិស្ថានជាមួយនឹងការវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស ដើម្បីបង្កើតការងារជាផ្នែកសំខាន់នៃដំណើរអភិវឌ្ឍន៍របស់ប្រទេស ។ យុទ្ធសាស្ត្រចតុកោណក៏ផ្តោតលើការបញ្ចុះថ្លៃថាមពលបន្ថែមទៀត ដើម្បីរួមចំណែកដល់ភាពប្រកួតប្រជែងក្នុងការធ្វើធុរកិច្ច ឧស្សាហកម្ម និងសន្តិសុខថាមពលរបស់ប្រទេសកម្ពុជា។ ចំនុចសំខាន់ៗរបស់យុទ្ធសាស្ត្រចតុកោណទាក់ទងនឹងវិស័យថាមពលរួមមាន៖

- ពង្រឹងធនធានមនុស្ស/សមត្ថភាពស្ថាប័នសម្រាប់ការគ្រប់គ្រងវិស័យថាមពល
- ការចូលរួមពីវិស័យឯកជន
- និរន្តរភាពបរិស្ថាន និងការអភិវឌ្ឍបៃតង
- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យថាមពលសំដៅធានាសន្តិសុខថាមពល ស្ថិរភាព និងថ្លៃសមរម្យដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍

[7] ផែនការត្រៀមខ្លួនថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់នៅកម្ពុជា

- បញ្ចុះថ្លៃអគ្គិសនីបន្ថែមទៀត ពង្រីកការផ្គត់ផ្គង់ និងបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី តាមរយៈការសាងសង់អនុស្ថានីយអគ្គិសនីបន្ថែមក្បែរប៉ូលសេដ្ឋកិច្ច និងតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់
- ការធ្វើពិពិធកម្មប្រភពថាមពល
- បន្តលើកទឹកចិត្ត និងបង្កើនការវិនិយោគលើថាមពលកកើតឡើងវិញ ជាពិសេសថាមពលពន្លឺព្រះអាទិត្យ ជាមួយគ្នានឹងការកាត់បន្ថយការផលិតថាមពលពីឥន្ធនៈហ្វូស៊ីល ដើម្បីធានាបានសន្តិសុខថាមពលរយៈពេលវែង
- អគ្គិសនីភាវូបនីយកម្មជនបទ។

## *១-២-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩- ២០២៣*

ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៦ នៃរដ្ឋសភា ក.រ.ថ. បានកំណត់ផែនការដើម្បីបន្តសកម្មភាពអាទិភាពរបស់ខ្លួនក្នុងការគ្រប់គ្រង និងជំរុញការអភិវឌ្ឍវិស័យថាមពល ដើម្បីសម្រេចបាននូវការផ្គត់ផ្គង់អគ្គិសនីមួយគ្រប់គ្រាន់ មានស្ថិរភាព គុណភាព និងថ្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ ដោយយកចិត្តទុកដាក់បង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញ បច្ចេកវិទ្យាបញ្ចេញកាបូនតិច និងជំរុញការអភិវឌ្ឍប្រសិទ្ធភាពថាមពលនិងការសន្សំសំចៃថាមពល ដែលបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ សកម្មភាពទាំងនេះបង្ហាញពីទំនាក់ទំនងជាក់ស្តែងរវាង វិស័យថាមពល និងការអភិវឌ្ឍដោយចីរភាព[៨]។ ចំនុចសំខាន់ៗរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទាក់ទងនឹងវិស័យថាមពលរួមមាន៖

- ជំរុញការអភិវឌ្ឍដោយប្រើប្រាស់បច្ចេកវិទ្យាបញ្ចេញកាបូនតិចជាមូលដ្ឋានសម្រាប់ឈានឆ្ពោះទៅកំណើនបៃតង
- ការអភិវឌ្ឍវិស័យថាមពល និងប្រព័ន្ធបណ្តាញអគ្គិសនី
- ពង្រីកសមត្ថភាពផ្គត់ផ្គង់អគ្គិសនី និងពិពិធកម្មប្រភពថាមពលដើម្បីកាត់បន្ថយការពឹងផ្អែកលើធ្យូងថ្ម និងប្រេងឥន្ធនៈសម្រាប់ការផលិតអគ្គិសនី
- ការអភិវឌ្ឍវារីអគ្គិសនី និងការពង្រីកបណ្តាញអគ្គិសនី
- បង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញ
- និរន្តរភាពបរិស្ថាន និងការអភិវឌ្ឍបៃតង
- លើកទឹកចិត្តដល់វិស័យឯកជនឱ្យចូលរួមក្នុងការវិនិយោគលើសេវាកម្មផ្គត់ផ្គង់ថាមពលតាមទីជនបទ ប្រកបដោយនិរន្តរភាពជាពិសេសការប្រើប្រាស់បច្ចេកវិទ្យាថ្មី និងថាមពលកកើតឡើងវិញ
- ជំរុញការអភិវឌ្ឍវិស័យថាមពល និងអគ្គិសនីតាមរយៈការបង្កើនការតភ្ជាប់ដល់ប្រជាជនប្រកបដោយគុណភាព ស្ថិរភាព និងថ្លៃសមរម្យ។

[8] http://mop.gov.kh/DocumentKH/NSDP%202019-2023%20in%20KH.pdf

## ក-២-គោលនយោបាយ និងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ

### *២-១-ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ ២០១៤-២០២៣*

ផ.យ.ប.អ.ក. មានគោលដៅយុទ្ធសាស្ត្រដូចខាងក្រោម៖

- លើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងផលប៉ះពាល់សុខភាព៖
    - ថាមពលកកើតឡើងវិញ
    - ប្រសិទ្ធភាពថាមពល
    - ការផ្ទេរបច្ចេកវិទ្យាសមស្រប
    - ការគ្រប់គ្រងសំណល់រឹងរាវ/តាមវិធានការចម្រុះនៅរាជធានី ទីក្រុងទីប្រជុំជន និងការគ្រប់គ្រងសំណល់សត្វ។
- សិក្សាវិភាគទៅលើជម្រើសដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាបនៅតាមវិស័យ និងប្រភពបញ្ចេញឧស្ម័ន (កសិកម្ម ថាមពល ការដឹកជញ្ជូន ឧស្សាហកម្ម ការគ្រប់គ្រងការប្រើប្រាស់ដីនិងព្រៃឈើ និងការគ្រប់គ្រងសំណល់)
- រៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងផែនការសកម្មភាពអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច ដោយអនុលោមតាមអាទិភាពអភិវឌ្ឍន៍នានារបស់ជាតិ
- ជំរុញការផ្ទេរបច្ចេកវិទ្យាសមស្រប ដើម្បីលើកកម្ពស់ការអភិវឌ្ឍដែលបញ្ចេញកាបូនតិច និងសម្រួលឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាសមស្របតាមរយៈ៖
    - គោលការណ៍ណែនាំជំនួយបច្ចេកទេស និងការបង្កើតភាពជាដៃគូ
    - ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធ
    - យន្តការទីផ្សារកាបូន
    - ការកៀរគរភាពជាដៃគូសាធារណៈ និងឯកជន
- បង្កើតប្រព័ន្ធចុះបញ្ជីគម្រោង និងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- បង្កើតប្រព័ន្ធសន្និធិឧស្ម័នផ្ទះកញ្ចក់ជាតិប្រកបដោយគុណភាព។

### *២-២-សេចក្តីជូនដំណឹងជាតិ (National Communication)*

អនុលោមតាម ផ.យ.ប.អ.ក. រាជរដ្ឋាភិបាលកម្ពុជាបានដាក់ជូនសេចក្តីជូនដំណឹងជាតិជាតិទី១ (INC) នៅ ខែសីហា ឆ្នាំ២០០២ និងសេចក្តីជូនដំណឹងជាតិទី២ (SNC) នៅឆ្នាំ២០១៦ ទៅកាន់លេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ[9,10]។ សេចក្តីជូនដំណឹងជាតិជាតិទី១ និងទី២ បានបញ្ជាក់ថាទោះបីប្រទេសកម្ពុជាមិនមែនជាប្រទេសដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ខ្ពស់ក៏ដោយ ក៏រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្រោមលក្ខខណ្ឌមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីប្រទេសអភិវឌ្ឍន៍។

---

[9] https://unfccc.int/sites/default/files/resource/Cambodia%27s%20INC_0.pdf
[10] https://unfccc.int/sites/default/files/resource/khmnc2.pdf

## *២-៣-ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (Nationally Determined Contribution)*

បន្ទាប់ពីសេចក្តីជូនដំណឹងជាតិលើកទី១ និងទី២ ព្រះរាជាណាចក្រកម្ពុជាបានដាក់ជូនការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកដំបូង ទៅកាន់លេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ២០១៥។ ការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនេះកំពុងត្រូវបានធ្វើបច្ចុប្បន្នភាព ហើយនឹងក្លាយជាការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុទី២ ដែលនឹងត្រូវអនុវត្តពី ឆ្នាំ២០២០ ដល់ ឆ្នាំ២០៣០។ ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនេះ បានកំណត់ការងារកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យថាមពលដែលក្រសួងរ៉ែ និងថាមពលត្រូវធ្វើចំនួន ៥ ដូចខាងក្រោម៖

- បង្កើនការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញឱ្យបានជាអតិបរមា និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពលនៅក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីថ្នាក់ជាតិ ដោយរក្សាបាននូវការផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់គ្រាន់ អាចទុកចិត្តបាន និងមានថ្លៃសមរម្យ ប្រកួតប្រជែងជាមួយប្រទេសជិតខាង
- ភ្ជាប់សេវាករអគ្គិសនីជនបទទៅនឹងបណ្តាញផ្គត់ផ្គង់អគ្គិសនីថ្នាក់ជាតិ
- ភ្ជាប់អ្នកប្រើប្រាស់ថាមពលដែលប្រើប្រភពថាមពលដែលមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅនឹងបណ្តាញផ្គត់ផ្គង់អគ្គិសនីថ្នាក់ជាតិ
- រៀបចំការផ្គត់ផ្គង់ថាមពលដល់តំបន់ដែលនៅក្រៅប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីថ្នាក់ជាតិ ដោយប្រើបច្ចេកវិទ្យាថាមពលស្អាត
- លើកកម្ពស់ប្រសិទ្ធភាពថាមពល។

ដោយសារក្នុងការរៀបចំការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុកន្លងមក ធ្វើការកំណត់គម្រោងអភិវឌ្ឍន៍គាំទ្រដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការកំណត់ចំនួនឧស្ម័នផ្ទះកញ្ចក់ដែលត្រូវបញ្ចេញក្នុងសេណារីយូទម្លាប់ធម្មតារបស់វិស័យថាមពលរហូតដល់ឆ្នាំ២០៣០ និងការកំណត់ចំនួនឧស្ម័នផ្ទះកញ្ចក់ដែលវិស័យថាមពលកម្ពុជាត្រូវកាត់បន្ថយធៀបទៅនឹងចំនួនដែលបញ្ចេញក្នុងសេណារីយូទម្លាប់ធម្មតាធ្វើឡើងដោយសន្មត និងមិនបានបន្សុីគ្នាឱ្យបានច្បាស់លាស់ជាមួយផែនការមេអភិវឌ្ឍន៍វិស័យថាមពលដែលរាជរដ្ឋាភិបាលបានអនុម័ត ធ្វើឱ្យការអនុវត្តរបស់វិស័យថាមពលមិនមានភាពច្បាស់លាស់និងមានការលំបាក។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងរ៉ែ និងថាមពល បានបញ្ចូលគោលដៅនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការពិភាក្សា និងការសិក្សារៀបចំផែនការមេអភិវឌ្ឍន៍វិស័យថាមពលឡើងវិញ ដើម្បីឱ្យការកំណត់គម្រោងអភិវឌ្ឍគាំទ្រដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការកំណត់ចំនួនឧស្ម័នផ្ទះកញ្ចក់ដែលត្រូវបញ្ចេញក្នុងសេណារីយូទម្លាប់ធម្មតារបស់វិស័យថាមពលរហូតដល់ឆ្នាំ ២០៣០ និងការកំណត់ចំនួនឧស្ម័នផ្ទះកញ្ចក់ដែលវិស័យថាមពលកម្ពុជាត្រូវកាត់បន្ថយ និងចំនួនកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល មានសង្គតិភាពជាមួយផែនការមេអភិវឌ្ឍន៍វិស័យថាមពល

ដែលបានរៀបចំ ជានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុដែលបានគ្រោង។

### *២-៣-របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង*

នៅឆ្នាំ២០២០ របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង (BUR)[11] លើកទី១ ត្រូវបានដាក់ជូនលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលជាឯកសារយោងសម្រាប់រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះរួមបញ្ចូលទាំងទិន្នន័យ និងព័ត៌មានពាក់ព័ន្ធ ទាក់ទងនឹងប្រភពសំខាន់ៗនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ រួមជាមួយនឹងវិធានការកាត់បន្ថយចាំបាច់ដែលត្រូវបានអនុវត្ត ឬបានគ្រោងរួចហើយ ។

## **ក-៣-គោលនយោបាយនិងផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍវិស័យថាមពល**

### ***៣-១-គោលនយោបាយនិងផែនការយុទ្ធសាស្ត្រអគ្គិសនីការូបនីយកម្មជនបទ***

ក្នុងឆ្នាំ២០១១ គោលនយោបាយអគ្គិសនីការូបនីយកម្មជនបទត្រូវបានពិចារណាក្នុងរបៀបវារៈរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យថាមពល ដើម្បីធ្វើយ៉ាងណាឱ្យការផ្គត់ផ្គង់ថាមពលអគ្គិសនីមាន ស្ថិរភាព ថ្លៃសមរម្យ និងគ្រប់គ្រាន់ សម្រាប់អ្នកប្រើប្រាស់ទាំងអស់គ្នា។ ម្យ៉ាងវិញទៀតគោលនយោបាយជាតិនេះក៏លើកកម្ពស់ឯកជនភាវូបនីយកម្មក្នុងវិស័យអគ្គិសនី និងការលើកទឹកចិត្តការប្រកួតប្រជែងក្នុងចំណោមក្រុមហ៊ុនឯកជននៅក្នុងវិស័យថាមពលផងដែរ[12]។ គោលនយោបាយនេះ បានដាក់ចេញគោលដៅជាយុទ្ធសាស្ត្រចំនួន២ ក្នុងការអភិវឌ្ឍវិស័យថាមពលនៅកម្ពុជា រួមមានៈ ១) នៅឆ្នាំ២០២០ ភូមិទាំងអស់នៅកម្ពុជាទទួលបានការផ្គត់ផ្គង់អគ្គិសនីណាមួយ ២) នៅឆ្នាំ២០៣០ យ៉ាងហោចណាស់ ៧០% នៃខ្នងផ្ទះទាំងអស់នៅកម្ពុជា ត្រូវមានអគ្គិសនីដែលមានគុណភាពបណ្តាញជាតិសម្រាប់ប្រើប្រាស់។

ឈរលើមូលដ្ឋាននៃការលើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមវិនិយោគ ធ្វើអាជីវកម្ម និងផ្តល់សេវាក្នុងវិស័យថាមពល រាជរដ្ឋាភិបាលបានសម្រេចគោលដៅនៃការផ្គត់ផ្គង់អគ្គិសនីឱ្យខ្នងផ្ទះចំនួន៧០% មុនផែនការដែលបានគ្រោងទុកជាង១០ឆ្នាំ ពោលគឺត្រឹមចុងឆ្នាំ២០១៩ ខ្នងផ្ទះចំនួន ៧៤,៧៨% នៃចំនួនខ្នងផ្ទះទាំងអស់បានទទួលការតភ្ជាប់ទៅនឹងបណ្តាញអគ្គិសនីជាតិរួចហើយ។ នៅចុងឆ្នាំ២០២០ ប្រទេសកម្ពុជាមានអ្នកកាន់អាជ្ញាប័ណ្ណចែកចាយអគ្គិសនីនៅតាមតំបន់នានាចំនួន៤៦៣ ដែលទទួលបានសិទ្ធិក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងប្រទេស។ តំបន់ដែនអាជ្ញាប័ណ្ណផ្គត់ផ្គង់អគ្គិសនីនៃអ្នកកាន់អាជ្ញាប័ណ្ណចែកចាយទាំងនេះបានគ្របដណ្តប់លើភូមិចំនួន ១៤.១៤៣ភូមិ ក្នុងចំណោមភូមិសរុបចំនួន ១៤.១៦៨ ឬប្រមាណ ៩៩,៨២% នៃចំនួនភូមិទាំងអស់ ក្នុងនោះមានភូមិចំនួន ២៥ ឋិតនៅក្រៅតំបន់ដែនអាជ្ញាប័ណ្ណ។ ក្នុងចំណោមភូមិទាំង ១៤.១៤៣ ភូមិ ដែលឋិតនៅក្នុងតំបន់ដែនអាជ្ញាប័ណ្ណ មានភូមិចំនួន ១៣.៧៩៨ ទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់របស់បណ្តាញអគ្គិសនីជាតិរួចហើយ ខណៈភូមិចំនួន ៣៧០ភូមិទៀត មិនទាន់បានភ្ជាប់អគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់របស់បណ្តាញជាតិនៅឡើយ។ ដូច្នេះនៅចុងឆ្នាំ២០២០ មានភូមិសរុបចំនួន ៣៧០ ត្រូវជា ២,៦១% នៃចំនួនភូមិសរុប នៅមិនទាន់បានភ្ជាប់អគ្គិសនីពីបណ្តាញជាតិប្រើប្រាស់នៅឡើយ។ យោងតាមរបាយការណ៍របស់អាជ្ញាធរ

[11] https://unfccc.int/sites/default/files/resource/FBUR_Cambodia.pdf

[12] EC-ASEAN energy facility. ការសិក្សាសមទ្ធិលទ្ធភាពនៃជម្រើសថាមពលកកើតឡើងវិញសម្រាប់ប្រព័ន្ធអគ្គិសនីនៅជនបទនៅកម្ពុជា; 2006.

អគ្គិសនីកម្ពុជា ក្នុងចំណោមភូមិទាំង ៣៧០ ដែលពិបាកទៅដល់មានភូមិចំនួន ២៥១ ជាតំបន់ដាច់ស្រយាល និងមានផ្ទះរស់នៅរាយប៉ាយ និងមានភូមិចំនួន ៣២ គ្មានផ្លូវទៅដល់ ភូមិចំនួន ៤៦ ស្ថិតនៅតំបន់កោះ ភូមិចំនួន ៣៤ ជាភូមិនៅតំបន់អណ្តែតទឹក និងភូមិចំនួន៧ ទៀតជា តំបន់លិចទឹកនៅរដូវវស្សា។

ក្នុងសន្និបាតប្រចាំឆ្នាំ២០១៩ ក.រ.ថ. បានស្នើនូវវិធានការសំខាន់ៗចំនួន៣សម្រាប់ការអភិវឌ្ឍវិស័យថាមពល ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ខ្លួនស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានកែសម្រួលគោលដៅនៃការផ្គត់ផ្គង់អគ្គិសនីដូចខាងក្រោម៖

- ការផ្គត់ផ្គង់អគ្គិសនីឱ្យភូមិ៖ សម្រេចឱ្យបានអត្រាផ្គត់ផ្គង់អគ្គិសនីឱ្យភូមិចំនួន ១០០% ដោយគិតរួមទាំងការផ្គត់ផ្គង់អគ្គិសនីតាមរយៈថាមពលពន្លឺព្រះអាទិត្យ និងអាគុយនៅឆ្នាំ២០២០។
- ការផ្គត់ផ្គង់អគ្គិសនីឱ្យតាមគ្រួសារ៖ សម្រេចឱ្យបាននូវអត្រាអគ្គិសនីភាវូបនីយកម្មពីបណ្តាញជាតិយ៉ាងហោចណាស់ ៩០% ត្រឹមឆ្នាំ ២០២៣។

តារាងទី ១៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យថាមពលក្នុងផ.យ.អ.ជ. ឆ្នាំ២០១៩-២០២៣

| គោលដៅ | វិធានការគោលនយោបាយ | ផែនការសកម្មភាព |
|---|---|---|
| ឈានទៅសម្រេចឱ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព ស្ថិរភាព គុណភាព និងថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទនៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា | ទី១.បន្តធ្វើការអភិវឌ្ឍបង្កើនសមត្ថភាពផ្គត់ផ្គង់ | ១.១. ធ្វើបច្ចុប្បន្នភាពផែនការមេអភិវឌ្ឍន៍វិស័យថាមពល<br>១.២. បន្តអភិវឌ្ឍសមត្ថភាពផលិត បញ្ជូន និងចែកចាយ ធ្វើយ៉ាងណាឱ្យកម្ពុជាមានប្រភពអគ្គិសនីគ្រប់គ្រាន់ ឱ្យការផ្គត់ផ្គង់ពីបណ្តាញជាតិគ្របដណ្តប់ទូទាំងប្រទេស និងឱ្យការចែកចាយគ្របដណ្តប់គ្រប់ភូមិ<br>១.៣.ជំរុញការភ្ជាប់បណ្តាញឱ្យទីតាំងត្រូវការប្រើប្រាស់ ដើម្បីសម្រេចគោលដៅឱ្យគ្រួសារជាង៩០%មានអគ្គិសនីប្រើប្រាស់នៅឆ្នាំ២០២៣។ |
| | ទី២.កែលម្អការផ្តល់សេវាផ្គត់ផ្គង់អគ្គិសនី | ២.១.កែលម្អការផ្តល់សេវាផ្គត់ផ្គង់អគ្គិសនី ធ្វើយ៉ាងណាឱ្យការផ្គត់ផ្គង់មានគ្រប់គ្រាន់២៤ម៉ោងមានគុណភាព មានសុវត្ថិភាព មានស្ថិរភាព មានថ្លៃកាន់តែសមរម្យ និងមានភាពយុត្តិធម៌ក្នុងការវាស់វែង និងកត់ត្រាបរិមាណផ្គត់ផ្គង់<br>២.២. កែលម្អការផ្តល់សេវាតភ្ជាប់ចរន្តអគ្គិសនី ដើម្បីសម្រួលធុរកិច្ចនៅកម្ពុជាដែលក្នុងនោះមាន៖ នីតិវិធី ចំនួនថ្ងៃតភ្ជាប់ ថ្លៃចំណាយ ក្នុងការតភ្ជាប់ ស្ថិរភាពក្នុងការផ្គត់ផ្គង់ និងតម្លាភាពនៃការគិតថ្លៃអគ្គិសនី។ |
| | ទី៣. ពង្រឹងយន្តការគ្រប់គ្រង | ៣.១. ពង្រឹងយន្តការទំនាក់ទំនងរវាងស្ថាប័ន<br>៣.២. ទាក់ទាញការដាក់ទុនវិនិយោគឱ្យបានគ្រប់គ្រាន់ |

| | | |
|---|---|---|
| | | ៣.៣. ប្រើប្រាស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទក្នុងការជួយឧបត្ថម្ភធនបន្ថយគម្លាតថ្លៃ និងការផ្ទេរទុនទៅជួយអភិវឌ្ឍតំបន់ដាច់ស្រយាល<br>៣.៤. កាត់បន្ថយផលប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គមឱ្យបានជាអតិបរមា គ្រប់គ្រងសក្តានុពលថាមពល ចូលរួមប្រើប្រាស់ប្រភពថាមពលស្អាត ចូលរួមក្នុងកិច្ចសហប្រតិបត្តិការថាមពលក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ។ |

រាជរដ្ឋាភិបាលផ្តោតលើការផ្តល់សេវាកម្មថាមពល និងលើកកម្ពស់គុណភាពជីវិតសម្រាប់ប្រជាជននៅតាមទីជនបទ តាមរយៈគោលនយោបាយសំខាន់ពីរ គឺ ១)គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល និង ២) គោលនយោបាយអគ្គិសនីភាវូបនីយកម្មជនបទ។ ការអភិវឌ្ឍថាមពលកកើតឡើងវិញ គឺជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រជាច្រើន ដែលត្រូវបានអនុម័តដើម្បីសម្រេចគោលបំណងដែលបានលើកឡើង។ មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងការលើកទឹកចិត្តការវិនិយោគ គឺជាឧបករណ៍គោលនយោបាយសំខាន់ពីរដើម្បីគាំទ្រដល់ការអនុវត្តគម្រោងអភិវឌ្ឍន៍វិស័យថាមពល និងគោលនយោបាយអគ្គិសនីភាវូបនីយកម្មជនបទ។ ផ្អែកលើឯកសារមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ក្នុងចំណោមបច្ចេកវិទ្យាកកើតឡើងវិញមានតែប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យប្រើតាមផ្ទះ និងវារីអគ្គិសនីខ្នាតតូចប៉ុណ្ណោះ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គម្រោងឧបត្ថម្ភធន[13,14,15,16]។

## ខ. បរិបទនៃការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល

ការប្រែប្រួលអាកាសធាតុ គឺជាការគំរាមកំហែងមួយដែលមិនត្រឹមតែទៅលើវិស័យថាមពលប៉ុណ្ណោះទេ ប៉ុន្តែក៏ទៅលើការអភិវឌ្ឍប្រទេសកម្ពុជាទាំងមូលផងដែរ ពីព្រោះឥទ្ធិពលរបស់វាបានប៉ះពាល់ដល់គ្រប់វិស័យសំខាន់ៗរបស់ប្រទេស។ យោងតាមរបាយការណ៍ថ្មីៗស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ចនៅកម្ពុជា[17] ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាត្រឹមឆ្នាំ២០១៥ គឺមានចំនួន ៤,៦% ទាបជាងសេណារីយ៉ូគ្មានការប្រែប្រួលអាកាសធាតុក្នុងកំឡុងពេល ១៩៩៣-២០១៥ រួចទៅហើយ ហើយវានឹងបន្តបន្ថយផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាប្រមាណ ៩,៨% ត្រឹមឆ្នាំ២០៥០។ ការប្រែប្រួលអាកាសធាតុត្រូវបានគេយល់ថានឹងធ្វើឱ្យកើតមានជាញឹកញាប់នូវព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះ និងរលកកម្តៅផែនដីជាដើម។ ការកើនឡើងសីតុណ្ហភាពនេះ នឹងជះឥទ្ធិពលដល់ទិន្នផលដំណាំកសិកម្ម និងផលិតភាពការងារដោយផ្ទាល់ ខណៈទឹកជំនន់ និងការផ្លាស់ប្តូររបបទឹកភ្លៀងអាចធ្វើឱ្យខូចខាតដល់ដំណាំកសិកម្ម។ ផលប៉ះពាល់និងផលវិបាកទាំងនេះ នឹងតម្រូវឱ្យមានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាសកម្មភាពដើម្បីកាត់បន្ថយការឡើងកម្តៅផែនដី ដោយសារសកម្មភាពរបស់មនុស្ស និងធម្មជាតិ មានន័យ

[13] http://www.un.org/esa/agenda21/natlinfo/countr/cambodia/energy.pdf

[14] Ung L, Sovuthea H, Siek S, Chetra S. ស្ថានភាពនិងសក្តានុពលសម្រាប់ការអភិវឌ្ឍជីវឥន្ធនៈនិងថាមពលកកើតឡើងវិញនៅទីជនបទនៅកម្ពុជា. Asian Development Bank 2009.

[15] Hill RL, Curtin KM. ការចែកចាយអំពូលអិលអ៊ីឌីដើរដោយពន្លឺព្រះអាទិត្យនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍៖ ការវាយតម្លៃសក្តានុពលទីតាំងចែកចាយនៅតាមជនបទនៃប្រទេសកម្ពុជាដោយប្រើការវិភាគបណ្តាញ. Socio-Economic Planning Sciences 2011; 45: 48–57.

[16] Javadi FS, Rismanchi B, Sarraf M, Afshar O, Saidur R, Ping HW, et al. គោលនយោបាយសកលនៃអគ្គិសនីភាវូបនីយកម្មជនបទ។ Renewable and Sustainable Energy Reviews 2013;19: 402–16.

[17] http://www.camclimate.org.kh/en/documents-and-media/library/category/39-financing.html?download=912:full-report-on-cc-impacts-on-economic-growth-in-cambodia_may-2018_en

ថាត្រូវប្រើប្រាស់គោលនយោបាយសមស្រប ដើម្បីសម្រេចបាននូវតុល្យភាពនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងបង្កើនសមត្ថភាពបន្សាំ ដែលអាចធានាថាកម្ពុជាអាចទទួលបានបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍបញ្ចេញកាបូនតិច និងធន់នឹងអាកាសធាតុ។ ជាទូទៅចំនុចអាទិភាព គឺជានាការអភិវឌ្ឍវិស័យថាមពលមួយដែលមិនត្រូវបានរងផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ ហើយក្នុងពេលដំណាលគ្នានេះ ជំរុញឱ្យមានការអភិវឌ្ឍថាមពលកកើតឡើងវិញដែលមិនធ្វើឱ្យអាកាសធាតុពិភពលោកកាន់តែអាក្រក់ទៅ។ ការផ្លាស់ប្តូរសេដ្ឋកិច្ច និងបច្ចេកវិទ្យាបញ្ចេញកាបូនតិចត្រូវការវិធានការគោលនយោបាយ ភាពច្នៃប្រតិដ្ឋ និងពេលវេលាដោយក្នុងរយៈពេលខ្លី គឺការផ្តោតសំខាន់លើការពង្រឹងប្រសិទ្ធភាពថាមពល ក្នុងរយៈពេលមធ្យមជំរុញបង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការធ្វើពិពិធកម្មការផ្គត់ផ្គង់ថាមពលសម្រាប់ការប្រើប្រាស់ទាំងអស់ និងក្នុងរយៈពេលវែង ប្រើប្រាស់បច្ចេកវិទ្យាទំនើបចុងក្រោយដូចជាបច្ចេកវិទ្យាបញ្ចេញកាបូនតិចបន្ថែមទៀតសម្រាប់ផលិតកម្មថាមពល[18]។

## ១.១-ភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ

វិស័យថាមពល គឺងាយរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ ជាពិសេសការខូចខាតពីគ្រោះមហន្តរាយធម្មជាតិលើហេដ្ឋារចនាសម្ព័ន្ធថាមពល ម្យ៉ាងវិញទៀត វិស័យនេះក៏អាចបង្កឱ្យមានការប្រែប្រួលអាកាសធាតុតាមរយៈការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការប្រើប្រាស់ឥន្ធនៈហ្វូស៊ីល។ គ្រោះថ្នាក់អាកាសធាតុធំៗចំនួន៣ ទាក់ទងនឹងវិស័យថាមពលៈ

- ការកើនឡើងសីតុណ្ហភាព
- ការកើនឡើងចំនួន និងអាំងតង់ស៊ីតេនៃគ្រោះរាំងស្ងួត
- ការកើនឡើងចំនួន និងអាំងតង់ស៊ីតេព្យុះ និងទឹកជំនន់

តារាងទី ២ៈ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល

| ផ្នែក | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល |
|---|---|
| ថាមពលវារីអគ្គិសនី | ការកើនឡើងសីតុណ្ហភាពខ្លាំង អាចជះឥទ្ធិពលដល់អានុភាពថាមពលដែលអាចផលិតបានដោយសារការកើនឡើងនៃការរំហួតទឹកអស់ពីអាងស្តុកការប្រែប្រួល នៃរបបទឹកភ្លៀង ភាពរាំងស្ងួត ទឹកជំនន់ និងការធ្លាក់ភ្លៀងដោយសារព្យុះបង្កឱ្យមានការកើនឡើងបរិមាណទឹកនៅក្នុងអាងវារីអគ្គិសនីដែលអាចប៉ះពាល់ដល់ទំនប់ និងសមត្ថភាពផលិតថាមពល។ |
| ថាមពលខ្យល់ | ការកើនឡើងសីតុណ្ហភាពអាចបន្ថយដង់ស៊ីតេខ្យល់ដែលនាំទិន្នផលថាមពលថយចុះ។ |
| ថាមពលជីវម៉ាស់ | ការកើនឡើងសីតុណ្ហភាពអាចបណ្តាលឱ្យមានអគ្គិភ័យ និងគំរាមកំហែងដល់ទិន្នផលដំណាំកសិកម្មដែលប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផលិតកម្មអគ្គិសនី និងថាមពលនានា។ |

[18] Naudé, W. (2011). ការប្រែប្រួលអាកាសធាតុនិងគោលនយោបាយឧស្សាហកម្ម. *Sustainability* 2011, *3*, 1003-1021; doi:10.3390/su3071003

| | |
|---|---|
| ថាមពលពន្លឺព្រះអាទិត្យ | សីតុណ្ហភាពខ្ពស់អាចកាត់បន្ថយប្រសិទ្ធភាពរបស់ប្រព័ន្ធផលិតថាមពលពីពន្លឺព្រះអាទិត្យ។ |
| ថាមពលអគ្គិសនីដើរដោយកម្តៅ | សីតុណ្ហភាពខ្ពស់នៃទឹកស្អំឱ្យត្រជាក់អាចបន្ថយប្រសិទ្ធភាពថាមពលពីរោងចក្រអគ្គិសនីដើរដោយកម្តៅ។ |

តារាងទី២ បង្ហាញពីទិដ្ឋភាពទូទៅនៃផលប៉ះពាល់ការប្រែប្រួលអាកាសធាតុលើប្រព័ន្ធផលិតថាមពល ដែលការកើនឡើងសីតុណ្ហភាព ភាពញឹកញាប់និងអាំងតង់ស៊ីតេនៃគ្រោះរាំងស្ងួត ព្យុះ និងទឹកជំនន់ នឹងអាចប៉ះពាល់ដល់ការផលិត និងបញ្ជូនអគ្គិសនីពីប្រភពហ្វូស៊ីល និងប្រភពថាមពលកកើតឡើងវិញ (វារីអគ្គិសនី ជីវម៉ាស ជីវឧស្ម័ន ពន្លឺព្រះអាទិត្យ និងខ្យល់) ដែលការប្រែប្រួលអាកាសធាតុក៏អាចប៉ះពាល់ដល់តម្រូវការថាមពលរបស់ប្រទេសជាតិផងដែរ។ នៅឆ្នាំ២០១៩ ដោយសារភាពរាំងស្ងួត និងរដូវវស្សាមកដល់យឺត សមត្ថភាពផ្គត់ផ្គង់ថាមពលអគ្គិសនីមិនអាចឆ្លើយតបនឹងតម្រូវការបាន(រូបភាពទី១) ដែលបណ្តាលឱ្យមានការរអាក់រអួលក្នុងការផ្គត់ផ្គង់អគ្គិសនីនៅទូទាំងប្រទេស។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្គត់ផ្គង់ថាមពលអគ្គិសនីលើស ៤០% នៃតម្រូវការក្នុងរដូវវស្សា (រូបភាពទី២) ដែលស្ថានភាពនេះអាចបន្ថែមបញ្ហាប្រឈមទាក់ទងនឹងការគ្រប់គ្រងការផលិតថាមពលវារីអគ្គិសនីតាមរដូវកាល និងតម្រូវឱ្យមានការបន្ថែមសមត្ថភាពផលិតអគ្គិសនីច្រើនដើម្បីផ្គត់ផ្គង់អគ្គិសនីនៅរដូវប្រាំង។




រូបភាពទី១៖ សមត្ថភាពផ្គត់ផ្គង់និងតម្រូវការអគ្គិសនីក្នុងរដូវប្រាំងចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៩




រូបភាពទី២៖ សមត្ថភាពផ្គត់ផ្គង់និងតម្រូវការអគ្គិសនីក្នុងរដូវវស្សាចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩

ការវាយតម្លៃផលប៉ះពាល់ គឺជាកត្តាចាំបាច់សម្រាប់ការខិតខំប្រឹងប្រែងឆ្ពោះទៅការបង្កើនភាពធន់នឹងអាកាសធាតុ ស្ថិរភាព សន្តិសុខថាមពល និងសុវត្ថិភាព។ ផ្អែកតាមបទពិសោធន៍ និងការសិក្សាបានបង្ហាញឱ្យឃើញថា៖

- ធនធានថាមពលកកើតឡើងវិញ ជាពិសេសវារីអគ្គិសនី ជីវម៉ាស់ និងពន្លឺព្រះអាទិត្យ អាចរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ តាមរយៈការផ្លាស់ប្តូររបបទឹកភ្លៀង ការរាំងស្ងួត ទឹកជំនន់ និងសីតុណ្ហភាពកើនឡើង។
- ប្រព័ន្ធផលិត បញ្ជូន និងចែកចាយអគ្គិសនីដំណើរការមិនសូវមានប្រសិទ្ធភាពនៅពេលសីតុណ្ហភាពកើនឡើង ហើយអាចប្រឈមនឹងហានិភ័យនៃការខូចខាតដោយសារព្យុះ រន្ទះ រាំងស្ងួត និងទឹកជំនន់កាន់តែខ្លាំងនិងញឹកញាប់។
- សីតុណ្ហភាពខ្ពស់នឹងបង្កើនសេចក្តីត្រូវការប្រើប្រាស់អគ្គិសនីសម្រាប់ប្រព័ន្ធត្រជាក់ដែលប្រើប្រាស់ក្នុងលំនៅឋាន ពាណិជ្ជកម្ម និងឧស្សាហកម្មដែលអាចបណ្តាលឱ្យការផ្គត់ផ្គង់អគ្គិសនីមិនគ្រប់គ្រាន់។

## ខ.២-ការបង្កឱ្យមានការប្រែប្រួលអាកាសធាតុពីវិស័យថាមពល

ការកើនឡើងនៃសេចក្តីត្រូវការប្រើប្រាស់ថាមពលបានដាក់សម្ពាធយ៉ាងខ្លាំងដល់ការប្រើប្រាស់ប្រភពធនធានធម្មជាតិ និងបរិស្ថាន ជាពិសេសការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបំពុលខ្យល់ផ្សេងទៀត។ យោងតាមរបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង ប្រភពធំៗនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជា គឺមានចំនួន ៥៖ ១.ព្រៃឈើនិងការប្រើប្រាស់ដីផ្សេងទៀត ២.កសិកម្ម ៣.ថាមពល ៤.ដំណើរការឧស្សាហកម្ម និងការប្រើប្រាស់ផលិតផល និង ៥.សំណល់[19]។ រូបភាពទី៣ បង្ហាញពីបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ចេញពីប្រភពទាំង៥ នេះចាប់ពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០១៦។ យើងអាចសង្កេតឃើញថាការផ្លាស់ប្តូរការប្រើប្រាស់ដី និងព្រៃឈើ និងការធ្វើកសិកម្មគឺជាប្រភពដ៏សំខាន់នៃការការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ចំណែកវិស័យថាមពល

[19] https://unfccc.int/sites/default/files/resource/FBUR_Cambodia.pdf

ឧស្សាហកម្ម និងការប្រើប្រាស់ផលិតផលកំពុងកើនឡើងយ៉ាងឆាប់រហ័សក្នុងទសវត្សចុងក្រោយនេះដោយសារតែការប្រើប្រាស់ធ្យូងថ្ម និងឥន្ធនៈហ្វូស៊ីលសម្រាប់ការផលិតអគ្គិសនី ការកើនឡើងការប្រើឥន្ធនៈហ្វូស៊ីលសម្រាប់ការដឹកជញ្ជូន និងការអភិវឌ្ឍឧស្សាហកម្មនៅក្នុងប្រទេស។ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅឆ្នាំ២០១៦ របស់ប្រទេសកម្ពុជា (រូបភាពទី៤) បង្ហាញថា ព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀតមានចំណែក ៨០% នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបរបស់ប្រទេសប្រមាណ ១៦៣.៥៩២,៣៥Mt$CO_2$e ក្នុងឆ្នាំ២០១៦។ វិស័យកសិកម្មគឺជាអ្នកបញ្ចេញឧស្ម័នផ្ទះកញ្ចក់ខ្ពស់ជាងគេទី២ ប្រមាណ១១% នៃបរិមាណការការបញ្ចេញសរុបក្នុងឆ្នាំ២០១៦ ដែលក្នុងនោះមានការដាំដុះស្រូវ និងល្បើងមេតានក្នុងពោះរបស់សត្វទំពាអៀងជាប្រភពដ៏សំខាន់នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យកសិកម្ម។ វិស័យថាមពល វិស័យឧស្សាហកម្ម និងការប្រើប្រាស់ផលិតផល និងកាកសំណល់ បានរួមចំណែកការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ ៦% ១% និង ២% នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបរៀងៗខ្លួន។ យោងតាមរបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ប្រទេសកម្ពុជាបានកើនឡើងចំនួន ១២១,១៤២.០៧ Mt$CO_2$e ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១៦ ការកើនឡើងប្រចាំឆ្នាំជាមធ្យមក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបក្នុងកំឡុងពេលនេះគឺ ១២,៩៧% ក្នុងនោះការកើនឡើងប្រចាំឆ្នាំជាមធ្យមនៃវិស័យនានាមានដូចជា៖ ព្រៃឈើនិងការប្រើប្រាស់ដីផ្សេងទៀត (១៧.៥%) កសិកម្ម (២,៩២%) ថាមពលដោយគិតទាំងការប្រើប្រាស់ឥន្ធនៈក្នុងការដឹកជញ្ជូន (១១,៦៧%) ដំណើរការឧស្សាហកម្មនិងការប្រើប្រាស់ផលិតផល (២១,៦៨%) និងសំណល់ (៣,៦៣%)។




រូបភាពទី៣៖ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជា( Mt$CO_2$e )[20]

[20] https://unfccc.int/sites/default/files/resource/FBUR_Cambodia.pdf




រូបភាពទី ៤៖ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជាក្នុងឆ្នាំ២០១៦

នៅក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបពីផ្នែកថាមពល ៦% ក្នុងរូបភាពទី៤ ខាងលើ ការប្រើប្រាស់ឥន្ធនៈហ្វូស៊ីលសម្រាប់ការដឹកជញ្ជូនគឺជាប្រភពដ៏សំខាន់នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលស្មើនឹង ៥៣% នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបនៃផ្នែកថាមពលស្មើនឹង ៩,៦០MtCO₂e ក្នុងឆ្នាំ២០១៦ (រូបភាពទី៥)។ ផលិតកម្មប្រភពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនី រួមទាំងចំហេះឥន្ធនៈដែលក្នុងនោះក៏រាប់បញ្ចូលការដុតអុសសម្រាប់ចម្អិនអាហារ និងការផលិតថាមពលកម្ដៅក្នុងទម្រង់ជាចំហាយទឹកសម្រាប់ឧស្សាហកម្មផងដែរគឺជាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ខ្ពស់បំផុតទី២ ប្រមាណ ៣៤% នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបពីផ្នែកថាមពល។ ការ ប្រើប្រាស់ថាមពលដោយឡែកក្រៅពីថាមពលអគ្គិសនីដែលបណ្ដាញអគ្គិសនីបានផ្គត់ផ្គង់ នៅក្នុងឧស្សាហកម្មកម្មន្តសាល និងផ្នែកផ្សេងទៀតរួមគ្នាបញ្ចេញ ៨% និង ៥% នៃការបញ្ចេញឧស្ម័នសរុបរៀងៗខ្លួនពីផ្នែកថាមពល។




រូបភាពទី ៥៖ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការប្រើប្រាស់ថាមពលសរុប ៩,៦០MtCO₂e ក្នុងឆ្នាំ២០១៦

កំណត់សម្គាល់៖ ក្រសួងរ៉ែ និងថាមពលគ្រប់គ្រងការប្រើប្រាស់ថាមពលតែក្នុងផលិតកម្មប្រភពថាមពលដែលត្រូវផ្គត់ផ្គង់ជារួម និងការប្រើប្រាស់ផ្សេងទៀតប៉ុណ្ណោះ ដោយឡែកការប្រើប្រាស់ថាមពលដោយនៅក្នុងឧស្សាហកម្មកម្មន្តសាល និងការដឹកជញ្ជូន គឺមិនទាន់ឋិតនៅក្នុងការគ្រប់គ្រងដោយក្រសួងរ៉ែ និងថាមពលនៅឡើយទេ។

## ខ.៣-គំនិតផ្តួចផ្តើមដែលមានស្រាប់

ទោះជាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ពីប្រទេសកម្ពុជាមានតិចពេលគឺតិចជាង ១% នៃការបញ្ចេញឧស្ម័នរបស់ពិភពលោកក៏ដោយ ក៏ព្រះរាជាណាចក្រកម្ពុជាបានប្តេជ្ញាចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដើម្បីចូលរួមជាមួយពិភពលោកផងដែរ។ ការប្តេជ្ញាចិត្តនេះនឹងត្រូវអនុវត្តនៅក្នុងវិស័យថាមពលតាមរយៈការបង្កើនប្រសិទ្ធភាពថាមពល និងការជំរុញការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញនៅក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី និងនៅក្នុងវិស័យផ្សេងៗទៀត ដូចជានៅក្នុងវិស័យឧស្សាហកម្ម តាមរយៈការជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញជំនួសការប្រើឥន្ធនៈហ្វូស៊ីល ចំពោះការប្រើប្រាស់ថាមពលផ្សេងៗក្រៅពីការផ្គត់ផ្គង់អគ្គិសនីដោយប្រព័ន្ធបណ្តាញជាតិ និងគម្រោងប្រសិទ្ធភាពថាមពលនៅក្នុងរោងចក្រកាត់ដេរ រោងម៉ាស៊ីន កិនស្រូវ និងឡឥដ្ឋ ព្រមទាំងនៅក្នុងវិស័យដឹកជញ្ជូនតាមរយៈការលើកកម្ពស់ការដឹកជញ្ជូនសាធារណៈ និងការប្រើប្រាស់យានយន្តដែលមានប្រសិទ្ធភាពថាមពល និងយានយន្តដែលមិនប្រើឥន្ធនៈហ្វូស៊ីល និងសកម្មភាពផ្សេងៗក្នុងវិស័យផ្សេងទៀត[21]។

ក្រសួងរ៉ែ និងថាមពលបានចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងមួយចំនួន ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដូចជាការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពល ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍបៃតងជាតិ[22] ផែនការត្រៀមខ្លួនសម្រាប់ការផ្តល់ថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នានៅព្រះរាជាណាចក្រកម្ពុជា[23] និងសេចក្តីព្រាងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រសិទ្ធភាពថាមពល[24], ការរៀបចំផែនការមេអភិវឌ្ឍន៍ថាមពលនៅកម្ពុជាឡើងវិញ ដែលក្នុងនោះកំពុងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញឱ្យបានជាអតិបរមា ដោយធានាបាននូវការផ្គត់ផ្គង់ថាមពលមួយគ្រប់គ្រាន់ មានស្ថិរភាព និងមានថ្លៃសមរម្យ។ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពទាំងនេះនឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យថាមពល ដើម្បីសម្រេចបានគោលដៅគន្លឹះរបស់វិស័យថាមពល ក្នុងពេលជាមួយគ្នាជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការប្រើប្រាស់និងផលិតកម្មថាមពលបៃតង (ប្រភពថាមពលកកើតឡើងវិញ) ការអនុវត្តគម្រោងប្រសិទ្ធភាពថាមពល និងការបន្សុំាហេដ្ឋារចនាសម្ព័ន្ធថាមពលឱ្យមានសមត្ថភាពទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

# គ. ការងារអាទិភាពរបស់វិស័យថាមពល

ជាមួយគ្នានឹងការរៀបចំផែនការសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ របស់វិស័យថាមពលក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល សម្រាប់ឆ្នាំ២០២១-២០២៣ ក្រសួងក៏មានការងារអាទិភាពមួយចំនួនដែលក្រសួងរ៉ែ និងថាមពល ត្រូវអនុវត្តនៅក្នុងរយៈពេលនេះផងដែរ។ ជារួមការងាររបស់ក្រសួងរ៉ែ និងថាមពល ក្នុងវិស័យថាមពលដែលត្រូវបន្សុីគ្នាជាមួយសកម្មភាពការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការងារអាទិភាពរបស់វិស័យថាមពលផ្ទាល់សម្រាប់ឆ្នាំ ២០២១-២០២៣ មានជាអាទិ៍ដូចខាងក្រោម៖

[21] RGC. Updated Cambodia's Nationally Determined Contribution 2020
[22] Royal Government of Cambodia. National Green Growth Strategic Plan 2013
[23] Ministry of Industry, Mines and Energy (MIME). Cambodia Sustainable Energy for All Readiness Plan, Phnom Penh, Cambodia. 2013.
[24] Ministry of Industry, Mines and Energy (MIME). National Policy, Strategy And Action Plan on Energy Efficiency in Cambodia. 2013 (draft).

- បន្តបញ្ចុះថ្លៃអគ្គិសនី ពង្រីកបណ្តាញ និងបង្កើនស្ថិរភាពអគ្គិសនីដោយសាងសង់អនុស្ថានីយ៍បន្ថែមសម្រាប់ប៉ូលសេដ្ឋកិច្ច និងតំបន់សក្តានុពលសេដ្ឋកិច្ចខ្ពស់
- បន្តជំរុញការអភិវឌ្ឍតំបន់ជនបទដោយវិនិយោគលើការពង្រីកវិសាលភាពនៃប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី
- បន្តលើកទឹកចិត្ត និងបង្កើនការវិនិយោគលើ ថាមពលកកើតឡើងវិញជាមួយគ្នានឹងការកាត់បន្ថយផលិតកម្មថាមពលពីប្រភពឥន្ធនៈហ្វូស៊ីលជាបណ្តើរៗ ដើម្បីធានាបាននូវការផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យសង្គម និងសេដ្ឋកិច្ចកម្ពុជាប្រកបដោយប្រសិទ្ធភាពផង និងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុក្នុងរយៈពេលវែងផង
- រៀបចំគោលនយោបាយប្រសិទ្ធភាពថាមពល និងផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្ត
- សិក្សានិងកំណត់អត្តសញ្ញាណបច្ចេកវិទ្យាបញ្ចេញកាបូនតិច និងមេត្រីភាពបរិស្ថាន ដែលកម្ពុជាអាចធ្វើការអភិវឌ្ឍបានដោយរក្សាបាននូវគោលដៅគន្លឹះនៃការអភិវឌ្ឍវិស័យថាមពល
- រៀបចំ និងវិភាគប្រភពនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអនុវត្តវិធានការកាត់បន្ថយក្នុងវិស័យថាមពល
- ធ្វើការវាយតម្លៃភាពងាយរងគ្រោះនៃហេដ្ឋារចនាសម្ព័ន្ធថាមពលជាមួយនឹងការប្រែប្រួលអាកាសធាតុនឹងវិធានការបន្សុាំហេដ្ឋារចនាសម្ព័ន្ធទាំងនេះជាមួយការប្រែប្រួលអាកាសធាតុ
- បង្កើនសមត្ថភាពស្ថាប័នលើការបន្សុាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ រួមទាំងការវាយតម្លៃហានិភ័យ ក្របខ័ណ្ឌច្បាប់ ការរៀបចំស្ថាប័ន ការផ្ទេរបច្ចេកវិទ្យា ការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ។
- បង្កើតក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់វិស័យថាមពល ដើម្បីធានាការគ្រប់គ្រងនិងការប្រើប្រាស់ធនធានថាមពលប្រកបដោយប្រសិទ្ធភាព
- បន្តជំរុញការអភិវឌ្ឍថាមពលកកើតឡើងវិញគ្រប់ប្រភេទ និងបង្កើនប្រសិទ្ធភាពថាមពល
- រៀបចំផែនការមេអភិវឌ្ឍន៍វិស័យថាមពលឡើងវិញ ជាមួយនឹងការពិនិត្យលទ្ធភាពប្រើប្រាស់ថាមពលកកើតឡើងវិញឱ្យបានជាអតិបរមា ដោយរក្សាបាននូវគោលដៅគន្លឹះនៃការអភិវឌ្ឍវិស័យថាមពល
- ជំរុញការតភ្ជាប់បណ្តាញអគ្គិសនីឱ្យអ្នកប្រើប្រាស់អគ្គិសនីឱ្យបាន៩០% នៃគ្រួសារសរុបត្រឹមឆ្នាំ២០២៣
- ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់អគ្គិសនីដែលមានលក្ខណៈគ្រប់គ្រាន់ មានស្ថិរភាព សម្រាប់ការប្រើប្រាស់២៤ម៉ោង ប្រកបដោយគុណភាព សុវត្ថិភាព ថ្លៃសមរម្យ និងមានភាពយុត្តិធម៌ក្នុងការវាស់វែង និងកត់ត្រា
- កាត់បន្ថយផលប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គមឱ្យបានជាអតិបរមា
- គ្រប់គ្រងសក្តានុពលថាមពល ចូលរួមប្រើប្រាស់ប្រភពថាមពលស្អាត ចូលរួមក្នុងកិច្ចសហប្រតិបត្តិការថាមពលក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ។

## ២. យុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ គឺជាទំនួលខុសត្រូវរួមរបស់ពិភពលោក ដែលក្នុងប្រទេសនីមួយៗ ការងារនេះត្រូវការកិច្ចសហការ និងការអន្តរាគមន៍ពីថ្នាក់ដឹកនាំស្ថាប័នតាមវិស័យនីមួយៗ និងថ្នាក់ដឹកនាំជាតិផ្ទាល់។ យុទ្ធសាស្ត្រទូទៅសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុមានចំនួន២ គឺ៖ ១.ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស និង២.ការបន្សុាំជាមួយការប្រែប្រួលអាកាសធាតុ ដែលក្នុងនោះយុទ្ធសាស្ត្រកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាញឹកញាប់អាចមានឧបសគ្គក្នុងការអនុវត្ត ដោយ

សារការថ្លឹងថ្លែងរវាងផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គមនិងផលប្រយោជន៍ផ្នែកបរិស្ថាន ដូច្នេះគេបានរៀបចំនូវយុទ្ធសាស្ត្រទី២ គឺការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ ដែលនឹងកើតឡើងនៅពេលអនាគត។ ការរៀបចំយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុបានធ្វើជា ២កម្រិត គឺ ទី១. ការរៀបចំយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាសកល ដែលរៀបចំដោយលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និង ទី២.យុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាតិដែលរៀបចំដោយប្រទេសនីមួយៗ។

## ២-១-យុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាសកល

គោលដៅសំខាន់នៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាសកល គឺការជំរុញឱ្យប្រើបច្ចេកវិទ្យាបញ្ចេញកាបូនតិចក្នុងការអភិវឌ្ឍបន្តទៀត ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស។ មូលដ្ឋានគន្លឹះសំខាន់ៗសម្រាប់ជំរុញការបញ្ចេញកាបូនតិចនៅក្នុងការអភិវឌ្ឍបន្តទៀតមាន៣ គឺ៖ ១.ការរៀបចំគោលនយោបាយថ្មីសម្រាប់ការអភិវឌ្ឍ ២.គំរូនៃការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់ និង៣.ការបង្កើតធនធានប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រលើកទឹកចិត្តដល់គម្រោងវិនិយោគប្រភេទនេះ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយប្រើបច្ចេកវិទ្យាបញ្ចេញកាបូនតិច នៅក្នុងយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាសកលនេះ អាចផ្តល់ជាទិសដៅសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ការអភិវឌ្ឍថាមពល និងអាចកំណត់គោលដៅនៃបរិមាណការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលអាចធ្វើបាន សម្រាប់ប្រទេសនីមួយៗ និងអាចកំណត់ការងារអន្តរាគមន៍ជាអាទិភាព តាមរយៈគោលនយោបាយដែលរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ជាតិ។ ដូច្នេះនៅកម្រិតពិភពលោក យុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាសកល មានយុទ្ធសាស្ត្ររួមចំនួនបីសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរួមមាន៖[25]

- ការរៀបចំកម្មវិធីនយោបាយ ការរៀបចំនិងអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច
- គំរូនៃការប្រើប្រាស់ និងផលិតកម្មដែលប្រើធនធាន និងថាមពលឱ្យមានប្រសិទ្ធភាពបំផុត និង
- បង្វែរការវិនិយោគឆ្ពោះទៅរកបច្ចេកវិទ្យាស្អាត ថាមពលកកើតឡើងវិញ និងការគ្រប់គ្រងទឹក កសិកម្ម និងព្រៃឈើប្រកបដោយនិរន្តរភាព។

## ២-២-យុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាតិ

ប្រទេសកម្ពុជាបានរៀបចំ និងអនុម័ត ផ.យ.ប.អ.ក. ឆ្នាំ ២០១៤-២០២៣ ដើម្បីផ្តល់ផែនទីបង្ហាញផ្លូវដល់ភាគីដែលពាក់ព័ន្ធ និងភាគីដែលមានចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍវិធានការ និងសកម្មភាពជាក់ស្តែងឱ្យសមស្របតាមការបន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ក្នុងនោះគោលដៅយុទ្ធសាស្ត្រចំនួន ៨ ត្រូវបានស្នើឡើងរួមមាន៖

- **គោលដៅយុទ្ធសាស្ត្រទី១៖** លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការលើកកម្ពស់សន្តិសុខស្បៀង ទឹក និងថាមពល។

[25] EU and UNDP Low Emission Capacity Building Programme website.

- **គោលដៅយុទ្ធសាស្ត្រទី២៖** កាត់បន្ថយភាពងាយរងគ្រោះ យេនឌ័រ និងហានិភ័យសុខភាពចំពោះ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ឱ្យបានតាមតាមគ្រប់តំបន់ និងតាមវិស័យនីមួយៗ។
- **គោលដៅយុទ្ធសាស្ត្រទី៣៖** ធានាភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ ប្រព័ន្ធអេកូឡូស៊ីឆ្នេរសមុទ្រ តំបន់ខ្ពង់រាប ។ល។) ជីវចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌។
- **គោលដៅយុទ្ធសាស្ត្រទី៤៖** ជំរុញការរៀបចំផែនការ និងបច្ចេកវិទ្យាបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។
- **គោលដៅយុទ្ធសាស្ត្រទី៥៖** ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។
- **គោលដៅយុទ្ធសាស្ត្រទី៦៖** លើកកម្ពស់កិច្ចគាំពារសង្គមដែលមានភាពបន្សាំ និងវិធីសាស្ត្រចូលរួមការកាត់បន្ថយការបាត់បង់ និងការខូចខាតដោយសារការប្រែប្រួលអាកាសធាតុ ។
- **គោលដៅយុទ្ធសាស្ត្រទី៧៖** ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌសម្របសម្រួលសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាតិ។
- **គោលដៅយុទ្ធសាស្ត្រទី៨៖** ពង្រឹងកិច្ចសហប្រតិបត្តិការ និងការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការប្រែប្រួលអាកាសធាតុ ក្នុងតំបន់ និងពិភពលោក។

លើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាតិខាងលើ គោលបំណងជាយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពល ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល សម្រាប់ឆ្នាំ ២០២១-២០៣០ មានចំនួន ៤ ដូចខាងក្រោម៖

- **គោលដៅជាយុទ្ធសាស្ត្រទី១៖** អភិវឌ្ឍគោលនយោបាយវិស័យថាមពលមួយ ដែលមានគោលដៅឆ្ពោះទៅរកថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា (SEforALL) ដោយធានាបាននូវគោលដៅគន្លឹះរបស់វិស័យថាមពលបច្ចុប្បន្នគឺការផ្គត់ផ្គង់ប្រភពថាមពលឱ្យបានគ្រប់គ្រាន់ អាចទុកចិត្តបាន និងមានថ្លៃសមរម្យ ប្រកួតប្រជែងជាមួយប្រទេសជិតខាង។
- **គោលដៅជាយុទ្ធសាស្ត្រទី២៖** ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យថាមពលឱ្យមានលក្ខណៈស៊ាំឬធន់នឹងការប្រែប្រួលអាកាសធាតុ។
- **គោលដៅជាយុទ្ធសាស្ត្រទី៣៖** អនុវត្តវិធីសាស្ត្រគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ សម្រាប់វិស័យថាមពល។
- **គោលដៅជាយុទ្ធសាស្ត្រទី៤៖** បង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។

## ៣. ផែនការសកម្មភាព

### ក. សង្ខេបវិសាលភាពនៃផែនការ

ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពល គឺផ្តោតសំខាន់លើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ តាមរយៈការកសាងសមត្ថភាពស្ថាប័នរបស់ក្រសួងរ៉ែ និងថាមពល និងមន្ត្រីរបស់ក្រសួង ក្នុងការរៀបចំគោលនយោបាយ និងសេចក្តីណែនាំចាំបាច់ក្នុងការអនុវត្តសកម្មភាពនានា និងក្នុងការសហការជាមួយភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ និងព្រឹត្តិការណ៍អាកាសធាតុបន្ទាន់ៗ ដូចជាទឹកជំនន់ ព្យុះគ្រោះរាំងស្ងួត ក៏ដូចជាការកើនឡើងសីតុណ្ហភាពជាដើម។ ផែនការសកម្មភាពនេះនឹងបន្តពង្រីកសកម្មភាពដែលមានស្រាប់ទាំងឡាយ ព្រមទាំងស្នើដាក់នូវសកម្មភាពថ្មីៗដែលពាក់ព័ន្ធនឹងផលប៉ះពាល់អាកាសធាតុទៅលើហេដ្ឋារចនាសម្ព័ន្ធថាមពល និងការអភិវឌ្ឍដែលមានមេត្រីភាពជាមួយបរិស្ថាន។

### ខ. តារាងផែនការសកម្មភាព

ក.រ.ថ. ស្នើដាក់ផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យថាមពលក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ដូចមានសង្ខេបនៅក្នុងតារាងទី៣ខាងក្រោម៖

តារាងទី៣៖ តារាងផែនការសកម្មភាព

| យុទ្ធសាស្ត្រ ផ.យ.ប.អ.ក. | រ.ប.ជ.អ.ក.ស.ប.ប.អ. | យុទ្ធសាស្ត្រ ផ.យ.ប.អ.ប. | ល.រ. ផែនការសកម្មភាព | ឈ្មោះផែនការសកម្មភាពប្រែប្រួលអាកាសធាតុ | ប្រភេទនៃសកម្មភាព | នាយកដ្ឋានទទួលខុសត្រូវ | ថវិកាប៉ាន់ស្មានបឋម (ពាន់ដុល្លារ) | | | | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ២០២១ | ២០២២ | ២០២៣ | សរុប | |
| ១ | | | | លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល។ | | | | | | | |
| | | ១ | | អភិវឌ្ឍគោលនយោបាយវិស័យថាមពលមួយដែលមានគោលដៅឆ្ពោះទៅរកថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា (SEforALL) ដោយធានាបាននូវគោលដៅគន្លឹះរបស់វិស័យថាមពលបច្ចុប្បន្នគឺការផ្គត់ផ្គង់ប្រភពថាមពលឱ្យបានគ្រប់គ្រាន់អាចទុកចិត្តបាន និងមានថ្លៃសមរម្យប្រកួតប្រជែងជាមួយប្រទេសជិតខាង។ | | | | | | | |
| | ១៨ | | ១ | រៀបចំផែនការមេអភិវឌ្ឍន៍វិស័យអគ្គិសនីនៅកម្ពុជាឡើងវិញ។ | កែលម្អ | អ.ន.ថ | ២.១០០,៤០ | ១២០,០០ | ១២០,០០ | ២.៣៤០,៤០ | ADB |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ម.ម. | | ២ | រៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ | កែលម្អ | អ.ន.ថ | ៩៣៤,២៧ | ៥០០,០០ | ៥០០,០០ | ១.៩៣៤,២៧ | ADB |
| ២ | | | | **កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ** | | | | | | | |
| | | ២ | | **ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យថាមពលឱ្យមានលក្ខណៈស៊ាំឬធន់នឹងការ ប្រែប្រួលអាកាសធាតុ** | | | | | | | |
| | ម.ម. | | ៣ | រៀបចំពង្រឹងសមត្ថភាព និងស្ថិរភាពអនុស្ថានីយ និងខ្សែបណ្តាញបញ្ជូនអគ្គិសនី។ | កែលម្អ | អ.ក. | ៤៩.៩៣០,០០ | ៨៦.០៤០,០០ | ៥៧.៧២០,០០ | ១៩៣.៦៩០,០០ | ADB |
| | ២៤ | | ៤ | រៀបចំសិក្សាហានិភ័យអាកាសធាតុសម្រាប់ប្រព័ន្ធថាមពលនៅកម្ពុជានិងផ្តល់អនុសាសន៍សម្រាប់ការអនុវត្តនាពេលអនាគត។ | ថ្មី | អ.ន.ថ. អ.ក. | ១៤៦,០០ | ១១៦,០០ | ៦០,០០ | ៣២២,០០ | មិនទាន់មាន |
| ៤ | | | | **លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព** | | | | | | | |
| | | ៣ | | **អនុវត្តវិធីសាស្រ្តគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល** | | | | | | | |
| | ម.ម. | | ៥ | បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យឧស្ម័នផ្ទះកញ្ចក់និងការប្រើប្រាស់ថាមពលថ្នាក់ជាតិ | កែលម្អ | ន.អ.ថ. | ១៧៦,០០ | ១៤២,០០ | ២៥៨,០០ | ៥៧៦,០០ | មិនទាន់មាន |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សម្រាប់ការធ្វើសន្និធិឧស្ម័នផ្ទះកញ្ចក់ និងតុល្យភាពថាមពល | | | | | | | |
| | ១៧ | | ៦ | ផ្តល់ជូនប្រភពថាពលអគ្គិសនីស្អាតនិងបច្ចេកវិទ្យាបញ្ចេញកាបូនតិចទៅកាន់ភូមិនិងគ្រួសារដែលនៅដាច់ស្រយាលមិនទាន់មានអគ្គិសនីប្រើប្រាស់។ | ពង្រីក | ន.ថ.ក.ផ. | ២០.៧៨២,១៩ | ១៨.០៤៣,១៩ | ៣៦.០៨៦,៣៨ | ៧៤.៩១១,៧៦ | មិនទាន់មាន |
| | ម.ម. | | ៧ | រៀបចំនិងអនុវត្តគម្រោងប្រសិទ្ធភាពថាមពលក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ | ថ្មី | ន.ប.ថ.គ.ថ. | ២០០,០០ | ២០០,០០ | ២០០,០០ | ៦០០,០០ | មិនទាន់មាន |
| | ១២ | | ៨ | រៀបចំនិងអនុវត្តកម្មវិធីស្លាកសញ្ញា និងស្តង់ដាប្រសិទ្ធភាពថាមពលក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ | កែលម្អ | ន.ប.ថ.គ.ថ. | ២.១០០,០០ | ៤០០,០០ | ៤០០,០០ | ២.៩០០,០០ | មិនទាន់មាន |
| | ១៦ | | ៩ | រៀបចំសិក្សាថាមពលស្អាត ប្រកបដោយនិរន្តរភាពសម្រាប់ការចម្អិនអាហារនិងអនុវត្តជម្រើសដែលល្អបំផុត។ | ថ្មី | ន.អ.ថ. | ១០០,០០ | ១.០០០,០០ | ៤០០,០០ | ១.៥០០,០០ | មិនទាន់មាន |
| | ម.ម. | | ១០ | រៀបចំសិក្សាគំរូអាជីវកម្មប្រកបដោយនិរន្តរភាពដើម្បីប្រើប្រាស់ថាមពលកម្តៅ និងចំហាយទឹកប្រកបដោយប្រសិទ្ធភាព។ | ថ្មី | ន.ថ.ក. | ៦០០,០០ | ៤០០,០០ | ៣០០,០០ | ១.៣០០,០០ | មិនទាន់មាន |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ១៤ | | ១១ | បង្កើតកម្មវិធីគ្រប់គ្រងថាមពលសម្រាប់អគារធំៗ និងរោងចក្រធំៗ និងតាមបែបគោលការណ៍ស្ម័គ្រចិត្តសម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ | ថ្មី | ន.អ.ថ, ន.ប.ថ. គ.ថ. | ៤០០,០០ | ៥០០,០០ | ៤០០,០០ | ១.៣០០,០០ | មិនទាន់មាន |
| ៥ | | ៤ | | **បង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | |
| | ម.ម. | | ១២ | បង្កើននិងរៀបចំការកសាងពង្រឹងសមត្ថភាពថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល។ | កែលម្អ | អ.ន.ថ | ១០០,០០ | ៥០,០០ | ៥០០,០០ | ៦៥០,០០ | មិនទាន់មាន |
| | ១៣ | | ១៣ | បង្កើនការយល់ដឹងជាសាធារណៈលើការសន្សំសំចៃថាមពល។ | ថ្មី | អ.ន.ថ | ១៩០,០០ | ៥០០,០០ | ៥០០,០០ | ១.១៩០,០០ | មិនទាន់មាន |
| សរុបរួម | | | | | | | ៧៧.៧៥៨,៨៧ | ១០៨.០១១,១៩ | ៩៧.៤៤៤,៣៨ | ២៨៣.២១៤,៤៤ | |

## គ. លទ្ធផលរំពឹងទទួលបានពីការអនុវត្តផែនការសកម្មភាពនេះ

ផ.ស.ប.អ.ថ. នឹងពង្រឹងការទទួលខុសត្រូវរបស់ក្រសួងរ៉ែ និងថាមពល ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យថាមពលដែលឋិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល។ ផ.ស.ប.អ.ថ. នឹងបង្កើតការអនុវត្តផ្អែកលើភ័ស្តុតាង ដើម្បីជូនដំណឹងដល់ការអន្តរាគមន៍ការប្រែប្រួលអាកាសធាតុនាពេលអនាគតតាមរយៈគោលនយោបាយ ដែលមានលក្ខណៈកាន់តែប្រសើរ ការផ្តល់មូលដ្ឋានទិន្នន័យការប្រែប្រួលអាកាសធាតុ និងភាពធន់ឬភាពស៊ាំ ការគ្រប់គ្រងធនធាន និងសមត្ថភាពគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ចំណេះដឹង និងការយល់ដឹងអំពីការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

លទ្ធផលរំពឹងទុកនៃការអនុវត្តផែនការសកម្មភាពដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពលនេះនឹងមានទាំងអត្ថប្រយោជន៍ទាំងរយៈពេលខ្លី និងទាំងរយៈពេលវែង។

អត្ថប្រយោជន៍រយៈពេលខ្លីរួមមាន៖

- បង្កើនសមត្ថភាពមន្ត្រីបច្ចេកទេសរបស់ក្រសួង និងដៃគូដែលពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពនានាដើម្បីដោះស្រាយការបន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (ឧទាហរណ៍ តាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលអំពីវិធីសាស្ត្រ និងមធ្យោបាយដោះស្រាយបញ្ហាថ្មីៗ)
- បង្កើតក្របខ័ណ្ឌស្ថាប័ន និងច្បាប់៖ វិធានការ និងគោលនយោបាយដែលត្រូវបានបង្កើតឡើង ដែលបានបញ្ចូលទៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សៀវភៅណែនាំបច្ចេកទេស ឬមគ្គុវិធាននានា ដែលបានបង្កើតឡើង។
- ការផ្ទេរបច្ចេកវិទ្យាផ្នែកទន់ និងរឹងពីប្រទេសអភិវឌ្ឍន៍មកប្រទេសកម្ពុជា
- ការផ្លាស់ប្តូរឥរិយាបថរបស់ក្រុមគោលដៅផ្សេងៗគ្នា សម្រាប់ការងារបន្សាំខ្លួន និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- ការប្តេជ្ញាចិត្ត និងការចូលរួមរបស់អ្នកពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ជាពិសេសស្ថាប័នរាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។

អត្ថប្រយោជន៍រយៈពេលវែងរួមមាន៖

- ធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចមេត្រីភាពបរិស្ថាន ដែលជួយកាត់បន្ថយភាពក្រីក្រ បង្កើនផលិតភាព និងគុណភាពជីវិត ធ្វើឱ្យប្រសើរឡើងនូវបរិស្ថានដែលយើងកំពុងរស់នៅទាំងអស់គ្នា
- អភិរក្សធនធានធម្មជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព
- ពិចារណាលើការវិនិយោគរយៈពេលវែង និងវិធានការការពារទុកជាមុននានា
- លើកកម្ពស់សង្គមឱ្យមានបរិស្ថានល្អ (កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ កាកសំណល់ និងការបំពុលផ្សេងៗ)។
- ការប្រើប្រាស់ធនធានទឹក ថាមពល និងធនធានផ្សេងទៀតឱ្យបានយូរអង្វែង។

## ៤. ការគ្រប់គ្រង និងយន្តការហិរញ្ញវត្ថុ

### ក. ការវិភាគលើការគ្រប់គ្រង និងយន្តការហិរញ្ញវត្ថុដែលមានស្រាប់

រូបភាពទី៦ ខាងក្រោមបង្ហាញពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ក្រសួងរ៉ែ និងថាមពល។ ក្រសួងមានអគ្គនាយកដ្ឋានចំនួន ៥ រួមមានអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកដ្ឋានធនធានរ៉ែ អគ្គនាយកដ្ឋានប្រេងកាត អគ្គនាយកដ្ឋានថាមពល និងអគ្គាធិការដ្ឋាន។ ក្នុងចំណោមនោះ អគ្គនាយកដ្ឋានថាមពល នឹងទទួលខុសត្រូវក្នុងការអនុវត្ត ផ.ស.ប.អ.ថ.នេះ។

### ខ. ការវិភាគប្រភព និងបរិមាណហិរញ្ញវត្ថុសម្រាប់សកម្មភាពប្រែប្រួលអាកាសធាតុ

#### ខ.១) ថវិកាជាតិ និងថវិកាសម្រាប់ក្រសួងរ៉ែ និងថាមពល

ចាប់តាំងពីឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំឱ្យដាក់បញ្ចូលសកម្មភាពប្រែប្រួលអាកាសធាតុនៅក្នុងសារាចរណែនាំថវិកាប្រចាំឆ្នាំសម្រាប់ក្រសួងពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាបស់ក្រសួងនីមួយៗ។ ក្រសួងសំខាន់ៗបានចាប់ផ្តើមធ្វើសមាហរណកម្មសកម្មភាពប្រែប្រួលអាកាសធាតុតាមអាទិភាពរបស់សកម្មភាពសម្រាប់ថវិកាជាតិរួចទៅហើយ។ នៅឆ្នាំ ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយថវិកាប្រមាណ ១ភាគរយ នៃផលិតផលក្នុងស្រុកសរុបសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើការត្រួតពិនិត្យការចំណាយសាធារណៈទៀងទាត់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុជាការពិចារណាក្នុងគោលការណ៍ណែនាំថវិកាជាតិដែលនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរ និងគ្រប់គ្រងធនធានខាងក្រៅ និងក្នុងស្រុកសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ រាជរដ្ឋាភិបាលបានផ្លាស់ប្តូរទស្សនាទានប្រកបដោយអំណោយផលជាមួយវិស័យឯកជន ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ការវិនិយោគបៃតង និងហិរញ្ញវត្ថុបៃតង។

#### ខ.២) យន្តការកៀរគរហិរញ្ញវត្ថុ

ក្រៅពីថវិកាជាតិ ក្រសួងរ៉ែ និងថាមពលបានបង្កើតភាពជាដៃគូជាមួយម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍មួយចំនួនលើបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ការងារនៃការកៀរគរហិរញ្ញវត្ថុ ត្រូវបានដឹកនាំដោយអគ្គនាយកតាមអគ្គនាយកដ្ឋាននីមួយៗ តាមរយៈសំណើគម្រោងហើយត្រូវបានអនុម័តយល់ព្រមដោយរដ្ឋមន្ត្រី។




រូបភាពទី ៦៖ រចនាសម្ព័ន្ធរបស់ក្រសួងរ៉ែ និងថាមពល[26]

[26] RGC (2018). Subdegree 184 ANKrBk on Allocation of National Expenditure by Chapter of the 2019 Financial Law for Management, Phnom Penh, Cambodia.

## ខ.៣) ប្រភព និងបរិមាណហិរញ្ញវត្ថុសម្រាប់ផែនការសកម្មភាព

ការចំណាយរបស់ ផ.ស.ប.អ.ថ. នេះត្រូវបានប៉ាន់ប្រមាណថាមានចំនួន ២៨៣ ២១៤ ៤៤០ ដុល្លារអាមេរិក ក្នុងរយៈពេល៣ឆ្នាំ ដែលមួយផ្នែកធំនៃថវិកាសម្រាប់ ផ.ស.ប.អ.ថ. នឹងត្រូវផ្តល់ហិរញ្ញប្បទានតាមរយៈដៃគូអភិវឌ្ឍន៍។ ក្នុងចំនួនថវិកា ២៨៣ ២១៤ ៤៤០ ដុល្លារអាមេរិកនេះ ថវិកាដែលបានកៀរគររួចហើយមានចំនួន ១៩៧ ៩៦៤ ៦៧៥ ដុល្លារអាមេរិក ស្មើនឹង ៦៩,៩០%។ ថវិកានេះបានប្រភពពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ជាកម្ចីអនុគ្រោះ (Concessional Loan)ចំនួនប្រមាណ ១២៧ ៨០០ ០០០ ដុល្លារអាមេរិក ពីមូលនិធិអាកាសធាតុយុទ្ធសាស្ត្រ (Strategic Climate Fund) ចំនួនប្រមាណ ៤ ៧០០ ០០០ដុល្លារអាមេរិក ជាជំនួយឥតសំណងមូលនិធិថាមពលស្អាត (Clean Energy Fund) មានចំនួនប្រមាណ ២ ០០០ ០០០ ដុល្លារអាមេរិក ជាជំនួយឥតសំណងពីរាជរដ្ឋាភិបាលចំនួន ២៨ ៩៥១ ៥០២ ដុល្លារអាមេរិក ជាថវិកាបដិភាគតាមរយៈការលើកលែងពន្ធ និងពីអគ្គិសនីកម្ពុជាចំនួន ៣០ ២០១ ៥១៩ ដុល្លារអាមេរិក ជាថវិកាបដិភាគ។ ម្ចាស់ជំនួយធំៗជាច្រើនរួមមាន SIDA UNDP និង EU កំពុងជួយដល់សម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា ដោយផ្តល់ថវិកាសរុបចំនួន ១២,៨ លានដុល្លារអាមេរិកសម្រាប់ឆ្នាំ២០១៩-២៣ ។ មូលនិធិសកលសម្រាប់ការប្រែប្រួលអាកាសធាតុរួមមាន CIF, GEF, LCDF, AF, FCPF និង UN-REDD គឺជាប្រភពហិរញ្ញវត្ថុដ៏មានសក្តានុពលសម្រាប់ការអនុវត្ត ផ.ស.ប.អ.ថ. របស់ក្រសួងរ៉ែ និងថាមពល ដែលរំពឹងថាដើរតួសំខាន់ក្នុងការផ្តល់ឥណទានបច្ចេកទេសសម្រាប់អនុវត្តផែនការសកម្មភាពនេះ ដោយសារទំហំហិរញ្ញប្បទានរបស់មូលនិធិរំពឹងថានឹងមានទំហំធំជាងមុនបន្ថែមទៀត។ លើសពីនេះ ដៃគូទ្វេភាគីសំខាន់ៗដែលគាំទ្រក្រសួងរ៉ែ និងថាមពល លើការងារប្រែប្រួលអាកាសធាតុគឺ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ប្រទេសអាឡឺម៉ង់ (តាមរយៈ GIZ) ទីភ្នាក់ងារ USAID ទីភ្នាក់ងារ JICA ទីភ្នាក់ងារ KOICA ជំនួយប្រទេសចិន ចក្រភពអង់គ្លេស និងSIDA។

ម៉្យាងវិញទៀត សហមូលនិធិក៏អាចស្វែងរកបានពីមូលនិធិឯកទេសលើការប្រែប្រួលអាកាសធាតុ (មូលនិធិបន្សាំ(AF) មូលនិធិអាកាសធាតុបៃតង (GCF) មូលនិធិ GEF/ LDCF មូលនិធិអភិវឌ្ឍន៍នរ៉ឌិក) ដើម្បីរៀបចំគម្រោងការប្រែប្រួលអាកាសធាតុណាដែលមានលក្ខណៈអាទិភាពចាំបាច់ និងកំពុងអនុវត្តស្រាប់ ឬគម្រោងប្រែប្រួលអាកាសធាតុដែលមានគោលបំណងជាក់លាក់ណាមួយ។ ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិដូចជា UNDP ឬ UNIDO អាចចាប់អារម្មណ៍ជួយគាំទ្រដល់ការកៀរគរធនធានសម្រាប់សកម្មភាពមួយចំនួន និងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍបច្ចេកទេស និងសមត្ថភាព។ ក្រៅពីនេះ ក៏មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផងដែរ ដែលធ្វើសកម្មភាពនៅក្នុងវិស័យថាមពលកកើតឡើងវិញ។ ការគាំទ្រគោលនយោបាយ និងការអភិវឌ្ឍសមត្ថភាព ក៏ដូចជាការផ្តល់មូលនិធិសម្រាប់សកម្មភាពប្រកបដោយភាពច្នៃប្រតិដ្ឋប្រហែលជាអាចកៀរគរបានតាមរយៈ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ឬវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល។ សក្តានុពលសម្រាប់ហិរញ្ញប្បទាន ឥណទានកាបូននៃគំនិតផ្តួចផ្តើមកាត់បន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ ក៏គួរតែត្រូវបានស្វែងរកផងដែរ ដោយមានការគាំទ្របច្ចេកទេសពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

### ៤.៤) គន្លឹះសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការគ្រប់គ្រង និងហិរញ្ញវត្ថុ

សកម្មភាពរបស់ ផ.ស.ប.អ.ថ. ដែលបានកំណត់ច្បាស់លាស់ នឹងត្រូវបានដាក់បញ្ចូលនៅក្នុងការកែប្រែប្រចាំឆ្នាំរបស់ផែនការវិនិយោគសាធារណៈដែលចាប់ផ្តើមនៅឆ្នាំ២០២០ សម្រាប់ ឆ្នាំ២០២១ ទៅឆ្នាំ២០២៣។

នៅកម្រិតគម្រោងគឺត្រូវធានាថាត្រូវមានលក្ខខណ្ឌវិនិច្ឆ័យ សម្រាប់ការរៀបចំគម្រោងថ្មីណាមួយនៅក្នុងក្រសួងរ៉ែ និងថាមពល រួមមានការវាយតម្លៃអំពីនិពទ្ធភាព ឬភាពពាក់ព័ន្ធអាកាសធាតុ ហើយប្រសិនបើគម្រោងត្រូវបានរកឃើញថាពាក់ព័ន្ធនឹងអាកាសធាតុ ត្រូវការធានាថាមានការដាក់បញ្ចូលវិធានការដាក់លាក់នៅក្នុងការរៀបចំសំណើគម្រោង ដើម្បីចូលរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ឬការបន្សាំ។ ការតស៊ូមតិលើបញ្ហានេះ នឹងផ្តោតលើទាំងផ្នែកបច្ចេកទេស និងនាយកដ្ឋានពាក់ព័ន្ធនឹងការពិនិត្យ និងបង្កើតគម្រោងថ្មី។

បច្ចុប្បន្នមិនមានថវិកាមូលធនក្នុងស្រុកគួរឱ្យកត់សម្គាល់ (លើកលែងតែមូលនិធិសមភាគី) ដែលត្រូវបានបម្រុងទុកសម្រាប់វិស័យថាមពលនៅឡើយទេ។ នៅពេលក្រសួងរ៉ែ និងថាមពល រៀបចំថវិកាកម្មវិធី ពេលនោះសកម្មភាព ផ.ស.ប.អ.ថ. នឹងត្រូវរាប់បញ្ចូលក្នុងថវិកាកម្មវិធីសម្រាប់ការផ្តល់ថវិកាតាមរយៈថវិកាជាតិ។

## ៥. ការពិនិត្យតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃនៃ ផ.ស.ប.អ.ថ. នេះមានលក្ខណៈស្របទៅនឹងក្របខ័ណ្ឌពិនិត្យតាមដាន និងការវាយតម្លៃសម្រាប់ការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា ដែលត្រូវបានបង្កើតឡើងដោយ ផ.យ.ប.អ.ក. ក៏ដូចជា សូចនាករ ផ.យ.អ.ជ. ស្តីពីការប្រែប្រួលអាកាសធាតុ។ ក្របខ័ណ្ឌនេះរួមបញ្ចូលសូចនាករសំខាន់ៗចំនួន៤ ដែលនឹងត្រូវវាស់ជារៀងរាល់ឆ្នាំដូចមានបង្ហាញក្នុងតារាងទី៤ខាងក្រោម៖

តារាងទី ៤៖ ប្រភេទសូចនាករ ពិនិត្យតាមដាននិងវាយតម្លៃ

| ប្រភេទសូចនាករ | គោលបំណង | ភាពញឹកញាប់ |
|---|---|---|
| ១. ការផ្សព្វផ្សាយ និង ការបញ្ជ្រាប ផ.ស.ប.អ.ថ. | វឌ្ឍនភាពសកម្មភាព និងការអនុវត្តគម្រោងក្នុង ផ.ស.ប.អ.ថ. | ប្រចាំឆ្នាំ |
| ២. ការរៀបចំពង្រឹងស្ថាប័ន | វឌ្ឍនភាពក្នុងពង្រឹងសមត្ថភាពស្ថាប័ន រួមមានការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍវិស័យថាមពល | ប្រចាំឆ្នាំ |
| ៣. លទ្ធផល | ការវាយតម្លៃលទ្ធផលសកម្មភាពគម្រោង | ប្រចាំឆ្នាំ ឬអាស្រ័យលើសកម្មភាព[27] |
| ៤. ផលជះ | ការវាយតម្លៃវឌ្ឍនភាពឆ្ពោះទៅរកការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យថាមពល | ប្រចាំឆ្នាំ |

[27] ដោយសារសកម្មភាពភាគច្រើននឹងតម្រូវឱ្យមានការបង្កើតសំណើគម្រោងដើម្បីទទួលបានមូលនិធិដែលត្រូវការសម្រាប់ការអនុវត្ត សូចនាករដែលបានកំណត់នេះគឺជាការចាប់ផ្តើមប៉ុណ្ណោះហើយនឹងត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីវិសាលភាពជាក់ស្តែងនៃសកម្មភាព។ មានតែសូចនាករដែលទាក់ទងនឹងសកម្មភាពដែលត្រូវបានផ្តល់ថវិកាសម្រាប់ការអនុវត្តប៉ុណ្ណោះដែលនឹងត្រូវបានត្រួតពិនិត្យ។

សូមកត់សម្គាល់អំពីសូចនាករនៃការអនុវត្ត ផ.ស.ប.អ.ថ. ទាំងនេះ ទោះបីជាផ្នែកខ្លះត្រួតគ្នាជាមួយការរៀបចំពង្រឹងស្ថាប័នដទៃ និងសូចនាករលទ្ធផល ដែលជាផ្នែកមួយនៃក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃជាក់លាក់ ប៉ុន្តែក៏បានផ្តល់ទិដ្ឋភាពសង្ខេបនៃភាពជោគជ័យរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការអនុវត្ត ផ.ស.ប.អ.ថ. ហើយក៏ជួយសម្រួលដល់ការប្រៀបធៀបជាមួយការអនុវត្ត ផ.ស.ប.អ នៅក្នុងវិស័យដទៃទៀតដែរ។ សំណុំសូចនាករពេញលេញដែលជាផ្នែកមួយនៃក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃរបស់ ផ.ស.ប.អ.ថ. នេះ មានបង្ហាញក្នុងតារាងទី៥ ខាងក្រោម។

តារាងទី ៥៖ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ

| ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ផ.ស.ប.អ.ថ. របស់ក្រសួងរ៉ែ និងថាមពល | | |
|---|---|---|
| | **សូចនាករ** | **ឯកតា** |
| ១. ការអនុវត្ត ផ.ស.ប.អ.ថ. | | |
| | សកម្មភាពបានទទួលមូលនិធិដោយជោគជ័យ | ចំនួន |
| | ការដាក់បញ្ចូលសកម្មភាព ផ.ស.ប.អ.ថ. ទៅក្នុងផែនការវិនិយោគសាធារណៈ និងផែនការយុទ្ធសាស្ត្រថវិកា | ចំនួន |
| ២. ការពង្រឹងស្ថាប័ន | ស្ថានភាពនៃការអភិវឌ្ឍនៃគោលនយោបាយ និងផែនការថាមពល | %(វិធីសាស្ត្រដណ្តើរ) |
| | ការសម្របសម្រួលនៃការឆ្លើយតបនឹងការប្រែប្រួល និងការអនុវត្ត ផ.ស.ប.អ.ថ. | % (វិធីសាស្ត្រដណ្តើរ) |
| | ស្ថានភាពនៃការគ្រប់គ្រងព័ត៌មានទាក់ទងនឹងអាកាសធាតុ | % (វិធីសាស្ត្រដណ្តើរ) |
| ៣. សូចនាករលទ្ធផល | | |
| សកម្មភាពទី ១៖ រៀបចំធ្វើបច្ចុប្បន្នភាពផែនការមេអភិវឌ្ឍន៍វិស័យថាមពលនៅកម្ពុជា។ | • ការអនុវត្តផែនការមេ | %នៃថាមពលកកើតឡើងវិញ |
| សកម្មភាពទី ២៖ រៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ។ | • ការអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពប្រសិទ្ធភាពថាមពល | ប័ណ្ណពិន្ទុ (វិធីសាស្ត្រដណ្តើរ) |
| សកម្មភាពទី ៣៖ រៀបចំពង្រឹងសមត្ថភាព និងស្ថិរភាពអនុស្ថានីយ និងខ្សែបណ្តាញបញ្ជូនអគ្គិសនី។ | • សន្ទុស្សន៍នៃថាមពលកកើតឡើងវិញនៅក្នុងល្បាយផលិតកម្មថាមពល<br>• បរិមាណឧស្ម័នផ្ទះកញ្ចក់បានកាត់បន្ថយ | • %នៃ ថាមពលកកើតឡើងវិញ<br>• បរិមាណឧស្ម័នផ្ទះកញ្ចក់កាត់បន្ថយ |

| | | |
|---|---|---|
| | • ចំនួនអនុស្ថានីយបន្ថែម<br>• ប្រវែងខ្សែបណ្ដាញបញ្ជូនអគ្គិសនីបានសាងសង់។ | • ចំនួន<br>• ប្រវែង |
| សកម្មភាពទី ៤៖<br>ការសិក្សាហានិភ័យនៃការប្រែប្រួលអាកាសធាតុសម្រាប់ប្រព័ន្ធថាមពលនៅកម្ពុជាពេលអនាគត។ | • របាយការណ៍សិក្សាហានិភ័យនៃការប្រែប្រួលអាកាសធាតុរបស់ប្រព័ន្ធថាមពលនៅពេលអនាគត | • ចំនួនរបាយការណ៍ |
| សកម្មភាពទី ៥៖<br>បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យឧស្ម័នផ្ទះកញ្ចក់និងការប្រើប្រាស់ថាមពលថ្នាក់ជាតិសម្រាប់ការធ្វើសន្និធិឧស្ម័នផ្ទះកញ្ចក់និងតុល្យភាពថាមពល។ | • របាយការណ៍សន្និធិឧស្ម័នផ្ទះកញ្ចក់ត្រូវបានផ្សព្វផ្សាយ<br>• តារាងតុល្យភាពថាមពលត្រូវបានផ្សព្វផ្សាយ | • ចំនួនរបាយការណ៍និងតារាង |
| សកម្មភាពទី ៦៖<br>ផ្ដល់បច្ចេកវិទ្យាថាមពលស្អាតនិងបញ្ចេញកាបូនតិចទៅកាន់ភូមិនិងគ្រួសារដែលនៅដាច់ស្រយាលមិនទាន់មានអគ្គិសនីប្រើប្រាស់។ | • ចំនួនប្រព័ន្ធអគ្គិសនីខ្នាតតូចសម្រាប់ភូមិ<br>• សន្ទស្សន៍នៃខ្នងផ្ទះទទួលបានថាមពលប្រើប្រាស់នៅក្នុងភូមិ | • ចំនួន<br>• ភាគរយ |
| សកម្មភាព ៧៖<br>គម្រោងប្រសិទ្ធភាពថាមពលស្ថិតក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្ដីពីប្រសិទ្ធភាពថាមពល។ | • ចំនួនគម្រោងប្រសិទ្ធភាពថាមពល | • ចំនួន |
| សកម្មភាព ៨៖<br>គម្រោងស្លាកសញ្ញា និងស្តង់ដាប្រសិទ្ធភាពថាមពលស្ថិតក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្ដីពីប្រសិទ្ធភាពថាមពល ។ | • រៀបចំច្បាប់ គោលនយោបាយ បទប្បញ្ញត្តិ និងស្តង់ដាប្រសិទ្ធភាពថាមពលនិងកម្មវិធីស្លាកសញ្ញាប្រសិទ្ធភាពថាមពល<br>• ចំនួនផលិតផលដែលត្រូវបានបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល | • ចំនួន |
| សកម្មភាព ៩៖<br>ការសិក្សាបច្ចេកវិទ្យាថាមពលស្អាតនិងប្រកបដោយនិរន្តរភាពសម្រាប់ការចម្អិនអាហារនិងអនុវត្តជម្រើសដែលមានល្អបំផុត។ | • របាយការណ៍សិក្សាដែលបានផ្សព្វផ្សាយ<br>• គម្រោងថាមពល សម្រាប់ការចំអិនអាហារ | • ចំនួន |
| សកម្មភាព ១០៖<br>សិក្សាគំរូអាជីវកម្មប្រកបដោយនិរន្តរភាព ដើម្បីប្រើប្រាស់ថាមពលកម្ដៅនិងចំហាយទឹកប្រកបដោយប្រសិទ្ធភាពនិងស្អាតសម្រាប់គ្រប់វិស័យ។ | • រៀបចំគំរូអាជីវកម្មថាមពលកម្ដៅ និងចំហាយទឹកប្រកបដោយនិរន្តរភាព | • ចំនួនរបាយការណ៍ |
| សកម្មភាព ១១៖<br>បង្កើតកម្មវិធីគ្រប់គ្រងថាមពលសម្រាប់អគារធំៗ និងរោងចក្រធំៗ និងតាម | • រៀបចំកម្មវិធីសន្សំសំចៃថាមពលសម្រាប់ផ្នែកឧស្សាហកម្ម និងអគារធំៗ | • ចំនួន |

| | | |
|---|---|---|
| បែបគោលការណ៍ស្ម័គ្រចិត្តសម្រាប់សហគ្រាសធុនតូចនិងមធ្យម ស្ថិតក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ។ | | |
| សកម្មភាព ១២៖ រៀបចំកម្មវិធីពង្រឹងសមត្ថភាពវិស័យថាមពលកកើតឡើងវិញនិងប្រសិទ្ធភាពថាមពល។ | • កម្រិតសមត្ថភាពរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធមានភាពប្រសើរឡើងលើវិស័យថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល | • ប័ណ្ណពិន្ទុ (វិធីសាស្ត្រដណ្ដើរ) |
| សកម្មភាព ១៣៖ បង្កើនការយល់ដឹងជាសាធារណៈលើការសន្សំសំចៃថាមពល។ | • កម្មវិធីសម្រាប់ការយល់ដឹងជាសាធារណៈស្តីពីការសន្សំថាមពលត្រូវបានបង្កើត និងផ្សព្វផ្សាយ។<br>• កម្រិតនៃការយល់ដឹងអំពីការសន្សំថាមពលរបស់សាធារណជន | • ចំនួន<br>• ប័ណ្ណពិន្ទុ (វិធីសាស្ត្រដណ្ដើរ) |
| ៤. ផលជះ: | ១. ការយល់ដឹងជាសាធារណៈអំពីបញ្ហាការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល | ការស្ទង់មតិ |
| | ២. បញ្ជ្រាបបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ថាមពល | ចំនួន |
| | ៣. សន្ទស្សន៍នៃភាពងាយរងគ្រោះ | |
| | ៤. អាំងតង់ស៊ីតេកាបូនក្នុងវិស័យថាមពល | $CO_2$e/Btu |
| | | |

សូចនាករលទ្ធផលបន្ថែមសម្រាប់ការត្រួតពិនិត្យវឌ្ឍនភាព ក្នុងការអនុវត្តសកម្មភាពជាក់លាក់មានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធសកម្មភាពដែលមានបង្ហាញនៅក្នុងផ្នែកឧបសម្ព័ន្ធ។

ការត្រួតពិនិត្យ និងវាយតម្លៃចុងក្រោយនឹងត្រូវធ្វើឡើងនៅពាក់កណ្តាលឆ្នាំ២០២៣ ដើម្បីជូនដំណឹងអំពីការរៀបចំ ផ.ស.ប.អ.ថ. ជុំបន្ទាប់ ដែលការត្រួតពិនិត្យ និងវាយតម្លៃនេះ នឹងវាស់ស្ទង់អំពីវឌ្ឍនភាពក្នុងការអនុវត្ត ផ.ស.ប.អ.ថ. និងការចូលរួមចំណែកក្នុងការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យថាមពល ក៏ដូចជាអនុលោមភាព និងការចូលរួមចំណែកដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់នៅក្នុង ផ.យ.ប.អ.ក. ហើយក៏នឹងផ្តល់ជាអនុសាសន៍សម្រាប់ការកែតម្រូវគោលនយោបាយឆ្លើយតបនាពេលអនាគតផងដែរ។

អគ្គនាយកដ្ឋានថាមពល នៃក្រសួងរ៉ែ និងថាមពល នឹងទទួលខុសត្រូវសម្រាប់ការត្រួតពិនិត្យជាប្រចាំដោយរាយការណ៍ពីការអនុវត្ត ផ.ស.ប.អ.ថ. យ៉ាងហោចណាស់មានរបាយការណ៍តាមដាន និងវាយតម្លៃយ៉ាងតិចមួយក្នុងមួយឆ្នាំ។

## ៦. ផ.ស.ប.អ.ថ. និងយេនឌ័រ

ការប្រែប្រួលអាកាសធាតុជះឥទ្ធិពលដល់ជនជាតិភាគតិច យេនឌ័រ ជាពិសេសស្ត្រី និងក្មេងស្រី។ ក្នុងចំណោមវិស័យដទៃទៀត វិស័យដែលមានស្ត្រីដើរតួនាទីស្នូល រួមមានៈ សន្តិសុខស្បៀង អាហារូបត្ថម្ភ ថាមពល ការផ្គត់ផ្គង់ជីវភាពរស់នៅ សុខភាព ការគ្រប់គ្រងធនធានធម្មជាតិ គឺវិស័យដែលទទួលរងផលប៉ះពាល់ផ្ទាល់ពីការប្រែប្រួលអាកាសធាតុ។ តាមរយៈការធ្វើឱ្យមានគម្លាតសមភាពយេនឌ័រកាន់តែខ្លាំងជាងមុន ការប្រែប្រួលអាកាសធាតុក៏ជាបុព្វហេតុបង្កឱ្យមានអំពើហឹង្សាប្រឆាំងនឹងស្ត្រី និងក្មេងស្រីផងដែរ។ ចំពោះបញ្ហានេះ សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាអាទិភាព រួមមានការទទួលបានថាមពលស្អាតសម្រាប់ចម្អិនអាហារ និងការទទួលបានអគ្គិសនីប្រើប្រាស់ពីប្រភពស្អាត មានទំនាក់ទំនងទៅនឹងសមភាពយេនឌ័រ បរិយាបន្នសង្គម និងសក្តានុពលក្នុងការរួមចំណែកដល់សូចនាករផ្អែកលើយេនឌ័រមួយចំនួនថែមទៀតផង។ ផែនការសកម្មភាពទាក់ទងយេនឌ័រក្នុង ផ.ស.ប.អ. ក្នុងវិស័យថាមពល និងជាផែនការអាទិភាពរបស់ក្រសួង មានដូចជាៈ (១)ការទទួលបានថាមពលនៅតាមតំបន់ជនបទ និង (២) ការធ្វើពិពិធកម្មប្រភពថាមពលសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងសហគមន៍ ដើម្បីកាត់បន្ថយការពឹងផ្អែកលើជីវម៉ាសធ្វើជាប្រភពថាមពល។ ស្ត្រីជារឿយៗទទួលខុសត្រូវចំពោះការសម្រេចចិត្តទាក់ទងនឹងការប្រើប្រាស់ថាមពលនៅក្នុងគ្រួសារនៅតាមទីជនបទ ហើយស្ត្រីក្នុងគ្រួសារក្រីក្រ និងនៅក្នុងតំបន់ដាច់ស្រយាលច្រើនតែទទួលបានថាមពលក្រោយគេ។ សកម្មភាព និងសូចនាករកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលឆ្លើយតបតាមគោលការណ៍យេនឌ័រ នឹងជួយវាស់វែងការផ្លាស់ប្តូរទាំងនេះ ហើយក៏រួមចំណែកដល់ការវាស់ស្ទង់ភាពជោគជ័យនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៥ ការប្តេជ្ញាចិត្តរបស់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) និង ផ.យ.ប.អ.ក. ផងដែរ។

## ៧. តម្រូវការផ្នែកច្បាប់

ដើម្បីបំពេញតាមមុខងាររបស់ក្រសួងរ៉ែ និងថាមពល បទប្បញ្ញត្តិមួយចំនួនត្រូវបានបង្កើតឡើងដើម្បីជានាការនាំមុខ និងការគ្រប់គ្រងវិស័យថាមពលប្រកបដោយប្រសិទ្ធភាព ដែលបទប្បញ្ញត្តិក្នុងវិស័យទាំងនោះ រួមមានវិស័យៈ ប្រេងកាត ឧស្ម័នធម្មជាតិ និងអគ្គិសនីរបស់ប្រទេសកម្ពុជា។ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ច្បាប់ស្តីពីវិសោធនកម្មលើកទី១ លើមាត្រា៩ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ និងច្បាប់ស្តីពីវិសោធនកម្មលើកទី២ លើមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៦ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រ៧៤ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ មានគោលបំណងគ្រប់គ្រង និងផ្តល់ក្របខ័ណ្ឌសម្រាប់ការផ្គត់ផ្គង់ និងសេវាកម្មអគ្គិសនីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះមានវិសាលភាពលើរាល់សកម្មភាពនៃការផ្គត់ផ្គង់ ការផ្តល់សេវាកម្ម ការប្រើប្រាស់អគ្គិសនី និងសកម្មភាពផ្សេងទៀតលើវិស័យអគ្គិសនី។ មាត្រា៤ថ្មី នៃច្បាប់នេះ បានចែងថា ក្រសួងរ៉ែនិងថាមពល ត្រូវផ្តល់នូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ បង្កើនប្រសិទ្ធភាពក្នុងការផលិត ការបញ្ជូនចែកចាយអគ្គិសនី និង

ការប្រើប្រាស់អគ្គិសនី ព្រមទាំងសកម្មភាពដើម្បីបង្កើតកម្មវិធីសន្សំសំចៃអគ្គិសនីសម្រាប់ប្រទេសកម្ពុជា ក៏ដូចជាយុទ្ធសាស្ត្រដើម្បីធានាសន្តិសុខថាមពល។ មាត្រានេះគាំទ្រដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមរយៈការកែលម្អប្រសិទ្ធភាពថាមពលដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយ ផ.ស.ប.អ.ថ.។

បន្ថែមលើបទប្បញ្ញត្តិគាំទ្រដែលមានស្រាប់នេះ ការអនុវត្ត ផ.ស.ប.អ.ថ. អាចនឹងតម្រូវឱ្យមានការកែតម្រូវ និងការរៀបចំថ្មីនូវក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ និង/ឬ ការរៀបចំបទប្បញ្ញត្តិថ្មីដោយផ្អែកលើតម្រូវការជាក់ស្តែងពេលអនុវត្ត ។ ការបង្កើតបទប្បញ្ញត្តិដែលមានសក្តានុពលមួយទៀត គឺបទប្បញ្ញត្តិលើវិស័យថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ដើម្បីជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងសមធម៌ក្នុងការទទួលបានថាមពល។

## ៨. សេចក្តីសន្និដ្ឋាន

ក្រសួងរ៉ែ និងថាមពលវាយតម្លៃខ្ពស់ចំពោះផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពលឆ្នាំ ២០២១-២០២៣ ដែលជាមូលដ្ឋានសម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពល។ ផ្អែកលើយុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ខាងលើ យើងសម្រេចបានយុទ្ធសាស្ត្រ និងសកម្មភាពជាក់លាក់ដែលនឹងគាំទ្រដល់ការសម្រេចបាននូវផែនការយុទ្ធសាស្ត្រ ចក្ខុវិស័យ គោលដៅ និងបេសកកម្មនៃការងារប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពល។ យុទ្ធសាស្ត្រទាំងនេះ ក៏បង្ហាញពីសារៈសំខាន់នៃវិធីសាស្ត្របីវិមាត្រដើម្បីផ្តល់អត្ថប្រយោជន៍ដល់សង្គម សេដ្ឋកិច្ច និងបរិស្ថានទាំងមូលផងដែរ ។

នៅចុងបញ្ចប់នៃរយៈពេលអនុវត្ត ការវាយតម្លៃនៃការអនុវត្តនឹងត្រូវបានធ្វើឡើងដើម្បីដកស្រង់មេរៀនពីបទពិសោធន៍ និងដើម្បីកំណត់ចំណុចអន្តរាគមន៍ថ្មីនៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យថាមពលនាពេលអនាគត។

## ឧបសម្ព័ន្ធ៖ ឯកសារសកម្មភាពប្រែប្រួលអាកាសធាតុ

១) ឯកសារសកម្មភាពលេខ ១៖

| | |
|---|---|
| សកម្មភាព | រៀបចំផែនការមេអភិវឌ្ឍន៍វិស័យអគ្គិសនីនៅកម្ពុជាឡើងវិញ។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | - ផ.យ.ប.អ.ក.០១៖ លើកកម្ពស់ភាពធន់នឹងអាកាសធាតុតាមរយៈការកែលម្អសន្តិសុខស្បៀង ទឹក និងថាមពល<br>- ផ.យ.ប.អ.ឧ.ថ. ០១៖ អភិវឌ្ឍគោលនយោបាយវិស័យថាមពលមួយដែលមានគោលដៅឆ្ពោះទៅរកថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា (SEforALL) ដោយធានាបាននូវគោលដៅគន្លឹះរបស់វិស័យថាមពលបច្ចុប្បន្ន គឺការផ្គត់ផ្គង់ប្រភពថាមពលឱ្យបានគ្រប់គ្រាន់ អាចទុកចិត្តបាន និងមានថ្លៃសមរម្យអាចប្រកួតប្រជែងជាមួយប្រទេសជិតខាងបាន។ |
| សនិទានភាព | គោលបំណងរួមនៃគម្រោង គឺការធ្វើវិវេចនាផែនការមេនៃការអភិវឌ្ឍវិស័យថាមពលដែលមានស្រាប់នៅប្រទេសកម្ពុជា និងធ្វើបច្ចុប្បន្នភាពផែនការថ្មីមួយ ព្រមទាំងរៀបចំវិធីសាស្ត្រព្យាករណ៍តម្រូវការថាមពលអគ្គិសនី ផែនការអភិវឌ្ឍន៍ប្រភពផ្គត់ផ្គង់អគ្គិសនី និងផែនការអភិវឌ្ឍន៍ បណ្តាញបញ្ជូនអគ្គិសនី។ ផែនការមេនៃការអភិវឌ្ឍវិស័យថាមពលនៅកម្ពុជា គឺជាផែនទីបង្ហាញផ្លូវគន្លឹះសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យថាមពល ដើម្បីផែនការឆ្ពោះទៅរកការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយដែលមានលក្ខណៈ គ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទនៅគ្រប់ទីកន្លែង ទូទាំងព្រះរាជាណាចក្រកម្ពុជា។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☑ Cat 2 –កែលម្អ ☐Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាព លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍ | **ការពិពណ៌នាសង្ខេប៖** ក្រសួងរ៉ែ និងថាមពលបានដឹកនាំ និងសហការជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីរៀបចំ និងអភិវឌ្ឍផែនការមេអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅកម្ពុជាឱ្យបានត្រឹមត្រូវ និងសុក្រឹតភាពជូនរាជរដ្ឋាភិបាលកម្ពុជា។ ការរៀបចំបច្ចុប្បន្នភាពផែនការមេនេះ បានបែងចែកជា ៣ ដំណាក់កាលសំខាន់ៗដូចខាងក្រោម៖<br>*ដំណាក់កាលទី ១៖* ការព្យាករសេចក្តីត្រូវការអគ្គិសនីឆ្នាំ២០២០-២០៤០ លើមូលដ្ឋាននៃការពិនិត្យ៖ ១)-កំណើននៃសេចក្តីត្រូវការអគ្គិសនីជាក់ស្តែង ២)-ផលប៉ះពាល់បញ្ហាជាសកលជំងឺឆ្លងកូវីដ-១៩ ដល់ការប្រើប្រាស់ថាមពលអគ្គិសនី និងសេដ្ឋកិច្ចនៅកម្ពុជា និង៣)-កំណើននៃសំណង់ធំៗ |

| | |
|---|---|
| | ដែលកំពុងកើនឡើងនៅកម្ពុជា។ ការព្យាករនៃសេចក្ដីត្រូវការអគ្គិសនីនេះបានរៀបចំជា ០៣ ជម្រើស៖ ១-ជម្រើសកំណើនតាមកម្រិតធម្មតា (Business As Usual = BAU) ២-ជម្រើសកំណើនកម្រិតខ្ពស់ (High Case) និង៣-ជម្រើសកំណើនកម្រិតទាប (Low Case)។<br>*ដំណាក់កាលទី ២៖* ផែនការអភិវឌ្ឍន៍ប្រភពផ្គត់ផ្គង់អគ្គិសនីដោយផ្អែកលើមូលដ្ឋាននៃការពិនិត្យទៅលើ៖<br>- ដោយបង្ហាញបរិមាណថាមពលផលិតនិងអានុភាពនៃប្រភពថាមពលដែលមានចែកជា២រដូវ ក្នុងឆ្នាំនីមួយៗ។ ការកំណត់ពេលវេលាដាក់ឱ្យដំណើរការ (COD) នៃគម្រោងប្រភពអគ្គិសនីនីមួយៗ<br>- ការកំណត់កម្រិតថាមពលបម្រុងទុក (Reserve Margin) នៃប្រភពផ្គត់ផ្គង់អគ្គិសនីដោយផ្អែកលើ៖ ១-ការប្រែប្រួលតម្រូវការប្រើប្រាស់អគ្គិសនី ក្នុងនោះការប្រែប្រួល GDP និងការប្រែប្រួលអាកាសធាតុ និង ២-ការប្រែប្រួលការផ្គត់ផ្គង់ថាមពលអគ្គិសនី ក្នុងនោះការដាច់ចរន្តអគ្គិសនីពីរោងចក្រអគ្គិសនី និងបម្រែបម្រួលទឹក<br>- ការកំណត់លក្ខណៈ និងលក្ខខណ្ឌនៃការជ្រើសរើសគម្រោងប្រភពថាមពលណាមួយ ដោយផ្អែកលើ ១-មេគុណថាមពលរវាងរដូវប្រាំង និងរដូវវស្សា ២-ថ្លៃអគ្គិសនីទាប ៣-ការផ្ដល់អានុភាព និងបរិមាណថាមពលផលិតបាននៃសក្ដានុពលប្រភពថាមពលនីមួយៗ និង ៤-ផលប៉ះពាល់បរិស្ថាន និងសង្គមមានកម្រិតអប្បបរមា<br>*ដំណាក់កាលទី ៣៖* ផែនការអភិវឌ្ឍបណ្ដាញបញ្ជូនអគ្គិសនី៖<br>- សិក្សា និងវិភាគលំហូរអានុភាពនៃប្រព័ន្ធបណ្ដាញបញ្ជូនអគ្គិសនី ការកំណត់លក្ខណៈ និងលក្ខខណ្ឌនៃការជ្រើសរើសគម្រោងខ្សែបណ្ដាញបញ្ជូនអគ្គិសនី ដើម្បីជានាប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីឱ្យមានគុណភាព ស្ថិរភាព សន្តិសុខ និងថ្លៃសមរម្យ<br>- សិក្សាជម្រើសនៃការនាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាង និងប្រទេសក្នុងតំបន់អាស៊ាន<br>- ការវាយតម្លៃលទ្ធផលនៃផែនការបណ្ដាញបញ្ជូន ដោយប្រើប្រាស់កម្មវិធីកុំព្យូទ័រព្រមទាំងការបណ្ដុះបណ្ដាល។<br>**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**<br>-របាយការណ៍ការព្យាករតម្រូវការថាមពលអគ្គិសនី រួមមានផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និងលំនៅឋានឱ្យស្របតាមកំណើននៃការប្រើប្រាស់អគ្គិសនី និងសេដ្ឋកិច្ច |

| | |
|---|---|
| | - ផែនការអភិវឌ្ឍន៍ប្រភពផ្គត់ផ្គង់អគ្គិសនី រួមមាន ១-អភិវឌ្ឍន៍ប្រភពផ្គត់ផ្គង់អគ្គិសនីដែលមានប្រសិទ្ធភាពផ្នែកបច្ចេកទេស និងសេដ្ឋកិច្ច ២-ការធ្វើពាណិជ្ជកម្មប្រភពអគ្គិសនីពីប្រទេសជិតខាង និងតំបន់អាស៊ាន និង ៣-រៀបចំបង្គុំប្រភពអគ្គិសនីផ្សេងៗដើម្បីជួយគ្នាទៅវិញទៅមក និងឱ្យមានតម្លៃក្នុងកម្រិតមធ្យមនៅក្នុងប្រព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនី<br>- ផែនការអភិវឌ្ឍន៍បណ្ដាញបញ្ជូនអគ្គិសនី រួមមាន ១-អភិវឌ្ឍន៍ប្រភពអគ្គិសនីដែលមានសក្ដានុពលនៅទីតាំងផ្សេងៗ ដើម្បីភ្ជាប់បញ្ចូលទៅក្នុងប្រព័ន្ធបណ្ដាញជាតិបញ្ជូនអគ្គិសនី ២-គ្រប់គ្រង និងទទួលយកប្រភពអគ្គិសនីផ្សេងៗតាមពេលវេលា និងដូរកាលមកបញ្ចូលគ្នា ដើម្បីឱ្យស្របតាមទំហំនៃសេចក្ដីត្រូវការប្រើប្រាស់តាមពេលនីមួយៗ និង ៣-បំប្លែង និងបញ្ជូនប្រភពអគ្គិសនីទៅឱ្យរាជធានី-ខេត្ត និងតំបន់នានាតាមរយៈអនុស្ថានីយ ដើម្បីផ្គត់ផ្គង់អគ្គិសនីបន្តទៅអ្នកប្រើប្រាស់<br>- កម្រិតសន្ទុស្សន៍នៃបរិមាណថាមពលកកើតឡើងវិញ នៅក្នុងល្បាយនៃប្រភពផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងស្រុក។ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | ផែនការមេអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនី គឺជាឯកសារសំខាន់មួយមានវិសាលភាព ដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យថាមពលនៅកម្ពុជាដើម្បីចៀសវាងការដាច់ចរន្តអគ្គិសនី ការវិនិយោគដែលមិនចាំបាច់ និងធ្វើឱ្យការងារដំណើរការមានប្រសិទ្ធភាព និងចំណាយតិច ដោយការវាយតម្លៃតម្រូវការថាមពលអគ្គិសនីនាពេលអនាគត តាមរយៈសេណារីយ៉ូនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បច្ចេកវិទ្យា និងប្រជាសាស្ត្រ រយៈពេលមធ្យម និងរយៈពេលវែង។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - ការប្ដេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំ<br>- ការរៀបចំប្រមូល និងចងក្រងទិន្នន័យថាមពល<br>- សមត្ថភាពមន្ត្រីក្រសួង និងមន្ត្រីជំនាញក្នុងការព្យាករតម្រូវការថាមពលក្នុងសេណារីយ៉ូនីមួយៗ<br>- កម្រិតកិច្ចសហប្រតិបត្តិការពីស្ថាប័នពាក់ព័ន្ធផ្សេងៗ<br>- ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសទាន់ពេលវេលា។ |
| សូចនាករនៃភាពជោគជ័យ | - បច្ចុប្បន្នភាពផែនការមេអភិវឌ្ឍន៍វិស័យថាមពលត្រូវអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា |
| ការរៀបចំការអនុវត្ត | អគ្គនាយកដ្ឋានថាមពលនៃក្រសួងរ៉ែ និងថាមពលសហការជាមួយភាគីពាក់ព័ន្ធផ្សេងទៀតដូចជាអគ្គិសនីកម្ពុជា និងអាជ្ញាធរអគ្គិសនីជាដើម។ |
| ចំណាយប៉ាន់ស្មានសរុប | ២ ៣៤០ ៤០០ ដុល្លារ |
| ប្រភពមូលនិធិ | ADB និង ថវិកាជាតិ |
| រយៈពេល | ២០១៩-២០២១ |

២) ឯកសារសកម្មភាពលេខ ២៖

| | |
|---|---|
| សកម្មភាព | រៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | - ផ.យ.ប.អ.ក. ០១៖ លើកកម្ពស់ភាពធន់នឹងអាកាសធាតុតាមរយៈការកែលម្អសន្តិសុខស្បៀង ទឹក និងថាមពល<br>- ផ.យ.ប.អ.ឱ.ថ. ០១៖ អភិវឌ្ឍគោលនយោបាយវិស័យថាមពលមួយ ដែលមានគោលដៅឆ្ពោះទៅរកថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា (SEforALL) ដោយធានាឱ្យសម្រេចបាននូវគោលដៅគន្លឹះរបស់វិស័យថាមពលបច្ចុប្បន្ន គឺការផ្គត់ផ្គង់ប្រភពថាមពលឱ្យបានគ្រប់គ្រាន់ អាចទុកចិត្តបាន និងមានថ្លៃសមរម្យអាចប្រកួតប្រជែងបានជាមួយប្រទេសជិតខាង។ |
| សនិទានភាព | នៅប្រទេសកម្ពុជា គោលនយោបាយ និងសកម្មភាពប្រសិទ្ធភាពថាមពល ត្រូវបានធ្វើសេចក្តីព្រាងនៅក្នុងឆ្នាំ២០១៣ ជាមួយនឹងការគាំទ្រពី EU-EIPDF និងត្រូវបានកែសម្រួលឡើងវិញនៅឆ្នាំ២០១៧ ដោយមានការគាំទ្រពីជីអាយហ្សិត (GIZ)។ ការបង្កើតគោលនយោបាយនេះ ផ្អែកលើទិន្នន័យចាស់ ចាប់ពីឆ្នាំ ២០១០ មកម្ល៉េះ។ នៅក្នុង ខែវិច្ឆិកា ឆ្នាំ២០១៥ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានអនុម័តគម្រោងជំនួយបច្ចេកទេសអភិវឌ្ឍន៍សមត្ថភាព ក្នុងមហាអនុតំបន់ទន្លេមេគង្គ ដើម្បីគាំទ្រការអភិវឌ្ឍវិស័យអគ្គិសនីប្រកបដោយចីរភាព ប្រសិទ្ធភាពសេដ្ឋកិច្ច និងបន្ថយការប៉ះពាល់បរិស្ថាន-សង្គម និងដើម្បីចូលរួមសកម្មភាពការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងអនុតំបន់ទន្លេមេគង្គនេះ។ ក្នុងក្របខ័ណ្ឌជំនួយបច្ចេកទេស (TA) របស់ធនាគារអភិវឌ្ឍន៍អាស៊ី គម្រោងប្រសិទ្ធភាពថាមពលនេះ មានការសហការចូលរួមពីប្រទេសចំនួន ០៣ គឺ ប្រទេសកម្ពុជា ភូមា និងឡាវ ជាសមាជិកនៃប្រទេសនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលមានក្រសួងចំនួន ០៣ ជាតំណាងឱ្យរដ្ឋាភិបាលនៃប្រទេសនីមួយៗចូលរួម អនុវត្តក្នុងគម្រោងនេះ ដូចជា ១-ក្រសួងរ៉ែ និងថាមពល ជាតំណាងឱ្យប្រទេសកម្ពុជា ២-ក្រសួងថាមពល និងរ៉ែ ជាតំណាងឱ្យប្រទេសឡាវ និង៣-ក្រសួងឧស្សាហកម្ម ជាតំណាងឱ្យប្រទេសមីយ៉ាន់ម៉ា។ ដោយឡែកសម្រាប់ប្រទេសកម្ពុជាយើង ក្រសួងរ៉ែនិងថាមពល បាននិងកំពុងសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីរៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ហើយគ្រោងបញ្ចប់នៅឆ្នាំ២០២១។ គោលបំណងនៃគម្រោងនេះ គឺការសិក្សាវាយតម្លៃទីផ្សារប្រសិទ្ធភាពថាមពល និងការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងយន្តការនៃការអនុវត្តកម្មវិធីសកម្មភាពប្រសិទ្ធភាពថាមពល និងការសន្សំសំចៃថាមពល ព្រមទាំងរៀបចំស្តង់ដា បទប្បញ្ញត្តិ វិធានការគ្រប់គ្រងការប្រើប្រាស់អគ្គិសនី និងការបណ្តុះបណ្តាលធនធានមនុស្ស។ |

| | |
|---|---|
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☑Cat 2 –កែលម្អ ☐Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាព និងលទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍ | **ការពិព័ណ៌នាសង្ខេប៖**<br>ដើម្បីរៀបចំបច្ចុប្បន្នភាពគោលនយោបាយប្រសិទ្ធភាពថាមពល សកម្មភាពសំខាន់មួយចំនួនដែលត្រូវអនុវត្តមានដូចខាងក្រោម៖<br>- បង្កើតគណៈកម្មការអន្តរស្ថាប័ន និងក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពិនិត្យ និងកែសម្រួលខ្លឹមសារនៃសេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។<br>- រៀបចំប្រមូល-ចងក្រង និងវិភាគ ព័ត៌មានទិន្នន័យការប្រើប្រាស់ថាមពល ផ្នែកបំភ្លឺសាធារណៈ លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម និងដឹកជញ្ជូន។ ល។<br>- រៀបចំផែនការយុទ្ធសាស្រ្ត គោលនយោបាយ ផែនការសកម្មភាព កម្មវិធី និងយន្តការគ្រប់គ្រង តាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពថាមពលនៅកម្ពុជា ដើម្បីវិភាគ និងដោះស្រាយបញ្ហាប្រកបដោយនិរន្តរភាព<br>**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**<br>- សម្រេចបានផែនការយុទ្ធសាស្រ្ត គោលនយោបាយ និងផែនការសកម្មភាព ដើម្បីដឹកនាំការអភិវឌ្ឍប្រសិទ្ធភាពថាមពល សម្រាប់ក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងៗ<br>- បង្កើនការយល់ដឹង និងការខិតខំលើការលើកកម្ពស់ប្រសិទ្ធភាពថាមពល<br>- ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការពង្រឹងសន្តិសុខថាមពល |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | គម្រោងគោលនយោបាយ និងកម្មវិធីប្រសិទ្ធភាពថាមពល បានផ្តល់អត្ថប្រយោជន៍ និងរួមចំណែកដល់ការសម្រេចបាននូវគោលដៅប្រសិទ្ធភាពថាមពល ដែលមានផលប៉ះពាល់ជាវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គម រួមទាំងកំណើនផលិតផលក្នុងស្រុកសរុប និងកំណើនការងារផងដែរ។<br>អត្ថប្រយោជន៍ដែលបានកំណត់គោលដៅ រួមមានការសន្សំសំចៃថាមពល ការកែលម្អគុណភាពខ្យល់ អត្ថប្រយោជន៍បន្ថែមផ្សេងៗទៀត បូករួមទាំងអត្ថប្រយោជន៍កាត់បន្ថយកាបូន និងអត្ថប្រយោជន៍សុខភាពផងដែរ។ ចំពោះកំណើនសកម្មភាព ឬចំនួនការងារ គឺកើតចេញពីការបង្កើតគោលនយោបាយនេះ ច្រើនមានលក្ខណៈជាការងារបែប "គាំទ្រ" ជាជាងការផ្លាស់ប្តូរកំណើនសកម្មភាព ឬបរិមាណបានការងារថ្មីទាំងស្រុង។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការ | - ការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំ<br>- ក្របខ័ណ្ឌច្បាប់ និងការរៀបចំស្ថាប័នចាំបាច់ត្រូវកែលម្អ |

| | |
|---|---|
| អនុវត្តប្រកបដោយជោគជ័យ | - សមត្ថភាពមន្ត្រីក្រសួង និងអ្នកជំនាញក្នុងការសិក្សាការប្រើប្រាស់ថាមពលក្នុងសេណារីយ៉ូផ្សេងៗ ដើម្បីកាត់បន្ថយអាំងតង់ស៊ីតេថាមពល<br>- កម្រិតកិច្ចសហប្រតិបត្តិការពីស្ថាប័នពាក់ព័ន្ធផ្សេងៗ<br>- ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសទាន់ពេលវេលា។ |
| សូចនាករនៃភាពជោគជ័យ | - វឌ្ឍនភាពនៃគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព<br>- ចំនួនសិក្ខាសាលាផ្សព្វផ្សាយដែលបានរៀបចំ និងបង្កើតឡើង។ |
| ការរៀបចំការអនុវត្ត | អគ្គនាយកដ្ឋានថាមពលនៃក្រសួងរ៉ែ និងថាមពល សហការជាមួយអគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ |
| ចំណាយប៉ាន់ស្មានសរុប | ១ ៩៣៤ ២៧ ដុល្លារ |
| ប្រភពមូលនិធិ | ADB និងថវិកាជាតិ |
| រយៈពេល | ២០២០-២០២៣ |

៣) ឯកសារសកម្មភាពលេខ ៣៖

| | |
|---|---|
| សកម្មភាព | រៀបចំពង្រឹងសមត្ថភាព និងស្ថិរភាពអនុស្ថានីយ និងខ្សែបណ្តាញបញ្ជូនអគ្គិសនី។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | - ផ.យ.ប.អ.ក. ០២៖ កាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យសុខភាពតាមតំបន់ និងតាមវិស័យ រាប់ទាំងវិស័យយែនឌ័រ ចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ<br>- ផ.យ.ប.អ.ឧ.ថ. ០២៖ ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យថាមពលឱ្យមានលក្ខណៈស៊ាំ ឬធន់នឹងការប្រែប្រួលអាកាសធាតុ |
| សនិទានភាព | ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានផ្តល់កម្ចីឥណទាន និងជំនួយឥតសំណងជូនអគ្គិសនីកម្ពុជា សម្រាប់ការរៀបចំពង្រឹងសមត្ថភាពអនុស្ថានីយ និងខ្សែបណ្តាញបញ្ជូនអគ្គិសនី (Grid Reinforcement Project) នៅភ្នំពេញ ខេត្តកំពង់ចាម កំពង់ឆ្នាំង និងតាកែវ និងការដំឡើងប្រព័ន្ធស្តុកថាមពលអគ្គិសនីដោយប្រើប្រាស់អាគុយ (BESS) នៅអនុស្ថានីយ National Solar Park ដែលមានទំហំការងារ៖<br>១-គម្រោងពង្រឹងសមត្ថភាពប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី (Grid Reinforcement Project)<br>២-សាងសង់អនុស្ថានីយ និងខ្សែបញ្ជូនអគ្គិសនីនៅភ្នំពេញ<br>៣-សាងសង់អនុស្ថានីយ និងខ្សែបញ្ជូនអគ្គិសនីនៅខេត្តកំពង់ឆ្នាំង កំពង់ចាម និងតាកែវ<br>៤-ដំឡើងប្រព័ន្ធស្តុកថាមពលអគ្គិសនីដោយប្រើប្រាស់អាគុយ (BESS) ទំហំ 16 MWh នៅអនុស្ថានីយ National Solar Park នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☑Cat 2 –កែលម្អ ☐Cat 3 – ថ្មី |

| | |
|---|---|
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាព និងលទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍ | **ការពិពណ៌នាសង្ខេប៖**<br>ដើម្បីរៀបចំពង្រឹងសមត្ថភាពអនុស្ថានីយ និងខ្សែបណ្ដាញបញ្ជូនអគ្គិសនី សកម្មភាពសំខាន់ៗមួយចំនួនដែលត្រូវអនុវត្តមានដូចខាងក្រោម៖<br>- រៀបចំនីតិវិធីស្នើសុំកម្ចីឥណទានសម្រាប់គម្រោងពង្រឹងសមត្ថភាពប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី នៅភ្នំពេញ ខេត្តកំពង់ចាម កំពង់ឆ្នាំង និងតាកែវ និងជំនួយឥតសំណងសម្រាប់ការដំឡើងប្រព័ន្ធស្តុកថាមពលអគ្គិសនីដោយប្រើប្រាស់អាគុយ (BESS) នៅអនុស្ថានីយផលិតថាមពលដោយពន្លឺព្រះអាទិត្យ<br>- រៀបចំនីតិវិធីលទ្ធកម្មជ្រើសរើសទីប្រឹក្សាអនុវត្តគម្រោង (PIC) និងជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់ និងសាងសង់ (EPC)<br>- ការសិក្សាអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោង<br>- រៀបចំនីតិវិធីកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និង ADB<br>**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**<br>- ពង្រឹងសមត្ថភាព និង ស្ថិរភាពនៃប្រព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនីនៅកម្ពុជា<br>- បង្កើនការយល់ដឹង និងការខិតខំលើការលើកកម្ពស់ប្រសិទ្ធភាពថាមពល<br>- ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការពង្រឹងសន្តិសុខថាមពល<br>- ពង្រឹងសមត្ថភាពបន្សាំរបស់ប្រព័ន្ធថាមពលទៅនឹងការប្រែប្រួលអាកាសធាតុ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | គម្រោងនេះបានផ្តល់អត្ថប្រយោជន៍ និងរួមចំណែកដល់ការសម្រេចបាននូវគោលដៅប្រសិទ្ធភាពថាមពល រួមមានការរក្សាស្ថិរភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនី ការកែលម្អគុណភាពខ្សែបណ្ដាញបញ្ជូនអគ្គិសនី និងអត្ថប្រយោជន៍បន្ថែមផ្សេងៗទៀត បូករួមទាំងអត្ថប្រយោជន៍សន្សំកាបូន និងការពង្រឹងសន្តិសុខថាមពល។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - សមត្ថភាពមន្ត្រី និងអ្នកជំនាញក្នុងការសិក្សាគម្រោង<br>- កម្រិតកិច្ចសហប្រតិបត្តិការពីស្ថាប័នពាក់ព័ន្ធផ្សេងៗ<br>- ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសទាន់ពេលវេលា |
| សូចនាករនៃភាពជោគជ័យ | - សន្ទស្សន៍នៃថាមពលកកើតឡើងវិញនៅក្នុងល្បាយផលិតកម្មថាមពល<br>- បរិមាណឧស្ម័នផ្ទះកញ្ចក់បានកាត់បន្ថយ<br>- ចំនួនអនុស្ថានីយបន្ថែម<br>- ប្រវែងខ្សែបណ្ដាញបញ្ជូនអគ្គិសនីបានសាងសង់។ |

| | |
|---|---|
| ការរៀបចំការអនុវត្ត | អគ្គិសនីកម្ពុជាសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត |
| ចំណាយប៉ាន់ស្មានសរុប | ១៩៣ ៦៩០ ០០០ ដុល្លារ |
| ប្រភពមូលនិធិ | ADB និងថវិកាជាតិ |
| រយៈពេល | ២០២១-២០២៣ |

៤) ឯកសារសកម្មភាពលេខ ៤៖

| | |
|---|---|
| សកម្មភាព | រៀបចំសិក្សាហានិភ័យអាកាសធាតុសម្រាប់ប្រព័ន្ធថាមពលនៅកម្ពុជា និងផ្តល់អនុសាសន៍សម្រាប់ការអនុវត្តនាពេលអនាគត។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | - ផ.យ.ប.អ.ក. ០២៖ កាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យសុខភាពតាមតំបន់ និងតាមវិស័យ រាប់ទាំងវិស័យយេនឌ័រចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ<br>- ផ.យ.ប.អ.ឧ.ថ. ០២៖ ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យថាមពលឱ្យមានលក្ខណៈស៊ាំ ឬធន់នឹងការប្រែប្រួលអាកាសធាតុ។ |
| សនិទានភាព | ដោយសារហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីមានតម្លៃថ្លៃ និងតម្រូវការថាមពលអគ្គិសនីចេះតែកើនឡើងនៅក្នុងប្រទេសកម្ពុ ធ្វើឱ្យការវាយតម្លៃហានិភ័យ និងការកំណត់វិធានការការពារនានានឹងចូលរួមចំណែកដល់ការសម្រេចបាននូវគោលនយោបាយសន្តិសុខថាមពលរបស់រាជរដ្ឋាភិបាល។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☐Cat 2 –កែលម្អ ☑Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការបន្សុាំ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាពនិងលទ្ធផលរំពឹងទុកនិងអត្ថប្រយោជន៍ | **ការពិពណ៌នាសង្ខេប៖**<br>- វាយតម្លៃហានិភ័យនៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ជាពិសេសតំបន់ដែលមានទីតាំងស្ថិតនៅចំតំបន់ងាយរងគ្រោះដោយអាកាសធាតុ និងផ្តល់ជាអនុសាសន៍គោលនយោបាយ និងវិធានការសមស្រប<br>- កសាងសមត្ថភាពលើនីតិវិធីត្រួតពិនិត្យ សំដៅកាត់បន្ថយហានិភ័យអាកាសធាតុលើហេដ្ឋារចនាសម្ព័ន្ធ និងធ្វើអធិការកិច្ចតាមទីតាំងងាយរងគ្រោះដោយអាកាសធាតុ<br>- រៀបចំគោលការណ៍ណែនាំថ្នាក់ជាតិស្តីពី ការបញ្ជាក់ពីអាកាសធាតុនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី<br>- ផ្សព្វផ្សាយលទ្ធផលវាយតម្លៃ និងគោលការណ៍ណែនាំដល់ម្ចាស់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី និងអ្នកពាក់ព័ន្ធ។ |

| | |
|---|---|
| | **លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**<br>ផែនទីបង្ហាញផ្លូវដល់ការសេចក្តីសម្រេចចិត្តគោលនយោបាយ ក៏ដូចជាវិនិយោគិនឱ្យមានការយល់ដឹងកាន់តែច្បាស់ អំពីកម្រិតហានិភ័យអាកាសធាតុលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ហើយនឹងអាចអនុវត្តវិធានការដើម្បីដោះស្រាយហានិភ័យទាំងនោះបាន(ចំណុចនេះក៏រួមចំណែកដល់ការធ្វើផែនការ និងរចនាហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរឡើងនាពេលអនាគតថែមទៀតផង)។ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | ការវិភាគហានិភ័យអាកាសធាតុ នឹងផ្តល់នូវផលប៉ះពាល់ជាសក្តានុពលជាទូទៅនៃការប្រែប្រួលអាកាសធាតុលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដែលអាចត្រូវបានប្រែទៅជាវិធានការការពារ ហើយចេញពីចំណុចនេះ យើងអាចកាត់បន្ថយថ្លៃវិនិយោគបាន។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - សកម្មភាពនេះពឹងផ្អែកលើលទ្ធផលពីការវាយតម្លៃភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុជាតិ។<br>- សមត្ថភាពមន្ត្រីក្រសួងរ៉ែ និងថាមពល អគ្គិសនីកម្ពុជា និងសេវាករអគ្គិសនីជនបទដើម្បីយល់ដឹងពីហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដែលអាចកើតមានលើហេដ្ឋារចនាសម្ព័ន្ធ គឺចាំបាច់ដើម្បីអនុវត្តសកម្មភាពឱ្យបានជោគជ័យ។<br>- កិច្ចសហប្រតិបត្តិការជាមួយម្ចាស់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ត្រូវការជាចាំបាច់ដើម្បីធ្វើការវាយតម្លៃ។ |
| សូចនាករនៃភាពជោគជ័យ | - ចំនួនហេដ្ឋារចនាសម្ព័ន្ធដែលបានវាយតម្លៃ<br>- កម្រិតនៃការអនុវត្តអនុសាសន៍វាយតម្លៃហានិភ័យ<br>- កម្រិតនៃការផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីភ័ស្តុតាងអាកាសធាតុលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី |
| ការរៀបចំការអនុវត្ត | អគ្គនាយកដ្ឋានថាមពល នៃក្រសួងរ៉ែ និងថាមពល ដោយមានការសហការជាមួយក្រសួងបរិស្ថាន អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា និងអាជីវកម្មអគ្គិសនីព្រមទាំងដៃគូអភិវឌ្ឍន៍ដទៃទៀត។ |
| ចំណាយប៉ាន់ស្មានសរុប | ៣២២ ០០០ ដុល្លារ |
| ប្រភពមូលនិធិ | CCCA, ADB, AFD, CHINA AID, KOICA and JICA |
| រយៈពេល | ២០២១ – ២០២៣ |

៥) ឯកសារសកម្មភាពលេខ ៥៖

| | |
|---|---|
| សកម្មភាព | បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យឧស្ម័នផ្ទះកញ្ចក់និងការប្រើប្រាស់ថាមពលថ្នាក់ជាតិសម្រាប់ការធ្វើសន្និធិឧស្ម័នផ្ទះកញ្ចក់និងតុល្យភាពថាមពល |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | - ផ.យ.ប.អ.ក. ០៤៖ លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព<br>- ផ.យ.ប.អ.ឧ.ថ. ០៣៖ អនុវត្តវិធីសាស្ត្រគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល។ |
| សនិទានភាព | ក្នុងនាមជាភាគីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ ប្រទេសកម្ពុជាមានកាតព្វកិច្ចរាយការណ៍អំពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន។ ការបង្កើតសន្និធិឧស្ម័នផ្ទះកញ្ចក់ គឺជាជំហានដំបូងចាំបាច់ដើម្បីរាយការណ៍អំពីឧស្ម័នផ្ទះកញ្ចក់ និងការគ្រប់គ្រងការបញ្ចេញឧស្ម័ន។ សន្និធិឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យថាមពលក៏ជាធាតុចូលមួយនៃរបាយការណ៍ជាតិដែលតម្រូវដោយអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងជាផ្នែកមួយនៃការធ្វើតុល្យភាពថាមពលផងដែរ ។ សកម្មភាពនេះ ត្រូវបានបង្កើតឡើងដើម្បីបង្កើតប្រព័ន្ធសន្និធិឧស្ម័នផ្ទះកញ្ចក់ សម្រាប់វិស័យថាមពល (ប្រភពចំហេះ និងប្រភពចល័ត)និងសម្រាប់កំណត់ឱកាសកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☑Cat 2 –កែលម្អ ☐ Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាព និងលទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍ | - អភិវឌ្ឍសមត្ថភាពរបស់អគ្គនាយកដ្ឋានថាមពល ដើម្បីរៀបចំ និងបង្កើតប្រព័ន្ធសន្និធិឧស្ម័នផ្ទះកញ្ចក់ (រួមទាំងនីតិវិធីប្រមូលទិន្នន័យ និងពិធីសារការធានាគុណភាព ។ល។)<br>- ផ្តល់ការបណ្តុះបណ្តាលការងារលើគោលការណ៍ណែនាំ IPCC ២០០៦ សម្រាប់សន្និធិឧស្ម័នផ្ទះកញ្ចក់<br>- កំណត់ផ្នែករឹងនិងផ្នែកទន់ និងយកវាមកប្រើ (រួមទាំងការបណ្តុះបណ្តាលលើការប្រើប្រាស់សូហ្វែរ)<br>- អនុវត្តការប្រមូលទិន្នន័យសន្និធិ (ការរួមបញ្ចូលគ្នាដោយស្ថានីយ និងប្រភពចល័ត) រួមទាំងការកែលម្អការចងក្រងទិន្នន័យ កង្វះទិន្នន័យ និងការវិភាគទិន្នន័យ<br>- ធ្វើការសិក្សាដើម្បីបង្កើតកត្តាបញ្ចេញឧស្ម័នសម្រាប់វិស័យថាមពល។<br>- កំណត់ជម្រើសហិរញ្ញប្បទានដែលចាំបាច់សម្រាប់ការធានានិរន្តរភាពនៃសកម្មភាព<br>- សន្និធិថាមពល និង ឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល |

| | |
|---|---|
| | - -ចែករំលែកព័ត៌មានតាមរយៈសិក្ខាសាលា ដើម្បីចូលរួមជាមួយក្រសួង និងអ្នកពាក់ព័ន្ធដទៃទៀត។<br>- ផ្តល់របាយការណ៍ឱ្យបានទាន់ពេលវេលាដល់ជនបង្គោលថ្នាក់ជាតិសម្រាប់សន្និធិឧស្ម័នផ្ទះកញ្ចក់ នៅអគ្គលេខាធិការដ្ឋានក.ជ.អ.ច.<br>- ការសិក្សាលើជម្រើសនៃការកាត់បន្ថយ (រួមទាំងការវិភាគអត្ថប្រយោជន៍ធៀបនឹងចំណាយ CBA) រួមទាំងការលើកកម្ពស់បច្ចេកវិទ្យាដែលមានគោលបំណងបង្កើនប្រសិទ្ធភាព ឬ ជំនួសអុស ឬធ្យូង មានដូចជាចង្ក្រានដែលមានប្រសិទ្ធភាពឡជីវឧស្ម័ន អំពូលពន្លឺព្រះអាទិត្យ ការបូមទឹក ខ្យល់ និងម៉ាស៊ីនចំពោះទឹកសេ៉ាមិចជាដើម។<br>- សកម្មភាពនេះ នឹងផ្តល់លទ្ធផលគួរឱ្យទុកចិត្ត ការបំពេញបាននូវសកម្មភាពដែលមានគុណភាពល្អ និងការទទួលបានទិន្នន័យការបញ្ចេញដែលធ្វើឱ្យការប៉ាន់ស្មានតម្រូវការថាមពល និងការបញ្ចេញនាពេលអនាគត និងការកំណត់ឱកាសសម្រាប់ការកាត់បន្ថយការបញ្ចេញចេញពីវិស័យថាមពលឱ្យកាន់តែមានភាពប្រសើរឡើង។ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | ជាកាតព្វកិច្ចសម្រាប់ប្រទេសកម្ពុជាក្នុងនាមជាសមាជិកនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ លើសពីនេះទៀតការធ្វើសន្និធិឧស្ម័នផ្ទះកញ្ចក់ នឹងជួយប្រទេសកម្ពុជាក្នុងការគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ពីវិស័យថាមពលឱ្យកាន់តែមានប្រសិទ្ធភាពដោយផ្តល់ព័ត៌មានដែលមានប្រយោជន៍ដល់អ្នកធ្វើគោលនយោបាយ និងវិនិយោគិនលើវិស័យសក្តានុពលសម្រាប់ការធ្វើផែនការ និងការវិនិយោគកាបូនតិច។ ការងារនេះក៏នឹងជួយប្រទេសកម្ពុជាក្នុងការទាក់ទាញសម្រាប់ការផ្តល់មូលនិធិអាកាសធាតុដែលបានគ្រោងទុកសម្រាប់គម្រោងកាត់បន្ថយ ក៏ដូចជាដើម្បីប្រមូលការគាំទ្រពីប្រទេសអភិវឌ្ឍន៍ទាក់ទងនឹងជំនួយបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យាផងដែរ។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | កិច្ចសហប្រតិបត្តិការយ៉ាងសកម្មរវាង ក្រសួងរ៉ែ និងថាមពល ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) និងលេខាធិការដ្ឋានក.ជ.អ.ច. និងអ្នកជំនាញអន្តរជាតិអំពីតុល្យភាពថាមពល និងសន្និធិឧស្ម័នផ្ទះកញ្ចក់។ |
| សូចនាករនៃភាពជោគជ័យ | -ប្រព័ន្ធសន្និធិឧស្ម័នផ្ទះកញ្ចក់ សម្រាប់វិស័យថាមពលត្រូវបានបង្កើតឡើង<br>-ការបង្កើតការបញ្ចេញមូលដ្ឋាននៅចន្លោះឆ្នាំ២០១៦ និង ២០៥០ ដោយផ្អែកលើទិន្នន័យដែលអាចរកបានថ្មីៗ និងការប៉ាន់ស្មាននៃតម្រូវការនាពេលអនាគត<br>-ចំនួនជម្រើសកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់<br>-កម្រិតសមត្ថភាពប្រសើរឡើងនៅក្នុងប្រព័ន្ធសន្និធិឧស្ម័នផ្ទះកញ្ចក់ |

| | |
|---|---|
| ការរៀបចំការអនុវត្ត | នាយកដ្ឋានអភិវឌ្ឍថាមពល របស់ក្រសួងរ៉ែ និងថាមពល ដោយមានការសម្របសម្រួលជាមួយ ក.ស.ជ. ក.ប. អ.អ.ក. អ.ក. និងដៃគូអភិវឌ្ឍន៍ដទៃទៀត។ |
| ចំណាយប៉ាន់ស្មានសរុប | ៥៧៦ ០០០ ដុល្លារ |
| ប្រភពមូលនិធិ | ម្ចាស់ជំនួយទ្វេភាគី, USAID, UNDP, JICA, ADB, UNEP, UNFCCC, IGES, GEF, and CCCA |
| រយៈពេល | ២០២១-២០២៣ |

៦) ឯកសារសកម្មភាពលេខ ៦៖

| | |
|---|---|
| សកម្មភាព | ផ្តល់ជូនប្រភពថាពលអគ្គិសនីស្អាតនិងបច្ចេកវិទ្យាបញ្ចេញកាបូនតិចទៅកាន់ភូមិនិងគ្រួសារដែលនៅដាច់ស្រយាលមិនទាន់មានអគ្គិសនីប្រើប្រាស់។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | -ផ.យ.ប.អ.ក. ០៤៖ លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។<br>-ផ.យ.ប.អ.ឧ.ថ. ០៣៖ អនុវត្តវិធីសាស្ត្រគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល។ |
| សនិទានភាព | នៅចុងឆ្នាំ២០១៩ ប្រទេសកម្ពុជា មានសហគ្រាសអគ្គិសនីជនបទចំនួន ៣៦៤ ដែលទទួលបានសិទ្ធិក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងប្រទេស។ តំបន់អាជ្ញាប័ណ្ណគ្របដណ្តប់ភូមិចំនួន ១៤ ០៩៥ (៩៩,៤៨%) ក្នុងចំណោមចំនួនភូមិសរុបចំនួន ១៤ ១៦៨ ដែលក្នុងនោះមាន ៧៣ភូមិស្ថិតនៅក្រៅតំបន់អាជ្ញាប័ណ្ណ។ ក្នុងចំណោម ១៤ ០៩៥ភូមិ នៅក្នុងតំបន់អាជ្ញាប័ណ្ណមានភូមិចំនួន ១៣ ១៣១ ទទួលបានអគ្គិសនីពីបណ្តាញជាតិរួចហើយ ខណៈដែលភូមិចំនួន ៩៦៦ នៅមិនទាន់បានភ្ជាប់អគ្គិសនីពីបណ្តាញជាតិប្រើប្រាស់នៅឡើយ។ ដូច្នេះ ភូមិសរុបចំនួន ១ ០៣៧ នៅមិនទាន់បានភ្ជាប់អគ្គិសនីពីបណ្តាញប្រើប្រាស់នៅឡើយគិតត្រឹមចុងឆ្នាំ២០១៩ នេះ។ យោងតាមអាជ្ញាធរអគ្គិសនីបានឱ្យដឹងថា ភូមិចំនួន ៧៩៤ ទៀតនេះ នឹងត្រូវភ្ជាប់បណ្តាញជាតិអគ្គិសនីនៅក្នុងឆ្នាំ២០២០ រីឯភូមិនៅសល់ចំនួន ២៤៣ ទៀត ពិបាកនឹងតបណ្តាញចូលទៅដល់ក្នុងឆ្នាំ២០២០ នេះបានណាស់។ ក្នុងចំណោមភូមិចំនួន ២៣៧ ដែលពិបាកទៅដល់ មានចំនួន ១១៨ភូមិ ជាភូមិដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាល និងមានចំនួនខ្នងផ្ទះដាច់ពីគ្នាឆ្ងាយ ក្នុងនោះមានភូមិចំនួន ៣២ គ្មានផ្លូវទៅដល់; ភូមិចំនួន ៤៦ ស្ថិតនៅលើកោះ ភូមិចំនួន ៣៤ គឺជាភូមិអណ្តែតទឹក ហើយមានភូមិចំនួន ៧ គឺជាភូមិលិចទឹកនៅរដូវវស្សា។ ការលំបាកក្នុងការនាំបណ្តាញអគ្គិសនីជាតិចូលដល់ភូមិ និងខ្នងផ្ទះទាំងនេះ អាចដោះស្រាយបានដោយការផ្តល់ថាមពលពន្លឺព្រះអាទិត្យ ឬថាមពលស្អាតផ្សេង |

| | |
|---|---|
| | ទៀតតាមជម្រើសពីរដែលអាចធ្វើបានរួមមាន៖ ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ និងបណ្តាញអគ្គិសនីខ្នាតតូច។ |
| ប្រភេទសកម្មភាព | ☑Cat 1 –ពង្រីក ☐Cat 2 –កែលម្អ ☐Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយ និងការបន្សាំ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាព និងលទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍ | **ការពិពណ៌នាសង្ខេប៖**<br>- ធ្វើការសិក្សាលើស្ថានភាពនៃការប្រើប្រាស់អគ្គិសនីនៅក្នុងភូមិដាច់ស្រយាលទាំងអស់ និងសមិទ្ធិលទ្ធភាពនៃជម្រើសដែលអាចផ្គត់ផ្គង់អគ្គិសនីបាន រួមមានថាមពលពន្លឺព្រះអាទិត្យ និងបណ្តាញអគ្គិសនីខ្នាតតូច និងបច្ចេកវិទ្យាបញ្ចេញកាបូនតិចនានា។<br>- ការរៀបចំឯកសារគោលគំនិតគម្រោង និងឯកសារបច្ចេកទេសដេញថ្លៃ<br>- ការដេញថ្លៃជាសាធារណៈសម្រាប់អ្នកផ្គត់ផ្គង់។<br>- ត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវាកម្ម។<br>- រាយការណ៍លទ្ធផល និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ។<br>**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**<br>- សម្រេចបានគោលដៅអគ្គិសនីភាវូបនីយកម្ម ១០០ភាគរយ<br>- កម្រិតជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទមានការកើនឡើង<br>- ការបង្កើតការងារ<br>- ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់<br>- សុខភាព និងសន្តិសុខល្អប្រសើរ<br>- មានទិន្នន័យគ្រប់គ្រាន់សម្រាប់អ្នកធ្វើគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត<br>- ទាក់ទាញវិនិយោគិនចូលមកក្នុងប្រទេស។ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | ថាមពលព្រះអាទិត្យ និងថាមពលស្អាតផ្សេងទៀត គឺជាប្រភពថាមពលដែលមានថ្លៃសមរម្យ និងមានផ្គត់ផ្គង់ក្នុងស្រុក។ នៅក្នុងសេណារីយ៉ូធុរកិច្ចធម្មតា(BAU) ថាមពលសូឡាមានតម្លៃថ្លៃជាងតម្លៃរបស់ម៉ាស៊ូត។ តម្លៃមូលដ្ឋានសន្មតថា ការប្រើប្រាស់ម៉ាស៊ីនភ្លើងម៉ាស៊ូតនៅតាមស្ថានីយ៍សាកក្នុងភូមិ យកមកសាកអាគុយរថយន្ត ធ្វើឱ្យការផ្គត់ផ្គង់អគ្គិសនីសម្រាប់គ្រួសារមានកម្រិតទាប។ វិធីសាស្ត្រនេះធ្វើឱ្យថ្លៃដើមផលិតនៃកម្រិតមូលដ្ឋាន មានតម្លៃ ០,៤០ ដុល្លារក្នុងមួយគីឡូវ៉ាត់ម៉ោង។ នៅក្នុងការប្រៀបធៀបថ្លៃដើម ថាមពលសូឡានៅក្នុងសេណារីយ៉ូ BAU ត្រូវបានប៉ាន់ប្រមាណថា មានចំនួន ១,១៧ ដុល្លារក្នុងមួយគីឡូវ៉ាត់ម៉ោង។ នេះមានន័យថា អគ្គិសនីពីសូឡាដោយមិនទាន់កាត់កងជាមួយនឹងតម្លៃហានិភ័យត្រូវមានតម្លៃបន្ថែម ០,៧៧ ដុល្លារអាមេរិកក្នុងមួយគីឡូវ៉ាត់ម៉ោង លើតម្លៃថាមពលដែលបានមកពីបច្ចេកវិទ្យាថាមពលមូលដ្ឋាន។ ចំពោះសេណារីយ៉ូក្រោយការ |

| | |
|---|---|
| | ចំណាយថ្លៃអគ្គិសនីបន្ទាប់ពីកាត់កងលើតម្លៃហានិភ័យរួចហើយ តម្លៃរបស់វាចុះថយបន្តិចបន្តួចដល់ ១,០៨ ដុល្លារក្នុងមួយគីឡូវ៉ាត់ម៉ោង។ នេះមានន័យថា ០,៦៨ ដុល្លារអាមេរិក ខ្ពស់ជាងថ្លៃអគ្គិសនីក្នុងតម្លៃមូលដ្ឋានដែលប្រើម៉ាស៊ីនម៉ាស៊ូត។ ត្រង់នេះវាបង្ហាញថា នៅពេលអនុវត្តអន្តរាគមន៍របស់រាជរដ្ឋាភិបាលដើម្បីលុបបំបាត់បរិយាកាសវិនិយោគថាមពលអគ្គិសនីពីថាមពលសូឡា វាមានថ្លៃសមរម្យជាង ប៉ុន្តែថ្លៃអគ្គិសនីទូទៅពីថាមពលសូឡានៅតែខ្ពស់ជាងថ្លៃអគ្គិសនីពីមូលដ្ឋានម៉ាស៊ីនភ្លើងម៉ាស៊ូត (បើមើលពីជ្រុងនៃការផលិតអគ្គិសនី)។ គ្រួសារមួយចំណាយប្រហែល ០,៦០ ដុល្លារ ទៅ ០,៧៥ ដុល្លារ អាស្រ័យលើទំហំអាគុយជាទូទៅប្រហែល ៥០-៧០ អំពែរម៉ោង។ ភាពញឹកញាប់នៃការសាកអាគុយ គឺអាស្រ័យលើតម្រូវការថាមពលរបស់គ្រួសារ ប៉ុន្តែជាធម្មតាមានចំនួន ១-៣ ដងក្នុងមួយសប្តាហ៍។<br>ទោះយ៉ាងណាក្តី ការផ្តល់ការគាំទ្រពីគម្រោងនេះ គេរំពឹងថានឹងកាត់បន្ថយថ្លៃអគ្គិសនីពីថាមពលសូឡាបានបន្តទៀត។ នៅក្នុងការអនុវត្តជាក់ស្តែង មូលនិធិអគ្គិសនីជនបទបានផ្តល់ប្រាក់ឧបត្ថម្ភរហូតដល់ ១០០ ដុល្លារអាមេរិក ក្នុងមួយប្រព័ន្ធ។ ឧបត្ថម្ភធននេះ នឹងធ្វើឱ្យថ្លៃដើមធ្លាក់ចុះប្រហែល ៣០ %ទៀត។ ជាមួយនឹងបច្ចេកវិទ្យាថ្មីនៃអាគុយ LiFePO4 ដែលគេរំពឹងថាអាចមានអាយុកាលប្រើប្រាស់រហូតដល់ ១០ឆ្នាំ នោះមានន័យថាគ្រួសារនីមួយៗមិនចាំបាច់ផ្លាស់ប្តូរអាគុយពួកគេញឹកញាប់ទៀតទេ ដែលវាអាចធ្វើឱ្យថ្លៃចុះថោកបានមួយកម្រិតទៀត។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - សកម្មភាពនេះ ពឹងផ្អែកលើឆន្ទៈក្នុងការរួមគ្នាបង់ថ្លៃពីគ្រួសារនីមួយៗ សម្រាប់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ និងបណ្តាញអគ្គិសនីខ្នាតតូច។<br>- កម្រិតសមត្ថភាពរបស់សហគមន៍មូលដ្ឋានគឺត្រូវការសម្រាប់ប្រតិបត្តិការ និងការគ្រប់គ្រងបណ្តាញអគ្គិសនីខ្នាតតូច។<br>- ការប្តេជ្ញាចិត្តពីថ្នាក់ដឹកនាំ គឺចាំបាច់ដើម្បីធានាការអនុវត្តបានរហ័ស។<br>- ការគាំទ្រពីអាជ្ញាធរមូលដ្ឋានសហគមន៍ គឺជាកត្តាចាំបាច់ក្នុងការសម្រួលដល់ការដំឡើងការប្រើប្រាស់ដីសម្រាប់បណ្តាញខ្នាតតូចការប្រមូលថ្លៃសម្រាប់ការថែទាំ។<br>- មានសេវាថែទាំនៅថ្នាក់មូលដ្ឋាន គឺត្រូវការសម្រាប់ជួសជុលប្រព័ន្ធ ឬថែទាំ។<br>- ត្រូវការការគាំទ្រពីអ្នកកាន់អាជ្ញាប័ណ្ណផ្គត់ផ្គង់អគ្គិសនី ដើម្បីការពារជម្លោះ។ |
| សូចនាករនៃភាពជោគជ័យ | - ចំនួនបណ្តាញអគ្គិសនីខ្នាតតូច ដែលបានដំឡើង<br>- ចំនួន SHS ដែលបានដំឡើង។<br>- ចំនួនគ្រួសារដែលបានចាកចេញពីភាពក្រីក្រ<br>- ចំនួន SHS និងប្រតិបត្តិការខ្នាតតូចបន្ទាប់ពី ៥ ឆ្នាំ។ |

| | |
|---|---|
| ការរៀបចំការអនុវត្ត | នាយកដ្ឋានថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត របស់ក្រសួងរ៉ែ និងថាមពល សហការជាមួយ អាជ្ញាធរអគ្គិសនី អគ្គិសនីកម្ពុជា និងមូលនិធិអគ្គិសនីជនបទ ព្រមទាំងដៃគូអភិវឌ្ឍន៍ដទៃទៀត។ |
| ចំណាយប៉ាន់ស្មានសរុប | ៧៤ ៩១១ ៧៦៥ ដុល្លារ |
| ប្រភពមូលនិធិ | CCCA, ADB, KfW, China AID, KOICA and JICA |
| រយៈពេល | ២០២១-២០២៣ |

៧) ឯកសារសកម្មភាពលេខ៧៖

| | |
|---|---|
| សកម្មភាព | រៀបចំនិងអនុវត្តគម្រោងប្រសិទ្ធភាពថាមពលក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | - ផ.យ.ប.អ.ក. ០៤៖ លើកកម្ពស់ការកសាងផែនការ និងការប្រើប្រាស់បច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។<br>- ផ.យ.ប.អ.ឧ.ថ. ០៣៖ អនុវត្តវិធីសាស្ត្រគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល |
| សនិទានភាព | ប្រទេសកម្ពុជា បានប្តេជ្ញាចិត្តក្នុងការកាត់បន្ថយការបញ្ចេញកាបូនដែលបំភាយចេញពីកំណើនសេដ្ឋកិច្ច និងកំពុងខិតខំប្រឹងប្រែងដើម្បីដើរលើមាគ៌ានៃការអភិវឌ្ឍប្រកបដោយភាពធន់នឹងបញ្ចេញកាបូនតិច ហើយតាមរយៈមាគ៌ានេះ នឹងបង្កើតបាននូវការអភិវឌ្ឍប្រកបដោយចីរភាពបន្ថែមទៀត។<br>ដើម្បីលើកកម្ពស់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ប្រទេសកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការបង្កើតលក្ខខណ្ឌដែលចាំបាច់សម្រាប់ដំណើរការនៃយន្តការឥណទានកាបូនដែលត្រូវបានបង្កើតឡើងក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) រួមមានទាំងយន្តការអភិវឌ្ឍស្អាត (CDM) បង្កើតឡើងដោយពិធីសារខ្យូតូ (Kyoto Protocol)។ យន្តការផ្តល់ហិរញ្ញប្បទានដល់គម្រោង និងកម្មវិធីផ្សេងទៀតរួមមានយន្តការផ្តល់ឥណទានរួម (JCM) ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើ (រេដបូក) និងសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជាតិ (NAMA) ជាដើម។<br>នៅក្នុងវិស័យថាមពល មានសក្តានុពលក្នុងការរៀបចំគម្រោងសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជាតិ(NAMA) ជាច្រើនរួមមាន៖ថាមពលវារីអគ្គិសនីជីវម៉ាស់ (ការបំប្លែងថាមពលជីវឥន្ធនៈកសិកម្មទៅជាថាមពល ឡឥដ្ឋ ចង្ក្រាន និងប្រសិទ្ធភាពឡចំហាយក្នុងឧស្សាហកម្ម) ថាមពលព្រះអាទិត្យ ថាមពលជីវឧស្ម័ន ខ្យល់ បច្ចេកវិទ្យាធ្យូងថ្មស្អាត និងសហផលិតកម្ម |

| | |
|---|---|
| | ថាមពលកម្តៅ ការគ្រប់គ្រងសំរាមទីក្រុង ការដោះស្រាយការខាតបង់ ការចែកចាយអគ្គិសនី ជាពិសេសប្រសិទ្ធភាពថាមពល ។ល។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☐Cat 2 –កែលម្អ ☑Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាពនិងលទ្ធផលរំពឹងទុកនិងអត្ថប្រយោជន៍ | សកម្មភាពនេះនឹងផ្តោតលើការបង្កើតគម្រោងសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជាតិនៅក្នុងវិស័យថាមពល ជាពិសេសប្រសិទ្ធភាពថាមពល រួមមានដូចតទៅ៖<br>- វាយតម្លៃលក្ខខណ្ឌ និងយុទ្ធសាស្ត្រក្របខ័ណ្ឌ និងកំណត់ឱកាសកាត់បន្ថយនៅក្នុងវិស័យថាមពល (ដោយមានការសម្របសម្រួលជាមួយការអនុវត្តសកម្មភាពទី៤)<br>- វាយតម្លៃសក្តានុពលកាត់បន្ថយការបញ្ចេញតាមលក្ខណៈបច្ចេកទេស និងការវិភាគផលចំណេញរួម និងថ្លៃដើមរួម<br>- ជ្រើសរើសគំនិតសម្រាប់រៀបចំគម្រោងប្រសិទ្ធភាពថាមពលរួមទាំង NAMA<br>- កំណត់គោលបំណងរបស់គម្រោង និងជ្រើសរើសឧបករណ៍ចម្រុះ<br>- រៀបចំយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ<br>- ផែនការលម្អិត<br>- កំណត់ធនធានដែលត្រូវការ<br>- គាំទ្រដល់ការអនុវត្តគម្រោង<br>សកម្មភាពនេះ ត្រូវបានគេរំពឹងថា នឹងទាក់ទាញការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុពីបណ្តាប្រទេសអភិវឌ្ឍន៍ និងពីវិនិយោគិនឯកជនឆ្ពោះទៅរកការអភិវឌ្ឍកាបូនតិច ដែលនឹងធ្វើឱ្យប្រសើរឡើងនូវផែនការអភិវឌ្ឍន៍ថាមពលកាបូនតិចនៅក្នុងប្រទេសកម្ពុជាផងដែរ។ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | -សកម្មភាពនេះ គឺជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជានៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ<br>-ចូលរួមចំណែកក្នុងការទាក់ទាញថវិកាសម្រាប់ការអនុវត្តគម្រោងនានា រាប់ទាំង NAMA (ទាំងប្រភពក្នុងស្រុក និងអន្តរជាតិ) ដូចជាការគាំទ្រពីប្រទេសអភិវឌ្ឍន៍ទាក់ទងនឹងជំនួយបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យា។<br>-ការបង្កើតប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងការផ្ទៀងផ្ទាត់ (MRV) |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - ភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្តរបស់ក្រសួងរ៉ែ និងថាមពលក្នុងការជំរុញនិងសម្រេចគោលដៅអភិវឌ្ឍន៍កាបូនតិចដោយផ្តោតសំខាន់លើរបៀបវារៈការអនុម័តលើក្របខ័ណ្ឌច្បាប់សម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័ន |

| | |
|---|---|
| | ផ្ទះកញ្ចក់ និងការបង្កើតប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងការផ្ទៀងផ្ទាត់ និងប្រព័ន្ធចុះបញ្ជីគម្រោងដែលមានគុណភាព។<br>- វឌ្ឍនភាពក្នុងការបង្កើតប្រព័ន្ធសន្និធិឧស្ម័នផ្ទះកញ្ចក់។<br>- ការពង្រឹងសមត្ថភាពបុគ្គលិករបស់ក្រសួងរ៉ែ និងថាមពល។<br>- ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុទាន់ពេលវេលា។ |
| សូចនាករនៃភាពជោគជ័យ | - ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានកាត់បន្ថយ<br>- ចំនួនគម្រោងត្រូវបានរៀបចំ<br>- បរិមាណថាមពលកាបូនតិច ត្រូវបានរួមបញ្ចូលក្នុងតុល្យការថាមពលជាតិ |
| ការរៀបចំការអនុវត្ត | អគ្គនាយកដ្ឋានថាមពល នៃក្រសួងរ៉ែ និងថាមពល ដោយសហការជាមួយ ក្រសួងបរិស្ថាន វិស័យឯកជន ស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដទៃទៀត។ |
| ចំណាយប៉ាន់ស្មានសរុប | ៦00 000 ដុល្លារ |
| ប្រភពមូលនិធិ | ODA, UNDP, GEF, មូលនិធិអាកាសធាតុបៃតង, មូលនិធិអភិវឌ្ឍន៍ Nordic និង JICA, KOICA និងដៃគូអភិវឌ្ឍន៍ដទៃទៀត។ |
| រយៈពេល | ២០២១-២០២៣ |

៨) ឯកសារសកម្មភាពលេខ ៨៖

| | |
|---|---|
| សកម្មភាព | រៀបចំនិងអនុវត្តកម្មវិធីស្លាកសញ្ញា និងស្តង់ដាប្រសិទ្ធភាពថាមពលក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | - ផ.យ.ប.អ.ក. ០៤៖ លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។<br>- ផ.យ.ប.អ.ឱ.ថ. ០៣៖ អនុវត្តវិធីសាស្ត្រគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល |
| សនិទានភាព | រហូតមកដល់ពេលនេះ នៅមិនទាន់មានបទដ្ឋាន និងកម្មវិធីបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល នៅឡើយទេនៅក្នុងប្រទេសកម្ពុជា។ ទោះយ៉ាងណាក្តី អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមានការផ្តួចផ្តើមគំនិតក្នុងឆ្នាំ២០១០ តាមរយៈគម្រោងសហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើតបទដ្ឋាន និងការដាក់ស្លាកសញ្ញាសម្រាប់ឧបករណ៍អគ្គិសនីតាមរយៈការលើកកម្ពស់ និងបង្ហាញ ការអភិរក្សថាមពលនៅក្នុងខេត្តសៀមរាបនៃនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន។ គម្រោងនេះ ត្រូវបានផ្តល់មូលនិធិដោយ EEP Mekong ដែលជាផ្នែកមួយនៃកម្មវិធីកាត់បន្ថយអាកាសធាតុសម្រាប់ប្រទេសក្នុងតំបន់ទន្លេមេគង្គ។ នៅក្នុងគម្រោងនេះ ស្លាកប្រសិទ្ធភាពថាមពលនៃឧបករណ៍អគ្គិសនីដែលនាំចូលមកប្រទេសកម្ពុជាត្រូវបានបកប្រែជាភាសាខ្មែរ ដើម្បីធានាថាប្រជាពលរដ្ឋនៅមូលដ្ឋានអាចជ្រើសរើស |

| | |
|---|---|
| | ផលិតផលមានប្រសិទ្ធភាពថាមពលសម្រាប់ការប្រើប្រាស់របស់ពួកគេបាន។ ទោះយ៉ាងណាក៏ដោយ មិនមានបទដ្ឋាននិងកន្លែងធ្វើតេស្តសំណាកផលិតផលដែលត្រូវបានបង្កើតឡើងក្នុងអំឡុងពេលអនុវត្តគម្រោងនេះទេ។ នៅឆ្នាំ២០១៣ គំនិតផ្តួចផ្តើមមួយទៀតសម្រាប់បទដ្ឋាន និងការដាក់ស្លាកប្រសិទ្ធភាពថាមពលស្ថិតក្រោមកម្មវិធីប្រសិទ្ធភាពថាមពលអាស៊ានជប៉ុនក្រោមការសម្របសម្រួលពីមជ្ឈមណ្ឌលថាមពលអាស៊ាន។ នៅក្នុងការគាំទ្រនេះ បទប្បញ្ញត្តិស្តីពី EE S&L សម្រាប់ម៉ាស៊ីនត្រជាក់ត្រូវបានបង្កើតឡើង ដោយសិក្សាអំពីសក្តានុពលទីផ្សារ និងសក្តានុពលសន្សំថាមពល ដើម្បីចង់ដឹងអំពីកម្មវិធីបទដ្ឋាន និងស្លាកប្រសិទ្ធភាពថាមពលដែលមានស្រាប់។ ទោះយ៉ាងណាក៏ដោយ គម្រោងនេះនៅតែស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍នៅឡើយ។ នៅឆ្នាំ២០១៤ សិក្ខាសាលាស្តីពីការពង្រឹងសមត្ថភាពកាត់បន្ថយភាពផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ នៅក្នុងប្រទេសកូរ៉េ និងការពិគ្រោះយោបល់គោលនយោបាយស្តីពីបទដ្ឋានប្រសិទ្ធភាពថាមពល និងស្លាកសញ្ញាសម្រាប់កម្ពុជា ជាផ្នែកមួយនៃកម្មវិធីកិច្ចសហប្រតិបត្តិការកាត់បន្ថយអាស៊ានបូក ៣ ត្រូវបានដាក់ចូលក្នុងរបៀបវារៈនៃការគាំទ្រសម្រាប់ប្រទេសកម្ពុជាដោយប្រទេសកូរ៉េ ដែលមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរបស់រដ្ឋសមាជិកអាស៊ានបូក ៣ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការកសាងសមត្ថភាពនិងការចែករំលែកព័ត៌មានស្តីពីការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍឱកាសអាជីវកម្មលើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ ក្នុងការគាំទ្រនេះ បទប្បញ្ញត្តិត្រូវបានបង្កើតឡើងជាមួយនឹងការរចនាស្លាកសញ្ញាប្រសិទ្ធភាពថាមពលដែលត្រូវបានប្រគល់ទៅ ក្រសួងរ៉ែ និងថាមពល ដើម្បីដំណើរការអនុម័ត និងអនុវត្តក្នុងសិក្ខាសាលានៅខែសីហា ឆ្នាំ២០១៧។ កិច្ចការងារប្រសិទ្ធភាពថាមពលនេះ រួមមានការបញ្ចូលបទដ្ឋានប្រសិទ្ធភាពថាមពល និងការដាក់ស្លាកសញ្ញាសម្រាប់ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ប្រសិទ្ធភាពថាមពលសម្រាប់អគារ ក្រមប្រសិទ្ធភាពថាមពលសម្រាប់អគារ សវនកម្មថាមពល និងការរាយការណ៍ចាំបាច់និងការកសាងសមត្ថភាពថាមពល។ ក្រសួងរ៉ែ និងថាមពល មានផែនការប្រមូលធនធានទាំងអស់ រួមទាំងជំនួយបច្ចេកទេសដើម្បីបញ្ចប់ឬកែលម្អបន្ថែមទៀតនូវបទប្បញ្ញត្តិស្តីពីបទដ្ឋាន និងការដាក់ស្លាកសញ្ញាប្រសិទ្ធភាពថាមពល ដើម្បីធានាថាត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិ ស្តីពីប្រសិទ្ធភាពថាមពល។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☑Cat 2 –កែលម្អ ☐Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាព និង | **ការពិពណ៌នាសង្ខេបៈ** |

| | |
|---|---|
| លទ្ធផលរំពឹងទុកនិងអត្ថប្រយោជន៍ | ដើម្បីធានាការបង្កើតបទដ្ឋាន និងការដាក់ស្លាកសញ្ញាប្រសិទ្ធភាពថាមពលដោយជោគជ័យ និងត្រូវបានអនុវត្តប្រកបដោយចីរភាព យើងត្រូវអនុវត្តតាមជំហានខាងក្រោម៖<br>- ជំហានទី ១៖ សម្រេចចិត្តថាតើនឹងអនុវត្តបទដ្ឋាន និងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលឬអត់ ហើយបើអនុវត្ត តើអនុវត្តបែបណា<br>- ជំហានទី ២៖ អភិវឌ្ឍសមត្ថភាពធ្វើតេស្ត និងការកសាងសមត្ថភាពឱ្យបានត្រឹមត្រូវ។<br>- ជំហានទី ៣៖ការរៀបចំ និងអនុវត្តកម្មវិធីបិទស្លាក វិភាគនិងកំណត់បទដ្ឋាន<br>- ជំហ៊ានទី ៤៖ ជំរុញ និងពង្រឹងការអនុវត្ត និង<br>- ជំហានទី ៥៖ វាយតម្លៃការដាក់ស្លាក ឬកម្មវិធីកំណត់បទដ្ឋាន<br>**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍រួមមាន៖**<br>បទដ្ឋាន និងការបិទស្លាកបង្កើនគុណភាពទីផ្សារ នាំឱ្យសម្ភារឧបករណ៍ដែលមានគុណភាពខ្ពស់ និងប្រើថាមពលតិចបំផុត។ បទដ្ឋាននេះនឹងរុញផលិតផលមិនសមរម្យចេញពីទីផ្សារ ការពារអតិថិជន និងកំណត់កម្រិតប្រកួតប្រជែងសម្រាប់អ្នកផលិត អ្នកចែកចាយ និងអ្នកផ្គត់ផ្គង់។ ការបិទស្លាកទាក់ទាញអតិថិជន និងអ្នកទិញផ្សេងទៀតឱ្យទទួលបានផលិតផលច្នៃប្រតិដ្ឋថ្មីល្អបំផុត។<br>បទដ្ឋាននឹងរុញផលិតផលមិនសមរម្យចេញពីទីផ្សារ។ ដោយកំណត់កម្រិតនៃការអនុវត្តថាមពលអប្បបរមា ឬកម្រិតគុណភាពដែលត្រូវការជាអប្បបរមា អត្ថប្រយោជន៍ចេញពីការអនុវត្តសកម្មភាពនេះរួមមានដូចខាងក្រោម៖<br>- បង្កើនប្រសិទ្ធភាព ឬគុណភាពផលិតផលជាមធ្យមនៅលើទីផ្សារ<br>- កាត់បន្ថយការចំណាយលើថាមពល<br>- កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់<br>- ការពារអ្នកប្រើប្រាស់<br>- បង្កើនប្រសិទ្ធភាព និងការប្រកួតប្រជែងទីផ្សារ<br>- ស្លាកសញ្ញាជូនដំណឹងអំពីជម្រើសឆ្លាតវៃលើផលិតផលល្អបំផុត ដើម្បីជួយឱ្យផលិតផលល្អបំផុតលេចធ្លោ<br>- ទទួលស្គាល់ផលិតផលល្អបំផុត<br>- រៀបរាប់ពីការអនុវត្តផលិតផល និងគុណភាព<br>- ការប្រកួតប្រជែង និងការច្នៃប្រតិដ្ឋ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | **ផលប៉ះពាល់សេដ្ឋកិច្ច៖**<br>ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចតែម្យ៉ាងទៅលើការផ្លាស់ប្តូរទីផ្សារពិភពលោកជាពិសេសចំពោះទីផ្សារថាមពលសម្រាប់បំភ្លឺ ឧបករណ៍អគ្គិសនី និងឧបករណ៍ដែលមានប្រសិទ្ធភាព មានតម្លៃរហូតដល់ទៅ៖ |

| | |
|---|---|
| | - ៣៥០ ពាន់លានដុល្លារ នៃការកាត់បន្ថយតម្លៃអគ្គិសនី<br>- ៥០០ ពាន់លានដុល្លារ ក្នុងការចំណាយលើផលិតផលដែលមានប្រសិទ្ធភាពថាមពលនៅឆ្នាំ២០៣៥ ដែលតំណាងឱ្យកំណើនទីផ្សារសេដ្ឋកិច្ចខ្លាំងនៅពេលនោះ។<br>**ការកាត់បន្ថយកាបូន៖**<br>ថ្មីៗនេះ បទដ្ឋានប្រសិទ្ធភាពនៃឧបករណ៍ប្រើប្រាស់ក្នុងចំណោមប្រទេសសេដ្ឋកិច្ចធំៗ ចំនួន ១៨ នៅលើពិភពលោក រំពឹងថា នឹងសន្សំសំចៃឧស្ម័នកាបូនិកបានជាងកន្លះជីកាតោនក្នុងឆ្នាំ២០៣០ ។<br>ទោះយ៉ាងណាក៏ដោយ មែនទែនទៅបទដ្ឋានឧបករណ៍អាចធ្វើបានច្រើនជាងតួលេខនេះទៅទៀត ប្រសិនបើឧបករណ៍ និងគ្រឿងបរិក្ខារថ្មីទាំងអស់ដែលត្រូវបានលក់នៅក្នុងសេដ្ឋកិច្ចធំៗ ប្រើបច្ចេកវិទ្យាដែលមានប្រសិទ្ធភាពថាមពលច្រើនបំផុត ដែលមាននៅលើទីផ្សារ នោះថាមពលត្រូវបានសន្សំជារៀងរាល់ឆ្នាំ។ នៅឆ្នាំ២០៣០ អាចនឹងស្មើនឹងជិត ១៦ អ៊ិចសាស៊ូល ដែលតួលេខនេះមានតម្លៃប្រមាណជា ២០% នៃតម្រូវការថាមពលអគ្គិសនីនៅទូទាំងពិភពលោកក្នុងឆ្នាំ២០១៤។<br>នៅទូទាំងពិភពលោក ប្រទេសចំនួន ៧៥ បានប្រកាន់ខ្ជាប់នូវបទដ្ឋាន និងស្លាកសញ្ញាគុណផលថាមពល។ ប្រសិនបើសេដ្ឋកិច្ចធំៗ ចំនួន ១៨ បានកែលម្អបទដ្ឋានរបស់ពួកគេ ហើយងាកមកប្រើបច្ចេកវិទ្យាឧត្តមគុណផលនោះ យើងអាចសន្សំសំចៃការបញ្ចេញឧស្ម័នកាបូនិកបានកន្លះជីកាតោននៅឆ្នាំ២០៣០ ពោលគឺស្ទើរតែពាក់កណ្តាលនៃការប្តេជ្ញាចិត្តរបស់ប្រទេសសរុបបញ្ចូលគ្នាសម្រាប់ឆ្នាំ២១០០ ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។<br>រហូតមកដល់បច្ចុប្បន្ននេះ ប្រទេសចំនួន ១៩ បានអនុម័ត ឬកំពុងពិចារណាទទួលយកបទដ្ឋានគុណភាពសម្រាប់ឧបករណ៍ប្រើប្រាស់ក្រៅបណ្តាញអគ្គិសនី ឬការបញ្ចេញឧស្ម័នពីចង្ក្រាន និងគោលនយោបាយសុវត្ថិភាពដែលបង្ហាញពីការវិវត្តយ៉ាងឆាប់រហ័សនៃទីផ្សារប្រកបដោយប្រសិទ្ធភាពថាមពលទាំងនេះ។ យើងគួរមានការស្រាវជ្រាវចាំបាច់ដើម្បីគណនាប្រសិទ្ធភាពចំណាយសម្រាប់ប្រទេសកម្ពុជា។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - ការគាំទ្រផ្នែកហិរញ្ញវត្ថុទាន់ពេលវេលា<br>- ការគាំទ្រផ្នែកបច្ចេកទេស ការគាំទ្រ និងការអនុវត្តច្បាប់<br>- កិច្ចសហប្រតិបត្តិការពីវិស័យឯកជន និងអាជ្ញាធរមូលដ្ឋាន |
| ការរៀបចំការអនុវត្ត | - បរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ត្រូវបានកាត់បន្ថយ<br>- ចំនួនស្លាកសញ្ញាប្រសិទ្ធភាពថាមពលបានបិទផ្សាយ |
| ចំណាយប៉ាន់ស្មានសរុប | អគ្គនាយកដ្ឋានថាមពលក្នុងក្រសួងរ៉ែ និងថាមពល និងក្រសួង-ស្ថាប័នពាក់ព័ន្ធដទៃទៀត។ |
| ប្រភពមូលនិធិ | ២ ៩០០ ០០០ ដុល្លារ |

| | |
|---|---|
| រយៈពេល | ADB, UNDP, CCCA, JICA, និងដៃគូអភិវឌ្ឍន៍ដទៃទៀត |
| ការរៀបចំការអនុវត្ត | ២០២១-២០២៣ |

៩) ឯកសារសកម្មភាពលេខ ៩៖

| | |
|---|---|
| សកម្មភាព | រៀបចំសិក្សាថាមពលស្អាតប្រកបដោយនិរន្តរភាពសម្រាប់ការចម្អិនអាហារ និងអនុវត្តជម្រើសដែលមានល្អបំផុត |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | - ផ.យ.ប.អ.ក. ០៤៖ លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។<br>- ផ.យ.ប.អ.ឧ.ថ. ០៣៖ អនុវត្តវិធីសាស្ត្រគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល។ |
| សនិទានភាព | នៅប្រទេសកម្ពុជាថាមពលជីវម៉ាសមានប្រហែល ៥៥ %នៃល្បាយថាមពលដែលជាសមាមាត្រខ្ពស់បំផុតនៅអាស៊ីអាគ្នេយ៍។ ថាមពលនេះ ត្រូវបានប្រើប្រាស់សម្រាប់ការចម្អិនអាហារក្នុងស្រុក ដែលក្នុងនោះមាន៨២ % នៃគ្រួសារកម្ពុជាសរុប ប្រើប្រាស់អុសធ្វើជាឥន្ធនៈដ៏សំខាន់។ ហើយ ១៨ %នៃប្រជាជនទាំងនោះ ប្រើប្រាស់ធ្យូងជាឥន្ធនៈចម្បងរបស់ពួកគេ។ ការប្រើប្រាស់ថាមពលសរុបរបស់ប្រទេសកម្ពុជា ត្រូវបានគេព្យាករថានឹងកើនឡើងក្នុងអត្រាប្រចាំឆ្នាំជាមធ្យម ៥,២ % ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០៣៥ ហើយធ្យូងត្រូវបានគេរំពឹងថា នឹងបន្តជាតំណាងផ្នែកដ៏សំខាន់មួយនៃល្បាយថាមពល។ ខណៈពេលដែលនៅតាមទីប្រជុំជនការប្រើប្រាស់ធ្យូងត្រូវបានគេរំពឹងថានឹងថយចុះបន្តិច គេរំពឹងថានឹងកើនឡើង ៥៣ %នៅតាមតំបន់ជនបទក្នុងចន្លោះឆ្នាំ២០១២ និង ២០៣០។ នៅថ្នាក់ជាតិ និងថ្នាក់តំបន់ការប្រើប្រាស់ធ្យូងត្រូវបានគេរំពឹងថានឹងកើនឡើងរហូតដល់ឆ្នាំ២០៣០។<br>ដូច្នេះឥន្ធនៈអុសនិងពិសេសជាងនេះគឺធ្យូង ដែលតំណាងឱ្យវិស័យសេដ្ឋកិច្ចយុទ្ធសាស្ត្រខ្ពស់សម្រាប់ប្រទេសកម្ពុជា។ ទោះយ៉ាងណាក៏ដោយការវិនិយោគជាតិ និងអន្តរជាតិនៅក្នុងវិស័យនេះនៅតែមានកម្រិតទាបនៅឡើយ។ ហេតុផលមួយអាចថា មកពីធ្យូងត្រូវបានគេចាត់ទុកថាជាថាមពលសម្រាប់អ្នកក្រីក្រដែលត្រូវជំនួសដោយហ្គាស LPG (ប្រេងឥន្ធនៈរាវ និង ឬ អគ្គិសនី)។ ចក្ខុវិស័យនេះ ត្រូវបានផ្សព្វផ្សាយឱ្យល្បីនៅទសវត្សរ៍ ឆ្នាំ១៩៩០ ជាមួយនឹងគំនិត "ជណ្តើរថាមពល"។ នៅក្នុងគោលគំនិតជណ្តើរថាមពលនេះ គ្រួសារប្រើប្រាស់ប្រភពថាមពលទំនើបៗជាលំដាប់ និងកាត់បន្ថយការប្រើប្រាស់ឥន្ធនៈអុសតាមបែបប្រពៃណីបណ្តើរៗនៅពេលដែលពួកគេក្លាយជាអ្នកមាន ហើយចាប់ផ្តើមងាកមកប្រើប្រភពថាមពលស្អាតវិញ។ ទោះយ៉ាងណាការសិក្សាថ្មីៗនេះ បង្ហាញថាធ្យូងមិនមែនជាថាមពលសម្រាប់អ្នកក្រីក្រទេ ព្រោះវាត្រូវបានគេប្រើប្រាស់ជាទូទៅនៅក្នុងតំបន់ទីក្រុងដែលមានប្រាក់ចំណូលខ្ពស់។ |

| | |
|---|---|
| | ការស្ទង់មតិមួយធ្វើឡើងដោយ GERES ក្នុងឆ្នាំ២០១៣ លើគ្រួសារចំនួន ១ ៩៦៩ តំណាងប្រជាជនកម្ពុជាបង្ហាញថា ចំណែកនៃគ្រួសារដែលប្រើប្រាស់ធ្យូងជាឥន្ទនៈបឋម មិនថយចុះដោយសារតែមានការកើនឡើងនៃទ្រព្យសម្បត្តិឡើយ។ ការពិតនេះត្រូវបានគេសង្កេតឃើញផងដែរនៅក្នុងរាជធានីភ្នំពេញដែលមានហ្គាស LPG ត្រូវបានគេប្រើប្រាស់ច្រើនជាងគេ ហើយទិន្នន័យនេះមានលក្ខណៈស្របជាមួយនឹងការសង្កេតដែលធ្វើឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍដទៃទៀត។ ក្នុងន័យនេះ ប្រភពប្រេងឥន្ទនៈដែលមាននិរន្តរភាពសម្រាប់ការចម្អិនអាហារ គឺជាធាតុចាំបាច់សម្រាប់ការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☐Cat 2 –កែលម្អ ☑Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាពនិងលទ្ធផលរំពឹងទុកនិងអត្ថប្រយោជន៍ | **សកម្មភាព៖**<br>- ធ្វើការសិក្សាប្រភពឥន្ទនៈស្អាតសម្រាប់ការចម្អិនអាហារ។<br>- អភិវឌ្ឍមូលដ្ឋានសម្រាប់ការវិភាគសក្តានុពល។<br>- សាកល្បងវិធីផលិតធ្យូងប្រកបដោយនិរន្តរភាព។<br>- បង្កើតបទប្បញ្ញត្តិសម្រាប់ផលិតកម្មធ្យូងប្រកបដោយនិរន្តរភាព។<br>- អនុវត្តបទប្បញ្ញត្តិ។<br>- តាមដានមើលលទ្ធផល។<br>**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**<br>- ការប្រើប្រាស់អុសសម្រាប់ផលិតកម្មធ្យូងត្រូវបានកាត់បន្ថយ ៣០% ឬច្រើនជាងនេះ។<br>- ការរកអុសប្រកបដោយចីរភាព គឺជាការអនុវត្តនៅក្នុងប្រទេសកម្ពុជា។<br>- ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។<br>- ផលប្រយោជន៍សេដ្ឋកិច្ចដោយសារប្រសិទ្ធភាពកាន់តែប្រសើរ។<br>- ការកាប់បំផ្លាញព្រៃឈើត្រូវបានកាត់បន្ថយ។ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | ផលិតកម្ម និងការផ្គត់ផ្គង់ធ្យូងប្រកបដោយនិរន្តរភាពដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង។ តួនាទីទាំងនោះរួមមាន៖ ផលិតកម្មអាហារកែច្នៃ ការប្រើប្រាស់ និងទទួលបានអាហារតាមរយៈការបង្កើតប្រាក់ចំណូលជាដើម។ ធ្យូងជាញឹកញាប់អាចរកបាននៅតាមទីផ្សារក្នុងស្រុក បើប្រៀបធៀបទៅនឹងជម្រើសថាមពលចម្អិនអាហារផ្សេងទៀត ដូចជាអគ្គិសនី ឬឥន្ទនៈរាវទំនើប ឬឥន្ទនៈហ្គាសជាពិសេសនៅតំបន់ទីប្រជុំជន និង/ឬតំបន់ទីក្រុងក្នុងប្រទេសកម្ពុជាជាដើម។ ការទទួលបានឥន្ទនៈក្នុងថ្លៃសមរម្យអាចជួយឱ្យម្ហូបត្រូវបានចម្អិនឱ្យបានល្អ ធ្វើឱ្យវាកាន់តែងាយរំលាយ និងបង្កើនការស្រូបយកសារធាតុចិញ្ចឹមបានល្អប្រសើរថែមទៀតផង។ ដូចគ្នានេះ |

| | |
|---|---|
| | ផងដែរ ប្រាក់ចំណូលជាសាច់ប្រាក់ពីផលិតកម្មធ្យូងថ្ម និងពាណិជ្ជកម្ម បានផ្តល់នូវមធ្យោបាយដើម្បីទិញអាហារឬដើម្បីវិនិយោគក្នុងផលិតកម្មកសិកម្ម។ អង្គការ FAO បានប៉ាន់ប្រមាណថាប្រជាជនប្រមាណ ២ ៥៧០ ៤០នាក់ នៅក្នុងប្រទេសកម្ពុជា ឬប្រហែល ១៨ភាគរយ នៃផ្ទះនៅប្រទេសកម្ពុជាប្រើប្រាស់ធ្យូងជាប្រភពថាមពលបឋមសម្រាប់ចម្អិនអាហារ។ អង្គការជីរេស (GERES) ប៉ាន់ស្មានថាផលិតកម្មធ្យូងថ្មជាតិរបស់កម្ពុជាមានប្រហែល ៣៣៦ ០០០ តោនក្នុងឆ្នាំ២០១៣។ ដោយគិតពីតម្លៃលក់រាយជាមធ្យម ០,៣៥ ដុល្លារក្នុងមួយគីឡូក្រាម ទីផ្សារធ្យូងនៅកម្ពុជានឹងមានចំនួនជាង ១១៧លានដុល្លារក្នុងមួយឆ្នាំ ដែលធ្វើឱ្យវាក្លាយជាវិស័យសេដ្ឋកិច្ចដ៏សំខាន់មួយសម្រាប់ជនបទនៅប្រទេសកម្ពុជា។ ផលិតកម្មធ្យូងអាចត្រូវបានរួមបញ្ចូលនៅក្នុងប្រព័ន្ធផលិតកម្មចំណីអាហារ ដូចជាតាមរយៈការអនុវត្តកសិផល។ ការសិក្សាបានរកឃើញថា ប្រព័ន្ធកសិឧស្សាហកម្មមួយចំនួនអាចផ្តល់ធនធានឈើសម្រាប់ផលិតធ្យូងពេញមួយឆ្នាំ រួមផ្សំជាមួយដំណាំកសិកម្មដើមបានផង។ លើសពីនេះទៀត អុសនិងចម្ការដើមឈើដែលបង្កើតឡើងសម្រាប់ផលិតកម្មធ្យូងប្រកបដោយនិរន្តរភាព អាចផ្តល់ចំណីអាហារ ចំណីសត្វ និងអុសក្នុងពេលដំណាលគ្នាបានថែមទៀត។ វាក៏រួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីបញ្ឈប់ និងការពារការកាប់បំផ្លាញព្រៃឈើផងដែរ។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - កិច្ចសហប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ<br>- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ<br>- អាចរកបានជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស។ |
| សូចនាករនៃភាពជោគជ័យ | - បទប្បញ្ញត្តិត្រូវបានបង្កើត អនុវត្ត និងអនុវត្តតាម។<br>- ការអនុវត្តធ្យូងប្រកបដោយនិរន្តរភាពត្រូវបានបង្កើតដាក់ពង្រាយនិងអនុវត្តតាម។<br>- ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់<br>- ការអនុវត្តធ្យូងប្រកបដោយនិរន្តរភាពចំនួនត្រូវបានអនុវត្ត ឬអនុវត្តតាម។ |
| ការរៀបចំការអនុវត្ត | នាយកដ្ឋានថាមពកកើតឡើងវិញ និងថាមពលផ្សេងទៀតសហការជាមួយ ក.ជ.អ.ច. |
| ចំណាយប៉ាន់ស្មានសរុប | ១ ៥០០ ០០០ដុល្លារ |
| ប្រភពមូលនិធិ | FAO មូលនិធិអាកាសធាតុបៃតង មូលនិធិអភិវឌ្ឍន៍ណ័រឌីក និងផ្សេងៗទៀត។ |
| រយៈពេល | ២០២១-២០២៣ |

១០) ឯកសារសកម្មភាពលេខ ១០៖

| | |
|---|---|
| សកម្មភាព | រៀបចំសិក្សាគំរូអាជីវកម្មប្រកបដោយនិរន្តរភាពដើម្បីប្រើប្រាស់ថាមពលកម្តៅ និងចំហាយទឹកប្រកបដោយប្រសិទ្ធភាព។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង | -ផ.យ.ប.អ.ក. ០៤៖ លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។ |

| | |
|---|---|
| ផ.យ.ប.អ. តាមវិស័យ | -ផ.យ.ប.អ.ឌ.ថ. ០៣៖ អនុវត្តវិធីសាស្ត្រគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល |
| សនិទានភាព | បច្ចេកវិទ្យាឡចំហាយដែលប្រើច្រើនបំផុតនៅក្នុងរោងចក្រកាត់ដេរ ដើម្បីបំប្លែងឥន្ធនៈអុសទៅជាថាមពលកម្ដៅសម្រាប់ដំណើរការផលិតកម្ម។ ឡចំហាយមានសមត្ថភាពខុសគ្នាចាប់ពី ៤៥ គីឡូក្រាមក្នុងមួយម៉ោង ដល់ ១២ 000 គីឡូក្រាមក្នុងមួយម៉ោង។<br>ឡចំហាយដែលមានទំហំចាប់ពី ១ ដល់ ៥ ត/ម ត្រូវបានប្រើប្រាស់ជាទូទៅបំផុតដែលមានប្រហែល ២៩ភាគរយ នៃឡចំហាយសរុបបន្ទាប់មកគឺឡចំហាយដែលមានទំហំពី ០,១ ទៅ ០,៥ ត/ម ដែលមានប្រហែល ២៤% និង ឡចំហាយចាប់ពី ០,៥ ទៅ ១ ត/ម និងឡចំហាយតូចជាង ០,១ ត/ម មានប្រមាណ ១៦% ចំណែកឡចំហាយដែលមានទំហំពី ៥ ទៅ ១0TPH និងលើសពី ១0TPH គឺ ៨ភាគរយ និង ១ភាគរយ រៀងៗខ្លួន។<br>យោងតាមការស្ទង់មតិឆ្នាំ២០១៧ និង២០១៨ របស់ GERES លើរោងចក្រចំនួន ៤៥ បានឱ្យដឹងថា អុសជាឥន្ធនៈដ៏សំខាន់សម្រាប់ការបង្កើតចំហាយទឹក។ ចំណែកប្រេងឥន្ធនៈផ្សេងៗទៀត ដែលត្រូវបានប្រើសម្រាប់ផលិតកម្មចំហាយនៅក្នុងរោងចក្រកាត់ដេរនៅកម្ពុជារួមមានអុស (៧៣%) ប្រេងឥន្ធនៈខ្មៅ(HFO) (២%) ប្រេងម៉ាស៊ូត(៦%) អគ្គិសនី(១៩%) ហ្គាសLPG(០,១៨%) កាកសំណល់ក្រណាត់(0.៥១ %) និងដុំជីវម៉ាសគៀប (០,៤៦%) ។ តាមរយៈការស្ទង់មតិការប្រើប្រាស់ឈើសរុបនៅក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជាត្រូវបានប៉ាន់ប្រមាណថាមានប្រមាណ ១ ១៤៣ ៩២៩,៦៤ ម<sup>៣</sup> ឬ ៦៣៣ ៨៩១ តោន /ឆ្នាំ ក្នុងឆ្នាំ ២០១៧ ។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☐ Cat 2 –កែលម្អ ☑Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាពនិងលទ្ធផលរំពឹងទុកនិងអត្ថប្រយោជន៍ | **សកម្មភាព៖**<br>- ធ្វើការវាយតម្លៃឡចំហាយនៅគ្រប់វិស័យទាំងអស់ រួមមានឧស្សាហកម្ម អគារពាណិជ្ជកម្ម និងកន្លែងផ្សេងទៀតដែលមានការប្រើប្រាស់ឡចំហាយ។<br>- ការប៉ាន់ស្មានសក្ដានុពលជាមួយនឹងការកំណត់អត្តសញ្ញាណបច្ចេកវិទ្យា។<br>- សាកល្បងឡចំហាយថាមពលប្រកបដោយប្រសិទ្ធភាព។<br>- ជំរុញការប្រើប្រាស់ឡចំហាយដែលមានប្រសិទ្ធភាពថាមពល។<br>- អភិវឌ្ឍការអនុវត្តស្តង់ដាថាមពលអប្បបរមាសម្រាប់ឡចំហាយ។<br>**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**<br>- មូលដ្ឋានទិន្នន័យឡចំហាយនៃប្រទេសកម្ពុជា។<br>- កាត់បន្ថយការប្រើប្រាស់អុស និងឥន្ធនៈផ្សេងទៀតសម្រាប់ការផលិតចំហាយទឹក។<br>- ការកាត់បន្ថយ ឧស្ម័នផ្ទះកញ្ចក់<br>- សន្សំសំចៃសេដ្ឋកិច្ចដោយសារប្រសិទ្ធភាពកាន់តែមានភាពប្រសើរឡើង។ |

| | |
|---|---|
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | ការរកឃើញពីការស្ទង់មតិនៅតាមរោងចក្របានបង្ហាញពីសក្តានុពលដ៏ធំនៃការសន្សំសំចៃជីវម៉ាស់តាមរយៈការដាក់ជំនួសឡចំហាយដែលមានស្រាប់ដោយប្រើឡថ្មីដែលមានប្រសិទ្ធភាពជាងមុន។ ជាទូទៅឡចំហាយឈើដែលមានអាយុលើសពី ៨ឆ្នាំ មានសក្តានុពលខ្ពស់ក្នុងការជំនួសនេះព្រោះវាមានប្រសិទ្ធភាពទាបណាស់។ នៅក្នុងការសិក្សារបស់ GERES បានឱ្យដឹងថា ប្រហែល ៣៣ % នៃឡចំហាយសរុប ៩៧១ មានសក្តានុពលច្រើនខ្លាំងសម្រាប់ការជំនួសដោយឡថ្មី ដែលក្នុងចំណោមនោះ មាន២៣៧ ជាឡចំហាយអុសដែលមានសមត្ថភាពខុសៗគ្នា។ ដោយពិចារណាលើភាពផ្សេងគ្នានៃទំហំឡចំហាយ លទ្ធភាពនៃការកែលម្អប្រសិទ្ធភាពថាមពល និងសក្តានុពលនៃការសន្សំអុសត្រូវបានប៉ាន់ប្រមាណថា មានចំនួន ១៨៩.៨៧៣ម៣ ក្នុងមួយឆ្នាំដែលមានប្រហែល ១៧%បើប្រៀបធៀបនឹងសេណារីយ៉ូឡចំហាយដែលមានប្រសិទ្ធភាពទាប។ ការសម្រេចបែបនេះតម្រូវឱ្យមានការវិនិយោគប្រមាណ ៦.៥លានដុល្លារ ដែលនឹងត្រូវចំណាយរយៈពេលសងត្រលប់ជាមធ្យមគឺ ១,៦៤ឆ្នាំ។ ប្រសិនបើការជំនួសឡចំហាយនេះត្រូវបានអនុម័ត នោះការសន្សំសំចៃឈើអាចនាំឱ្យមានការសន្សំការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រហែល ១៨០.៣៧០ តោនក្នុងមួយឆ្នាំ។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - កម្រិតនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងរ៉ែ និងថាមពល និងក្រសួងពាក់ព័ន្ធ វិស័យឯកជន និងភាគីពាក់ព័ន្ធទាំងអស់។<br>- ភាពអាចរកបាននៃឡចំហាយប្រសិទ្ធភាពថាមពល។<br>- ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិត្រឹមត្រូវដើម្បីគាំទ្រការងារនេះ។ |
| សូចនាករនៃភាពជោគជ័យ | - ចំនួនទិន្នន័យឡចំហាយប្រមូល និងផ្សព្វផ្សាយ<br>- ចំនួនឡចំហាយមានប្រសិទ្ធភាពថាមពលដែលបានជំនួស<br>- ចំនួនទឹកប្រាក់នៃឧស្ម័នផ្ទះកញ្ចក់សន្សំបាន |
| ការរៀបចំការអនុវត្ត | នាយកដ្ឋានថាមពលកម្តៅ និងចំហេះ នៃក្រសួងរ៉ែ និងថាមពល និងវិស័យឯកជន |
| ចំណាយប៉ាន់ស្មានសរុប | ១ ៣០០ ០០០ដុល្លារ |
| ប្រភពមូលនិធិ | UNDP, FAO, AFD, UNIDO, ADB, ធនាគារពិភពលោកនិងដៃគូអភិវឌ្ឍន៍ដទៃទៀត |
| រយៈពេល | ២០២១- ២០២៣ |

១១) ឯកសារសកម្មភាពលេខ ១១៖

| | |
|---|---|
| សកម្មភាព | បង្កើតកម្មវិធីគ្រប់គ្រងថាមពលសម្រាប់អគារធំៗ និងរោងចក្រធំៗ និងតាមបែបគោលការណ៍ស្ម័គ្រចិត្តសម្រាប់សហគ្រាសធុនតូចនិងមធ្យម ស្ថិតក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ |

| | |
|---|---|
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | - ផ.យ.ប.អ.ក. ០៤៖ លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។<br>- ផ.យ.ប.អ.ឧ.ថ. ០៣៖ អនុវត្តវិធីសាស្ត្រគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល |
| សនិទានភាព | ការប្រើប្រាស់ថាមពលនៅក្នុងរោងចក្រ និងអគារបានកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារតែកំណើននៃឧស្សាហកម្មដែលពឹងផ្អែកខ្លាំងលើថាមពលអគារខ្ពស់ៗ ដែលមានម៉ាស៊ីនត្រជាក់ កម្តៅទឹក ខ្យល់ត្រជាក់ និងការប្រើប្រាស់ផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ និន្នាការនេះអាចត្រូវបានកាត់បន្ថយដោយការកែលម្អអគារ ឬរោងចក្រ ការដំឡើងអ៊ីសូឡង់ទប់កម្តៅ និងថាមពលត្រជាក់ ការដាំរុក្ខជាតិ ភ្លើងបំភ្លឺ និងប្រព័ន្ធបញ្ជា ក៏ដូចជាលទ្ធភាពនៃឧបករណ៍គ្រប់គ្រងថាមពលដើម្បីជួយម្ចាស់ រោងចក្រ អគារ /អ្នកគ្រប់គ្រងអចលនទ្រព្យ អាចគ្រប់គ្រងការប្រើប្រាស់ថាមពលរបស់ពួកគេឱ្យមានប្រសិទ្ធភាពបាន។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☐Cat 2 –កែលម្អ ☑Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយ និងការបន្សាំ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាពនិងលទ្ធផលរំពឹងទុកនិងអត្ថប្រយោជន៍ | **សកម្មភាព៖**<br>- *អនុវត្តការប្រមូលទិន្នន័យ៖* ផ្នែកសំខាន់បំផុតនៃការងារគ្រប់គ្រងថាមពល គឺការវាយតម្លៃលើគំរូនៃការប្រើប្រាស់ និងការកំណត់អត្តសញ្ញាណនៃវិធានការសន្សំសំចៃថាមពលជាក់លាក់។ ការណ៍នេះ អាចសម្រេចទៅបានតាមរយៈការធ្វើសវនកម្មថាមពល។ សវនកម្មថាមពលអាចពាក់ព័ន្ធនឹងកម្រិតលម្អិតផ្សេងៗគ្នាអាស្រ័យលើគោលបំណងនៃការសិក្សា។ គោលបំណងគឺដើម្បីប្រមូលទិន្នន័យព័ត៌មានគ្រប់គ្រាន់ និងពាក់ព័ន្ធសម្រាប់ការវាយតម្លៃពេញលេញនៃអគារ និងរោងចក្រធំៗ។<br>- *ការវិភាគនិងការរៀបចំទិន្នន័យប្រៀបធៀប៖* ទិន្នន័យដែលប្រមូលបានគឺអាស្រ័យទៅលើការវិភាគស្ថិតិ និងការជាប់ទាក់ទងគ្នាពីអគារ និងរោងចក្រហូតដល់កម្រិតប្រព័ន្ធ។ គោលបំណងនៃការវិភាគគឺដើម្បីវាយតម្លៃពីឥទ្ធិពលនៃប៉ារ៉ាម៉ែត្រឯករាជ្យលើការប្រើប្រាស់អគ្គិសនីប្រចាំឆ្នាំ ដែលអាចកំណត់អត្តសញ្ញាណចំនុចសំខាន់។<br>- *បង្កើតឧបករណ៍វាយតម្លៃសវនកម្មថាមពល៖* វិធីសាស្ត្រនេះ អាចត្រូវបានប្រើជាមគ្គុទេសក៍យោងសម្រាប់ការងារនាពេលអនាគតក៏ដូចជាសម្រាប់ម្ចាស់អគារ ឬម្ចាស់រោងចក្រ /អ្នកគ្រប់គ្រងនៅពេលធ្វើការសវនកម្មថាមពល។<br>- *រៀបចំបង្កើតថាមពលប្រៀបធៀប៖* ការប្រើប្រាស់ខ្សែកោងប្រៀបធៀប ដែលជាលទ្ធផលនៃការសិក្សាសក្តានុពលសន្សំថាមពលសរុបនៃអគារ អាចត្រូវបានគណនាដោយប្រើខ្សែកោងបធៀបនៃការអនុវត្តថាមពលសរុប។ គោលដៅនៃ |

ការអនុវត្តការងារនេះ អាចត្រូវបានកំណត់សម្រាប់ការអនុវត្តរយៈពេលខ្លី ឬយូរអង្វែង ទៅតាមប្រភេទអគារ និងរោងចក្រ។ ប្រសិនបើទិន្នន័យថាមពលរបស់ប្រព័ន្ធសេវាកម្មអាចរកបាននោះ អគារ ឬរោងចក្រក៏អាចកំណត់កម្រិតសន្សំសំចៃដែលអាចសម្រេចបានពីប្រព័ន្ធនីមួយៗដោយប្រើខ្សែកោងបធៀបនៃប្រព័ន្ធនេះបានដែរ។ នៅពេលសក្តានុពលនៃការសន្សំនៃប្រព័ន្ធនេះត្រូវបានបង្កើតឡើងរួចហើយ ម្ចាស់អគារ ឬរោងចក្រអាចផ្តល់អាទិភាពដល់គម្រោងកែលម្អថាមពលយោងទៅតាមវិសាលភាពនៃការសន្សំនៅតាមប្រព័ន្ធនីមួយៗដែលអាចសម្រេចបាន។ សន្ទស្សន៍ថាមពលត្រូវបានគេទទួលស្គាល់យ៉ាងល្អថាជាឧបករណ៍សំខាន់មួយក្នុងការកំណត់តម្រូវការថាមពលបច្ចុប្បន្ន និងអនាគតនៃអគារ ឬកន្លែងទាំងនោះ។ មានប្រព័ន្ធសន្ទស្សន៍ ត្រូវដាក់បង្ហាញជូននៅលើគេហទំព័រដែលផ្តល់ជូនដោយរាជរដ្ឋាភិបាល និងសហគ្រាសពាណិជ្ជកម្ម ប៉ុន្តែទិន្នន័យបែបនេះ ត្រូវធ្វើបច្ចុប្បន្នភាពជាញឹកញាប់។

**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**

- *អត្ថប្រយោជន៍ហិរញ្ញវត្ថុ៖* បទពិសោធន៍ថ្មីៗបានបង្ហាញថា ប្រសិនបើកម្មវិធីគ្រប់គ្រងថាមពលត្រូវបានអនុវត្តតាមលក្ខណៈជាប្រព័ន្ធ នោះមានអត្ថប្រយោជន៍ហិរញ្ញវត្ថុគួរឱ្យកត់សម្គាល់។ អត្ថប្រយោជន៍ហិរញ្ញវត្ថុសំខាន់ៗមួយចំនួននៃការងារគ្រប់គ្រងថាមពលគឺ៖

  ១) ផលសងត្រលប់រហ័ស៖ ប្រហែលពីរឆ្នាំសម្រាប់វិធានការបង្កើនប្រសិទ្ធភាព និង ៥ឆ្នាំសម្រាប់វិធានការកែលម្អឡើងវិញ។

  ២) ផលវិនិយោគត្រឡប់ (ROI) ២០-៥០ភាគរយ(ប្រៀបធៀបទៅនឹងប្រមាណតែ ៦ ភាគរយសម្រាប់ប្រាក់កម្ចីដែលមានកាលកំណត់របស់ធនាគារ ( និង

  ៣) ការសន្សំអាចត្រូវបានប្រើដើម្បីផ្តល់ថវិកាដល់កម្មវិធីគ្រប់គ្រងថាមពល។

- *សម្រាប់ម្ចាស់អគារ និងអ្នកគ្រប់គ្រងរោងចក្រ និងបរិក្ខារថាមពល៖* ការវិនិយោគលើប្រសិទ្ធភាពថាមពលគួរតែត្រូវបានអនុវត្តដូចគ្នានឹងការសម្រេចចិត្តហិរញ្ញវត្ថុផ្សេងទៀតដែរ ហើយមិនគួរមានទៀតទេការមានលក្ខខណ្ឌច្រើនពេក ដែលកំណត់ទៅលើការវិនិយោគបែបនេះ ជាងការវិនិយោគដទៃទៀត។ ការវាយតម្លៃនៃវិធានការសន្សំសំចៃថាមពល គួរតែគិតពិចារណាពីអត្ថប្រយោជន៍កាន់តែទូលំទូលាយមានដូចជាការកែលម្អ ភាពងាយស្រួលនិងបរិស្ថានជាដើម។ ជាធម្មតារឿងនេះអាចត្រូវបានសម្រេចដោយប្រើវិធីសាស្ត្រ "វដ្តនៃការចំណាយ"។ ដូច្នេះ កម្មវិធីគ្រប់គ្រងថាមពល មិនគួរត្រូវបានចាត់ទុកថាជាកម្មវិធីដែលមិនប៉ះពាល់ដល់បរិស្ថានដែលតម្រូវឱ្យមានការចំណាយច្រើនទៀតនោះទេ ប៉ុន្តែគួរចាត់ទុកថាជាការវិនិយោគដែលនឹងនាំមកនូវចំណូលហិរញ្ញវត្ថុសំខាន់ៗសម្រាប់ស្ថាប័នមួយនៅពេលសម្រេចបានគោលដៅបរិស្ថានទាំងនោះ។

| | |
|---|---|
| | - *ប្រសិទ្ធភាពថាមពលនាំទៅរកអគារ និងរោងចក្រដែលគ្រប់គ្រងបានល្អប្រសើរជាងមុន៖* អត្ថប្រយោជន៍ជាក់ស្តែងនៃប្រសិទ្ធភាពថាមពលតាមរយៈកម្មវិធីគ្រប់គ្រងថាមពលដែលបានគ្រោងទុកគឺថាវាកាត់បន្ថយការចំណាយដែលជាចំនួនទឹកប្រាក់សន្សំច្រើនទាក់ទងនឹងអាយុកាលអគារ និងរោងចក្រ។ ទោះយ៉ាងណាក៏ដោយការកាត់បន្ថយការបញ្ចេញ និងការប្រើប្រាស់ធនធានធម្មជាតិតិចជាងមុន ឥឡូវនេះបានក្លាយជាអត្ថប្រយោជន៍រយៈពេលវែងជាងមុនថែមទៀត។ ការកែលម្អប្រសិទ្ធភាពថាមពលក៏អាចនាំឱ្យអគារ និងរោងចក្រកាន់តែប្រសើរជាមួយនឹងភាពកាន់តែងាយស្រួល បរិយាកាសការងារកាន់តែប្រសើរ អ្នកកាន់កាប់មានការពេញចិត្ត និងមានផលិតភាពកាន់តែប្រសើរឡើងថែមទៀតផង។<br>- *ភាពអាចរកបាននៃសម្ភារៈបណ្តុះបណ្តាល៖* ទាក់ទងនឹងប្រសិទ្ធភាពថាមពលសម្រាប់អគារ និងរោងចក្រ។<br>- *ប្រយោជន៍សម្រាប់វិស័យសិក្សាធិការ៖* បុគ្គលិកក្រសួង និងសាស្ត្រាចារ្យមកពីស្ថាប័នសិក្សាដែលមានចំណេះដឹងកាន់តែច្រើន អំពីវិធីកែលម្អប្រសិទ្ធភាពថាមពលសម្រាប់អគារ និងរោងចក្រធំៗ ។<br>- *អនុញ្ញាតឱ្យបុគ្គលិកក្រសួងស្វែងយល់ពីគម្រោងប្រសិទ្ធភាពថាមពល៖* ដែលមានសក្តានុពលផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់។ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | កម្មវិធីគ្រប់គ្រងថាមពលសម្រាប់អគារធំៗ និងរោងចក្រ គឺជាមធ្យោបាយដែលមានប្រសិទ្ធភាពចំណាយដើម្បីប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងជម្រើសកាត់បន្ថយចំណាយទាប។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - កម្រិតនៃកិច្ចសហប្រតិបត្តិការរវាង MME និងភាគីដែលចាប់អារម្មណ៍ជាពិសេស គឺ ម្ចាស់អគារឯកជន និងម្ចាស់រោងចក្រ។<br>- ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុទាន់ពេលវេលា<br>- អ្នកពិគ្រោះយោបល់ដែលមានសមត្ថភាព ឬក្រុមហ៊ុនពិគ្រោះយោបល់ដើម្បីគាំទ្រការងារ |
| សូចនាករនៃភាពជោគជ័យ | - ចំនួនអគារ និងរោងចក្រដែលបានចូលរួមក្នុងកម្មវិធីនេះ<br>- ចំនួនទឹកប្រាក់នៃ ឧស្ម័នផ្ទះកញ្ចក់សន្សំបាន |
| ការរៀបចំការអនុវត្ត | នាយកដ្ឋានអភិវឌ្ឍថាមពល និងនាយកដ្ឋានបច្ចេកទេសនិងគោលនយោបាយអាជីវកម្មថាមពល ក្នុងក្រសួងរ៉ែនិងថាមពល និងស្ថាប័នពាក់ព័ន្ធ |
| ចំណាយប៉ាន់ស្មានសរុប | ១ ៣០០ ០០០ដុល្លារ |
| ប្រភពមូលនិធិ | UNDP, UNEP, UNIDO, ADB, ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ដទៃទៀត |
| រយៈពេល | ២០២១-២០២៣ |

១២) ឯកសារសកម្មភាពលេខ ១២៖

| | |
|---|---|
| សកម្មភាព | បង្កើននិងរៀបចំការកសាងពង្រឹងសមត្ថភាពថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | ផ.យ.ប.អ.ក. ០៥ & ផ.យ.ប.អ.ឧ.ថ. ០៤៖ ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ |
| សនិទានភាព | គោលបំណងនៃការកសាងសមត្ថភាពលើវិស័យថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល គឺដើម្បីបង្កើនសមត្ថភាពរបស់មន្ត្រីរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដើម្បីលើកកម្ពស់ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពលនៅកម្ពុជា។ ការកសាងសមត្ថភាព គឺជាយុទ្ធសាស្ត្រមួយក្នុងការធានានិរន្តរភាពនៃកម្មវិធីថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☑Cat 2 –កែលម្អ ☐ Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយ និងការបន្សាំ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាពនិងលទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍ | **ការពិពណ៌នាសង្ខេប៖**<br>- ធ្វើការវាយតម្លៃលើតម្រូវការការកសាងសមត្ថភាព (ជាពិសេសឆ្លុះបញ្ចាំងពីតម្រូវការរបស់ក្រុមហ៊ុនអាជីវកម្ម និងឧស្សាហកម្មក្នុងស្រុក)<br>- លើកកម្ពស់ភាពជាដៃគូអភិវឌ្ឍន៍បច្ចេកវិទ្យារវាងទក្ខិណប្រទេស-ទក្ខិណប្រទេស (South - South) និងឧត្តរប្រទេស - ទក្ខិណប្រទេស (North - South)<br>- បង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពច្រើនឆ្នាំក្នុងតំបន់សម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗក្នុងវិស័យថាមពលកកើតឡើងវិញ & ប្រសិទ្ធភាពថាមពល (ជាពិសេស ឆ្លុះបញ្ចាំងពីតម្រូវការរបស់ក្រុមហ៊ុនអាជីវកម្ម និងឧស្សាហកម្មក្នុងស្រុក)<br>- សម្របសម្រួលការអនុម័ត និងការអនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពតំបន់ និងប្រមូលការគាំទ្រពីដៃគូផ្សេងៗ<br>- អភិវឌ្ឍបទដ្ឋានសមត្ថភាពបណ្តុះបណ្តាលវិញ្ញាបនប័ត្រ និងគ្រោងការណ៍ទទួលស្គាល់ និងទទួលស្គាល់លើថាមពលកកើតឡើងវិញ &ប្រសិទ្ធភាពថាមពល ដោយសម្របសម្រួលជាមួយក្រុមអាជីវកម្ម និងឧស្សាហកម្មក្នុងស្រុក។<br>- ធ្វើជាមជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ការទទួលស្គាល់ និងការបញ្ជាក់ពីមជ្ឈមណ្ឌលបណ្តុះបណ្តាល និងគ្រូបណ្តុះបណ្តាលជាតិ<br>- ការប្រតិបត្តិសិក្ខាសាលាថ្នាក់តំបន់ - អ្នកបណ្តុះបណ្តាល<br>- បណ្តុះបណ្តាលអ្នកបង្កើតគោលនយោបាយសំខាន់ៗ ក្នុងការរៀបចំផែនការគោលនយោបាយថាមពលប្រកបដោយនិរន្តរភាព និងយន្តការលើកទឹកចិត្តរួមទាំងបញ្ហាចម្រុះវិស័យ (ឧទាហរណ៍៖ ថាមពលខ្វះខាត ការបញ្ជ្រាប ការវាយតម្លៃបរិស្ថាន |

| | |
|---|---|
| | និងបទដ្ឋានក្នុងនីតិវិធីអនុម័ត គម្រោងការវាយតម្លៃអគ្គិសនី ការបញ្ជ្រាបយេនឌ័រ និងនីតិវិធីកែច្នៃ និងបញ្ចេញបច្ចេកវិទ្យា ថាមពលកកើតឡើងវិញ &ប្រសិទ្ធភាពថាមពល)<br>- បណ្តុះបណ្តាលឧបករណ៍ប្រើប្រាស់ និងនិយ័តករទាក់ទងនឹងសមាហរណកម្ម ថាមពលកកើតឡើងវិញ / ស្ថិរភាពបណ្តាញអគ្គិសនី និងប្រសិទ្ធភាពថាមពល (ឧ. ការគ្រប់គ្រងផ្នែកតម្រូវការ)<br>- ផ្តល់ការបណ្តុះបណ្តាលអភិវឌ្ឍន៍ ថាមពលកកើតឡើងវិញ & ប្រសិទ្ធភាពថាមពល ដែលផ្តោតសំខាន់លើសហគ្រាសធុនតូចនិងមធ្យមសហគ្រាសស្អាត (ដូចជាសវនករថាមពល អ្នកដំឡើងឧបករណ៍ អ្នកផ្តល់សេវាថាមពលកកើតឡើងវិញជាដើម)<br>- បង្កើនសមត្ថភាពរបស់ភាគីពាក់ព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រ និរន្តភាពបរិស្ថាន និងភាពធន់នឹងអាកាសធាតុទៅក្នុងគោលនយោបាយ និងគម្រោង<br>- បណ្តុះបណ្តាលអ្នកជំនាញលើការរៀបចំហិរញ្ញវត្ថុការរចនា និងរៀបចំផែនការគម្រោងថាមពលកកើតឡើងវិញ & ប្រសិទ្ធភាពថាមពល<br>- ធ្វើការសិក្សាជាមូលដ្ឋានស្តីពីតម្រូវការអាទិភាពស្រាវជ្រាវនៃវិស័យឧស្សាហកម្ម និងពាណិជ្ជកម្មប៉ាស៊ីហ្វិក ថាមពលកកើតឡើងវិញ & ប្រសិទ្ធភាពថាមពល<br>- បង្កើតគំរូលើកទឹកចិត្តក្នុងតំបន់ សម្រាប់ការបង្កើតកម្មវិធីស្រាវជ្រាវថ្នាក់តំបន់ ជាមួយនឹងភាពពាក់ព័ន្ធខ្ពស់សម្រាប់ឧស្សាហកម្មក្នុងស្រុក។<br><br>**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**<br>- ភាពអាចរកបាននៃសម្ភារៈបណ្តុះបណ្តាលទាក់ទងនឹង ប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ នៅក្នុងក្រសួង និងស្ថាប័នសិក្សា។<br>- បុគ្គលិកក្រសួង និងសាស្ត្រាចារ្យមកពីស្ថាប័នសិក្សាដែលមានចំណេះដឹងកាន់តែច្រើនអំពីវិធីកែលម្អ ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល<br>- អនុញ្ញាតឱ្យបុគ្គលិកក្រសួងស្វែងយល់ពីគម្រោងថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ដែលមានសក្តានុពលផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | ការអភិវឌ្ឍសមត្ថភាព គឺជាមធ្យោបាយដែលមានប្រសិទ្ធភាពចំណាយ ដើម្បីកែលម្អសមត្ថភាពធនធានមនុស្សសម្រាប់តម្រូវការក្នុងវិស័យអភិវឌ្ឍន៍ថាមពល កកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - កម្រិតនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងរ៉ែ និងថាមពល និងស្ថាប័នសិក្សា<br>- ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុទាន់ពេលវេលា<br>- អ្នកពិគ្រោះយោបល់ដែលមានសមត្ថភាព ឬក្រុមហ៊ុនពិគ្រោះយោបល់ដើម្បីគាំទ្រការងារ |

| | |
|---|---|
| សូចនាករនៃភាពជោគជ័យ | - ចំនួនសម្ភារៈបណ្តុះបណ្តាលផលិត<br>- ចំនួនសិក្ខាកាមបានទទួលការបណ្តុះបណ្តាល |
| ការរៀបចំការអនុវត្ត | អគ្គនាយកដ្ឋានថាមពល ក្រសួងរ៉ែ និងថាមពល និងស្ថាប័នបណ្តុះបណ្តាល |
| ចំណាយប៉ាន់ស្មានសរុប | ៦៥០ ០០០ ដុល្លារ |
| ប្រភពមូលនិធិ | UNDP, UNEP, UNIDO, ADB, ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ដទៃទៀត |
| រយៈពេល | ២០២១- ២០២៣ |

១៣) ឯកសារសកម្មភាពលេខ ១៣៖

| | |
|---|---|
| សកម្មភាព | បង្កើនការយល់ដឹងជាសាធារណៈលើការសន្សំសំចៃថាមពល។ |
| គោលដៅយុទ្ធសាស្ត្រ ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ | ផ.យ.ប.អ.ក. ០៥ & ផ.យ.ប.អ.ឧ.ថ. ០៤៖ ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ |
| សនិទានភាព | កម្មវិធីលើកកម្ពស់ការយល់ដឹងអំពីការសន្សំថាមពលសម្រាប់សាធារណជនមានគោលបំណងលើកកម្ពស់ និងបង្ហាញពីការអភិរក្សថាមពល និងប្រសិទ្ធភាពថាមពលនៅកម្ពុជា។ កម្មវត្ថុសំខាន់នៃកម្មវិធី គឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រសិទ្ធភាពថាមពល និងការអភិរក្សថាមពលក្នុង បរិបទនៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងដើម្បីបង្ហាញនូវដំណោះស្រាយវិធានជាក់ស្តែងអំពីការអភិរក្សថាមពលសាមញ្ញៗដែលអាចអនុវត្តដោយផ្ទាល់ពីសាធារណៈជន។ កម្មវិធីសន្សំសំចៃថាមពលឆ្លើយតបដោយផ្ទាល់ទៅនឹងអាទិភាពរបស់ប្រទេសកម្ពុជាក្នុងវិស័យប្រសិទ្ធភាពថាមពល និងចូលរួមក្នុងគោលបំណងជាតិដើម្បីកាត់បន្ថយភាពក្រីក្រ ដើម្បីសម្រេចបាននូវសន្តិសុខថាមពល និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ គម្រោងនេះផ្តោតលើវិស័យនានារាប់ទាំងនៅតាមគ្រួសារ អគាររាជរដ្ឋាភិបាល (ការិយាល័យរាជរដ្ឋាភិបាល សាលារៀន មន្ទីរពេទ្យ) និងវិស័យពាណិជ្ជកម្ម និងឯកជន (សណ្ឋាគារ/ផ្ទះសំណាក់ ភោជនីយដ្ឋាន និងមជ្ឈមណ្ឌលពាណិជ្ជកម្ម)។ |
| ប្រភេទសកម្មភាព | ☐ Cat 1 –ពង្រីក ☐ Cat 2 –កែលម្អ ☑Cat 3 – ថ្មី |
| ចំណាត់ថ្នាក់សកម្មភាព | ការកាត់បន្ថយ និងការបន្សាំ |
| ការពិពណ៌នាសង្ខេបនៃសកម្មភាពនិងលទ្ធផលរំពឹងទុកនិងអត្ថប្រយោជន៍ | **សកម្មភាព៖**<br>- ការវាយតម្លៃការយល់ដឹង<br>- សិក្ខាសាលាពិគ្រោះយោបល់សាធារណៈ<br>- ការអភិវឌ្ឍសម្ភារៈលើកកម្ពស់ការយល់ដឹងជាភាសាខ្មែរ |

| | |
|---|---|
| | - ការអភិវឌ្ឍគេហទំព័រ ឬទំព័រហ្វេសប៊ុកដែលផ្តល់ព័ត៌មានអំពីការអភិរក្សថាមពល និងប្រសិទ្ធភាពថាមពលជាភាសាខ្មែរ<br>- សិក្ខាសាលាលើកកម្ពស់ការយល់ដឹងសម្រាប់អគារសាធារណៈ (ភ្នាក់ងាររដ្ឋាភិបាល សាលារៀន និងមន្ទីរពេទ្យ) សណ្ឋាគារ/ផ្ទះសំណាក់ ភោជនីយដ្ឋាន និងអគារពាណិជ្ជកម្ម។<br>- យុទ្ធនាការលើកកម្ពស់ការយល់ដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក (ទូរទស្សន៍ វិទ្យុ សារព័ត៌មាន)<br>- យុទ្ធនាការលើកកម្ពស់ការយល់ដឹងនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា<br>**លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍៖**<br>- ព័ត៌មានស្តីពីការអភិរក្សថាមពល និងប្រសិទ្ធភាពថាមពលមានជាភាសាខ្មែរ និងផ្សព្វផ្សាយ<br>- បង្កើនការយល់ដឹងអំពីប្រសិទ្ធភាពថាមពល និងការអភិរក្សថាមពលកើនឡើង<br>- ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់<br>- ការប្រើប្រាស់អគ្គិសនីថយចុះ |
| ការវាយតម្លៃប្រសិទ្ធភាពចំណាយនៃសកម្មភាព | ការលើកកម្ពស់ការយល់ដឹង គឺជាមធ្យោបាយដែលមានប្រសិទ្ធភាពក្នុងការចំណាយ ដើម្បីលើកកម្ពស់ការសន្សំថាមពលនៅក្នុងប្រទេស ហើយវានាំមកនូវការផ្លាស់ប្តូរពិតប្រាកដចំពោះការប្រើប្រាស់ថាមពលសម្រាប់មនុស្សគ្រប់គ្នា។ |
| បុរេលក្ខខណ្ឌដែលត្រូវការសម្រាប់ការអនុវត្តប្រកបដោយជោគជ័យ | - កម្រិតនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងរ៉ែ និងថាមពល និងស្ថាប័នសិក្សា<br>- ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុទាន់ពេលវេលា |
| សូចនាករនៃភាពជោគជ័យ | - ចំនួនកន្លែងវិទ្យុដំណើរការ<br>- ចំនួនខិត្តប័ណ្ណ ប័ណ្ណព័ត៌មាន ប័ណ្ណប្រកាស និងសម្ភារៈបោះពុម្ព ចែកចាយ<br>- គេហទំព័រសន្សំសំចៃថាមពលត្រូវបានបង្កើត (ដោយមានការណែនាំអំពីការសន្សំសំចៃថាមពល និងថវិកាសន្សំបាន)<br>- ចំនួនសិក្ខាសាលាលើកកម្ពស់ការយល់ដឹង<br>- ចំនួនអ្នកចូលរួមក្នុងសិក្ខាសាលាលើកកម្ពស់ការយល់ដឹង<br>- ចំនួនកន្លែងទូរទស្សន៍ដំណើរការ<br>- ចំនួននៃការផ្សាយពាណិជ្ជកម្មកាសែត<br>- បរិមាណឧស្ម័នផ្ទះកញ្ចក់កាត់បន្ថយ |
| ការរៀបចំការអនុវត្ត | អគ្គនាយកដ្ឋានថាមពលរបស់ក្រសួងរ៉ែ និងថាមពល និងស្ថាប័នអប់រំ |
| ចំណាយប៉ាន់ស្មានសរុប | ១ ១៩០ ០០០ ដុល្លារ |
| ប្រភពមូលនិធិ | UNDP, UNEP, UNIDO, ADB, ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ដទៃទៀត |
| រយៈពេល | ២០២១-២០២៣ |




**ក្រសួងរ៉ែ និងថាមពល**

អាគារលេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣

ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ៖ (៨៥៥)២៣ ២១៩ ៥៧៤

អ៊ីម៉ែល៖ info@mme.gov.kh

ប្រអប់សំបុត្រ៖ ៤៩

KINGDOM OF CAMBODIA
Nation Religion King

Ministry of Mines and Energy

# ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុក្នុងវិស័យថាមពល ២០២១-២០២៣

# Climate Change Action Plan for Energy Sector 2021 – 2023

Climate Change Working Group for Mines and Energy Sector
December 2020

Phnom Penh, December 2021

Prakas On

The Implementation of the Climate Change Action Plan for Energy Sector 2021-2023

**Ministry of Mines and Energy**

- Having seen Constitution of the Kingdom of Cambodia;
- Having seen Royal Decree No. NS/RD/0918/925, dated 6 September 2018, on the Appointment of the Royal Government of Cambodia;
- Having seen Royal Decree No. NS/RD/0320/421, dated 30 March 2018, on the Modification and Addition to the Composition of the Royal Government of the Kingdom of Cambodia;
- Having seen Royal Kram No. NS/RK/1213/017, dated 28 June 2018, promulgating the Law on the Organization and Functioning of the Council of Ministers;
- Having seen Royal Kram No. NS /RK/1213/017 dated 09 December 2013, promulgating the Law on the Establishment of the Ministry of Mines and Energy;
- Having seen Sub-Decree No. 137/SDBK dated 31 October 2018 on the Organization and Functioning of the Ministry of Mines and Energy;
- Having seen Prakas No. 0321.ME.GDE.PK. dated 25 December 2018 on the Organization and Functioning of offices under various departments of the General Department of Energy;
- According to the meeting to discuss and decide on the final draft Climate Change Action Plan for Energy Sector 2021-2023, the last time on 10 December 2020;
- According to the necessity of the Ministry of Mines and Energy

Decides

Article 1.-

Implement the "Climate Change Action Plan for Energy Sector "2023-2021to contribute to the implementation of the Cambodia Climate Change Strategic Plan 2023-2014of the Royal Government of Cambodia.

Article 2. –

The Climate Change Action Plan for Energy Sector 2023-2021, which is put for implementation in Article 1 above, has the full content as the attached document.

Article 3. –

All relevant units and institutions, including the General Department of Energy, the Capital and Provincial Departments of Mines and Energy, the Electricity Authority of Cambodia, the Electricity of Cambodia and the Rural Electrification Fund, must jointly implement accurately and effectively the "Climate Change Action Plan for Energy Sector 2021-2023," which is put for implementation as per Article 1 above to contribute to the implementation of the Cambodia Climate Change Strategic Plan 2014-2023 of the Royal Government of Cambodia.

Article 4. –

Any Prakas and decision contrary to this Prakas shall be considered repealed.

Article 5. –

This Prakas is effective from the date of signing.

Minister of Mines and Energy

CC:

- Council of Ministers
- Cabinet of Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister
- Cabinets of Samdech, His Excellency/Her Excellency, Deputy Prime Ministers
- All Ministries and Government Institutions
- All Capital–Provincial Halls "To inform"
- As in Article 3 "To implement"
- Royal Gazette
- Records-Archives

*Informal Translation*

# Preface

